# សត្តវត្សអធម៌

## Le siècle du Mal



បញ្ញវ័ន្តខ្មែរសេរីជាច្រើនរូប បានត្រូវស្ដេចផ្ដាច់ការសីហនុបញ្ជាសម្លាប់ ដោយគ្មានជំនុំជំរះទោស (នៅត្រពាំងក្រឡឹង-ខេត្តកំពង់ស្ពឺ)

និពន្ធដោយឧប សៅ សង្ហា

គួរលើកយកមកពិចារណាដែរ

# ១

# មនោគមវិជ្ជាជាតិខ្មែរ

ប្រជាជាតិនិមួយៗ តែងតែមានមនោគមវិជ្ជាជាតិជានិច្ច សួរថាតើ មនោគមវិជ្ជាប្រជាជាតិខ្មែរ មានបែបណាដែរ ?

## អ្វីដែលហៅថាមនោគមវិជ្ជាជាតិ ?

មនោគមវិជ្ជា គឺជាគំនិតរួម របស់ពលរដ្ឋ នៃប្រជាជាតិមួយ ដូចយ៉ាង សសានា ទស្សនវិជ្ជា សង្គមធម៌ សេដ្ឋកិច្ច សីលធម៌។ល។ ដែលជា"ចក្ខុវិស័យនៃសាកលលោក"របស់ខ្លួនសំរាប់ ធ្វើពណ៌នា បកស្រាយនិងបង្ហាញ នូវភាពត្រឹមត្រូវ នៃស្ថានភាពប្រជាជាតិខ្លួន។ វាជា"ម៉ាស៊ីននៃការផ្លាស់ប្តូរ"របស់ប្រជាជាតិ ដើម្បីរកសេចក្តីរីកចំរើនក្នុងអានាគត ឬក៏វាអាចជា ទម្លាប់ដុះស្លែមួយ លែងប្រែប្រួល នោះដែរ។

មនោគមវិជ្ជាជាតិ ជាធាតុធំ របស់ប្រជាជាតិ ជាស្នូលនៃវប្បធម៌ជាតិ។ វាជាប្រព័ន្ធនៃគោលការណ៍ និងជាការត្រិះរិះ(pensée)ដែលបង្កបង្កើត ឲមានជា**រូបធម៌**(មានរូបពិត)នៃប្រជាជាតិដែលជាសពាង្គមានកម្រងក្បួន **ល័ក្ខខ័ណ្ឌឥរិយាបថ**(១)បុគ្គលម្នាក់ៗ ឬជា សមូហឥរិយាបថបណ្តាបុគ្គល សំរាប់ប្រត្តិបត្តិ រួមរស់ក្នុងវិន័យ ជាសមាជិករបស់សង្គមជាតិ។

វិន័យនេះ ជាធម៌បង្ខំដាច់ខាត ឲសមាជិកនៃសង្គមជាតិ គោរពប្រត្តិបត្តិតាម ហើយបើមាននរណាម្នាក់ មានទំនាស់នឹងគំនិតដាច់ខាតនេះ គេចាត់ទុកទង្វើនេះ ជាអសីលធម៌ ដែលអ្នកផងទាំងពួងអាចបន្ទោសបាន ជាទោស ដែលគេអាចបណ្តេញអ្នកបង្កនេះ ចេញពីសហគមន៍ ជាបទល្មើស ដែលតុលាការ អាចដាក់ទណ្ឌកម្មបាន។ រួមសេចក្តីមកមនោគមនវិជ្ជាជាតិ ជាច្បាប់របស់ជាតិផង និងជាលំនាំសីលធម័នៃប្រជាពលរដ្ឋផង។

តែមនោគមវិជ្ជាជាតិ ក៏អាចជាមធ្យោបាយសំរាប់ក្រុមអ្នកឧកញ្ញា និងអ្នកកាន់អំណាច យកវា មកប្រើ សំរាប់បំរើប្រយោជន៏បក្សពួក ព្រោះពួកគាត់ ជាអ្នកមានអំណាច អាចសំរេចកិច្ចការគ្រប់បែបយ៉ាង ក្នុងវិស័យសេដ្ឋកិច្ចក្តី សង្គមកិច្ចក្តី នៃប្រជាជាតិ។ តែកម្លាំង និងអធ្យោ

ក្តម(suprématie)អ្នកមានអំណាចទាំនោះ វាអាស្រ័យទៅលើឆន្ទៈនៃប្រជាពលរដ្ឋ ព្រោះ"មនោគមវិជ្ជាជាតិ"ជារូបភាព និងជាស្រមោល នៃចិត្តគំនិត នៃប្រជាពលរដ្ឋ។ ដូច្នេះអ្វី ដែលពួកគេអាចធ្វើបាន គឺវាអាសស្រ័យ ទៅលើអំណាចរបស់ពួកគេ លើឆន្ទៈប្រជាពលរដ្ឋ និងលើអំណាចរដ្ឋ។ រួមសេចក្តីមក បើរាស្ត្រល្ងង់ខ្លៅ បើរដ្ឋទុនខ្សោយ គឺឱកាសល្អ សំរាប់អ្នកមានអំណាច ប្រើអំណាចដែលគេមាន ដើម្បីរកប្រយោជន៍ផ្ទាល់របស់គេជាពុំខាន។

## ប្រជាជាតិមាននីតិរដ្ឋ

របៀបមនោគមវិជ្ជា កើតមានឡើងពី ការព្រមព្រៀងគ្នានៃពលរដ្ឋ(citoyen)។ គឺប្រជាពលរដ្ឋដែលជាជនាធិបតី មានអំណាច តាមច្បាប់ តាមបទបញ្ជា ដែលខ្លួនជាអ្នកបង្កើតដោយខ្លួនឯង។

ដូច្នេះ គ្រប់កិច្ចការដែលមានទំនាក់ទំនងនឹងប្រជាជាតិ គឺត្រូវចាំបាច់កើតពីឆន្ទៈប្រជាពលរដ្ឋជានិច្ច ព្រោះប្រជាពលរដ្ឋជាម្ចាស់នៃអំណាចរដ្ឋ។

ក្នុងប្រជាជាតិមាននីតិរដ្ឋ គឺមានវត្តមាននៃ សមភាពនិយម សាមគ្គីភាពនិយម នឹងសនិទាននិយម(rationalisme)ដែលជាកត្តា នាំឲជាតិ មានស្ថិរភាព និងឲប្រជាពលរដ្ឋមាន**មនោសារៈ**(ចិត្តខ្ពស់)ដែលជាមូលដ្ឋានចាំបាច់ សំរាប់ធ្វើអភិវឌ្ឍជាតិ ដើម្បីកំណើនសេដ្ឋកិច្ចសង្គមកិច្ច ឲប្រសើរឡើង សំរាប់សុខុមាលភាពក្នុង**របបជីវភាព**(២)នៃប្រជាពលរដ្ឋ។

## ប្រជាជាតិ ដែលមានអំណាចជាប្រពៃណី ជាអំណាចគ្រប់គ្រង

របៀបមនោគមវិជ្ជា កើតមកពីការព្រមព្រៀងគ្នារវាងពួក**អភិជន**(seigneur)ដែលជា **វរជន** (élite)នៃអំណាច គ្មានការរញ្ជួរា យកលក្ខន្តិកៈបុគ្គលមានឯកសិទ្ធ ដែលក្រុមខ្លួន មានពីកំណើតមក មកធ្វើជាអំណាចរដ្ឋ ឬអំណាចអាទិទេព ត្រួតត្រាលើប្រជាពលរដ្ឋ តាំងខ្លួនឯងដោយខ្លួនឯង ជាម្ចាស់នៃរាស្ត្រ និងប្រជាជាតិ។

## ប្រជាជាតិ ដែលមានអំណាចជាទិស្រឡាញ់(៣)ជាអំណាចគ្រប់គ្រង

របៀបមនោគមវិជ្ជា កើតមកពីបុគ្គលម្នាក់ ដែលប្រជាពលរដ្ឋ ចាត់ទុកជា"**មេ**"របស់ប្រជាជាតិ ដែលជាមនុស្សខ្លាំង គ្មានការរញ្ញេរា យកលក្ខណៈជាបុគ្គលពិសេស ដែលខ្លួនមានពីសេចក្តីស្រឡាញ់ពីប្រជាពលរដ្ឋ មកផ្លៀតផ្លៃ ធ្វើជាអំណាចផ្ទាល់ខ្លួន សំរាប់ដឹកនាំជាតិ តាមតែអំពើចិត្តរបស់ខ្លួន ដើម្បីរក្សាអំណាចខ្លួន តាមឧបាយកលប្រជាភិថុតិ **បន្ទំខ្លួន**(៤) ថាខ្លួនជា" មនុស្សនៃរាស្ត្រ"មាន**សមុទាចារ**(សេចក្តីតាំងចិត្ត)បំរើរាស្ត្រ ក្នុងសង្គមរាស្ត្រនិយម។ តែចំណេរកាលតមក អំណាចផ្ទាល់ខ្លួន តែងតែក្លាយជានិច្ច ទៅជាអំណាចផ្តាច់ការ ព្រោះរបបនេះ ជារបបគ្មានលិទ្ធិប្រជាធិបតេយ្យជាគ្រឹះ។

## ***អ្វីជាមនោគមវិជ្ជាខ្មែរ?***

យោងទៅតាមវិបរិយាស(vicissitude)នៃធាតុអំណាចដែលមានក្នុងប្រជាជាតិខ្មែរ ខ្មែរយើងតែងតែមានជំនឿថា ខ្លួនមានការពិបាក សំគាល់ថាអ្វី ដែលជា មនោគមវិជ្ជាជាតិខ្លួន។ តែតាមការពិត បើយើងយកប្រវត្តិសាស្ត្រជាតិខ្មែរ មកឆ្លុះមើល យើងឃើញថា វាមាន**និយតភាព**(régularité)ក្នុងសតិខ្មែរអំពីមនោគមវិជ្ជាជាតិ ដែលយើងសាកល្បងលើកមកបង្ហាញជូនក្នុងការសិក្សារបស់យើងនេះ។

### ១.ក្នុងសម័យអង្គរ(សតវត្សទី៨ដល់ទី១៥)

បើយើងយកនិយមន័យនៃ"មនោគមវិជ្ជាជាតិ"ខាងលើមកឆ្លុះមើល សំរាប់រក មនោគមវិជ្ជាជាតិខ្មែរក្នុងសម័យអង្គរ គឺគ្មានអ្វីក្រៅពី ជំនឿលើព្រហ្មញ្ញសាសនា និងការគោរពរាជសក្តិ(អំណាចហ្លួង)នោះឡើយ ព្រោះវត្ថុធាតុទាំងពីរនេះ ជាគំនិតរួមរបស់ប្រជារាស្ត្រខ្មែរ។ តែយើងដឹងដែរថា ព្រហ្មញ្ញសាសនា ជាសាសនា ដែលទុកអាទិទេពជាអ្នកសំរេចលើជោគវាសនានៃមនុស្ស។ មនុស្សត្រូវចំបាច់មានជំនួយពីអាទីទេព តាមការបួងសួង អង្វរ សុំប្រសិទ្ធិពរ ឲបានសំរេចនូវអ្វីៗមួយ ដែលខ្លួនចង់បាន។ ជាមួយជំនឿសាសនានេះ ស្រុកខ្មែរ ក្នុងសម័យអង្គរ មានអំណាចដឹកនាំ ជាអំណាចរាជាធិបតេយ្យ។ ធាតុសង្គមខ្មែរ ជាសង្គមសក្តិភូមិ មាន***វណ្ណៈវិភាគ****(៥)*ក្នុង**សង្គមនិម្មាណ**(៦)ជាបួនវណ្ណៈ មានវណ្ណៈក្សត្រ ជាវណ្ណៈអ្នកដឹកនាំនយោបាយ មានវណ្ណៈព្រាហ្មណ៍ ជាវណ្ណៈ អ្នកដឹកនាំសាសនា វណ្ណៈវេស្សៈ ជាសិប្បករ ប្រជាកសិករ ដែលខ្មែរយើងមានទម្លាប់ហៅថា"**អ្នកជា**"ឯចំណែកវណៈសុទ្ទៈ ជា"**អ្នកងារ**" ជាទាស

ករ ដែលគេទុកសម្រាប់តែប្រើ ជាខ្ញុំបំរើ។

ក្នុងសង្គមមានវណ្ណៈនេះ តើអាចមានការរួបរួម រវាងវណ្ណៈនឹងវណ្ណៈបានដែរឬទេ?

ក្នុងទស្សនៈព្រហ្មញ្ញសាសនា វណ្ណៈវិភាគដែលមានក្នុងសង្គម ជាការបែងចែកមានប្រយោជន៍សំរាប់សង្គម ព្រោះជាការបែងចែក នៃទួនាទីរបស់វណ្ណៈនិមួយៗ ដើម្បីឲសង្គម មានដំណើរល្អក្នុងការរស់នៅ គឺវាដូចជាប្រេង សំរាប់ឲម៉ាស៊ីនសង្គមដើរ រដើមបានល្អ។ វណ្ណៈនិមួយៗស្គាល់ទួនាទីរបស់ខ្លួនដែលខ្លួនត្រូវធ្វើ ដើម្បីប្រយោជន៍របស់វណ្ណៈខ្លួនឯងផង និងដើម្បីប្រយោជន៍សង្គមផង។ ក្នុងទស្សនៈនេះ គ្មានសញ្ញាណនៃការជិះជាន់រកប្រយោជន៍រវាងវណ្ណៈនោះឡើយ ដូច្នេះអត្ថន័យនៃពាក្យវណ្ណៈ គឺជាកាតព្វកិច្ច ក្នុងន័យដ៏ថ្លៃថ្នូរមួយតែប៉ុណ្ណោះ ដូចយ៉ាង ក្សត្រមានកាតព្វកិច្ច ដឹកនាំជាតិ ដើម្បីរកសេចក្តីសុខឲគេរ ពួកព្រាហ្មណ៍មានកតព្វកិច្ច ថ្វាយដង្វាយដល់អាទិទេព ដើម្បីរកសេចក្តីសុខជូនមនុស្សលោក អ្នកជា ប្រកបរបរគ្រប់បែបយ៉ាងដើម្បីការរស់នៅ និងបំពេញសេចក្តីត្រូវការ នៃមនុស្សលោក ឯចំណែងអ្នកងារ ជូនកម្លាំងរបស់ខ្លួន ដែលជា**កម្លាំងពល**(៧)ដល់វណ្ណៈដ៏ទៃទៀត ដើម្បីឲសង្គមមានដំណើរជាប្រក្រតី។ សុខមកម្មនៃសង្គម មានពីអត្ថិភាពនៃវណ្ណៈជាប្រយោជន៍នេះឯង ព្រោះវាជាស្តំសំរាប់ទ្រទ្រង់សង្គម។

កតព្វកិច្ចនៃវណ្ណៈនេះឯង វានាំឲមាន**សិនិទ្ធពល**(cohésion)សង្គម ដែលជាកត្តានាំឲមានស្ថិរភាពនយោបាយ និងសន្តិភាពសង្គម។ ម្យ៉ាងមួយវិញទៀត កតព្វកិច្ចនៃវណ្ណៈនេះ វាកម្លាយជំនឿសាសនា ឲទៅជាទំនៀមជាតិ ជារបៀបរស់នៅ ជាធម្មតារបស់ប្រជាពលរដ្ឋ។ ដូច្នេះ បើយោងលើការរៀបរាប់ខាងលើនេះ យើងអាចសន្និដ្ឋានបានថា ក្នុងសម័យបុរាណ ប្រទេសណាដែលយកព្រហ្មញ្ញសាសនា ជាសាសនាជាតិ មនោគមវិជ្ជាជាតិគឺព្រហ្មញ្ញសាសានានោះឯង។ ដូច្នេះយើងអាចធ្វើការស្មានបានថា ប្រជាជាតិនោះ មានបាវចនា គឺ”ជាតិនិងព្រហ្មញ្ញសាសនា”។

ត្រឡប់មកមើលស្រុកខ្មែរវិញ ក្នុងសម័យអង្គរ ខ្មែរគោរពព្រហ្មញ្ញសាសនាផង ពុទ្ធសាសនាផង និងមានជំនឿទៅលើ**ជីវចលនិយម**(animisme)ផង ដែលជាជំនឿអាយ របស់ជនជាតិខ្មែរ តាំងពីមុនសម័យអង្គរមកម្លេះ។ ជំនឿអាយនេះឯង ដែលអ្នកចេះដឹងខ្មែរយើង មានជំនឿថា ជាតិសាសន៍ខ្មែរ មានអារ្យធម៌អាយរបស់ខ្លួន មុននឹងបានទទួលឥទ្ធពលអារ្យធម៌ឥណ្ឌា។ អារ្យ

ធម៌នេះបានកើតមានឡើងតាំងពី កទឹកដីម្លេះ គ្រាន់តែខ្មែរយើងមិនបានសរសេរទុក មាន ត្រឹមតែទម្លាប់ធ្វើតៗគ្នាប៉ុណ្ណោះ តែអារ្យធម៌នេះបានទុកជា កេរ៍ដំណែលជាសក្ខីកម្មភាពជា ច្រើន ដូចយ៉ាងប្រាសាទថ្មតូចតាចក្នុងភូមិភាគអង្គរបូរី ប្រាសាទសង់ពីឥដ្ឋនៅសម្បូព្រៃគុក ក្នុងខេត្តកំពុងធំសព្វថ្ងៃ ល្បែងរបាំប្រពៃណីច្រើនបែបច្រើនយ៉ាង ជាពិសេស ភាសានិយាយស្ដី សម្រាប់ប្រស្រ័យគ្នាមានរហូតតាំងពីពេលនោះមក។

អារ្យធម៍អាយនេះឯង ដែលជាថ្នាលសំរាប់ទទួលអារ្យធម៍ឥណ្ឌា យកមកកែឆ្នៃវាឲសមស្របខ្លះ នឹងជំនឿអាយរបស់ខ្មែរ ដើម្បីឲអារ្យធម៌ថ្មីនេះ មានប្រជាប្រែភាពក្នុងសង្គមខ្មែរផង និង សំរាប់រកឯកភាពក្នុងជំនឿសាសនាផង និងឯកភាពជាតិផង។ អ្នកដែលមានស្នាដៃក្នុង ទង្វើដ៏ពិសេសសំរាប់ជាតិខ្មែរនេះ គឺព្រះ**បាទជ័យវរ្មនទី២**(៨០២-៨៥០) ស្នាព្រះហស្ថជាអាថ៌ របស់ព្រះអង្គ មានការរំដោះប្រទេសពីចំណុះប្រទេសជ្វា ឲមានឥស្សរភាព ការបង្រួបបង្រួម ជាតិ(ចេនឡាដីគោក និងចេឡាដីលិចទឹក)ឲមានឯកភាពឡើងវិញ ដូរឈ្មោះនគរខ្មែរ ឲហៅ ថា នគរកម្ពុជា ការលើកតាំងព្រហ្មញ្ញសាសនាជាសាសនាតែមួយរបស់រដ្ឋ ដោយយកលទ្ធិទេវ រាជ ជាលទ្ធិព្រះមហាក្សត្យ។ ត្រីវណ្ណកម្មដ៍សំខាន់នេះ បានក្លាយជាយោងសំរាប់អ្នកដឹកនាំ បន្ត ៗគ្នាក្នុងសម័យអង្គរ។ ទោះបីចាប់ពីសតវត្សទី១៣មក ពុទ្ធសាសនាកាន់តែមានឥទ្ធិពលខ្លាំង ឡើងៗក្នុងសង្គមខ្មែរ ជាពិសេសក្នុងមជ្ឈដ្ឋានអ្នកដឹកនាំ តែទំនៀមដែលជាស្នាព្រះហស្ថ ព្រះបាទជ័យវរ្មន នៅមានឥទ្ធិពលជានិច្ចក្នុងរបៀបដឹកនាំជាតិ ដូចយ៉ាង ក្នុងរឿងព្រេង ព្រះបាទតាត្រសក់ផ្អែម(១៣៤០ ?)ជាការកត់បញ្ជាក់ពីការបន្តឥទ្ធពលទំនៀមនេះក្នុងសង្គម ខ្មែរនិយមព្រះពុទ្ធសាសនា រហូតមកដល់បច្ចុប្បន្ននេះ ក្នុងពិធីជាច្រើនក្នុងព្រះបរមរាជ វាំង បុណ្យជាប្រពៃណីនិងនៅក្នុងទំនៀមទំលាប់នៃការរស់នៅធម្មតា របស់ជាតិសាសន៍ខ្មែរ។ បើយោងទៅតាមការរៀបរាប់ខាងលើនេះ ក្នុងសម័យអង្គរ មនោគមនវិជ្ជាជាតិ គឺជាព្រហ្មញ្ញ សាសនា និយមលទ្ធិទេវរាជ។ បើយើងធ្វើការស្មាននូវបាវចនាជាតិក្នុងសម័យអង្គរ គឺ ជាតិ ព្រហ្មញ្ញសាសនា និងព្រះមហាក្សត្យ ដែលជាមនុស្សប្រសិទ្ធិ**មានជាតិ**(incarnation)ជាអាទិ ទេព។

**២.សម័យអន្តរកាល(សតវត្សទី១៣ដល់១៥)**

សម័យអន្តរកាល គឺចាប់ផ្តើមឡើងពីការធ្វើឃាត**ព្រះបាទជ័យវរ្ម័នទី៨**(១៣២៧ ១៣៤០)ឬព្រះសីហនុរាជដែលជាមហាក្សត្រចុងក្រោយបង្អស់នៃ**វង្សាវលី**(lignée)មហាក្សត្រអង្គរ ដោយតាត្រសក់ផ្អែម ដែលជាអ្នកចាំសួនត្រសក់របស់ព្រះមហាក្សត្រ។ ឃាតករនេះ ក៏ត្រូវបាន សេនាបតីមន្ត្រីទាំងអស់ អញ្ជើញឲឡើងគ្រោងរាជ្យសម្បត្តិ បន្តពីជនរងគ្រោះទៅវិញ។ នេះជាហេតុការពិសេសមួយ ព្រោះយើងឃើញថា សេនាបតីមន្ត្រី ពេលនោះបានលើកយកលទ្ធិព្រះពុទ្ធ មកធ្វើការបកស្រាយ ក្នុងអំពើសម្លាប់ស្តេចនេះ តាមទ្រឹស្តី"កម្មផល"៖

ស្តេចត្រូវគេសម្លាប់ ព្រោះជាកម្មផលរបស់ព្រះអង្គ ឯចំណែកតាត្រសក់ផ្អែម បានធ្វើឃាតស្តេចក៏ជាកម្មផលរបស់គាត់ដែរ ទី១ទទួលកម្មផលអាក្រក់ ទី២ទទួលកម្មផលល្អ មួយទទួលបាបមួយទៀតទទួលបុណ្យ ដែលជាបារមី អាចឡើងសោយរាជសម្បត្តិបាន។ ការពិតក្នុងព្រឹត្តការណ៍ពិសេសនេះ មានលាក់នូវបដិវត្តន៍អហឹង្សាពីសំណាក់សេនាបតីមន្ត្រី ដើម្បីនាំគ្នាលើកតំកើងពុទ្ធសាសនា ជាសាសនារដ្ឋ។ ការឡើងសោយរាជ្យសម្បត្តិរបស់ព្រះបាទតាត្រសក់ផ្អែម ជាទីដើមនៃជោគជ័យពុទ្ធសាសនាឥតត្រឡប់ក្រោយបានវិញ លើព្រហ្មញ្ញសាសនា ប៉ុន្តែពុំមែនជាជ័យជំនះលុបបំបាត់សាសនាចាស់ទាំងស្រុងនោះឡើយ គឺជាជ័យជំនះសំរាប់ កែទម្រង់ចិត្តគំនិតវណ្ណៈអ្នកដឹកនាំ ឲស្របតាមគន្លងធម៌ព្រះពុទ្ធ តែអ្វីដែលជាទំនៀមមាននៅក្នុងលទ្ធិព្រាហ្មណ៍ អ្នកដឹកនាំថ្មី គេនៅរក្សាទុកជាច្រើន ដើម្បីរក្សាកេរ៍មរតកវប្បធម៌បុរាណខ្មែរ។ ឧទាហរណ៏៖ ទង្វើទ្រទ្រង់ពុទ្ធសាសនារបស់មហាក្សត្រថ្មី គឺការបញ្ជូនរាជទូតទៅស្រុកលាវ សូមចម្លងព្រះត្រៃបិដក ដែលប្រទេសនេះ គេមានប្រាំច្បាប់ ទុកជាសាស្រ្តា សំរាប់ធ្វើការសិក្សា ដើម្បីកំណើននៃពុទ្ធសាសនាក្នុងនគរខ្មែរ ប៉ុន្តែព្រះមហាក្សត្រ ទ្រង់នៅតែរក្សារាជពិធីព្រហ្មញ្ញសាសនាក្នុងបរមរាជវាំង ដូចយ៉ាង តែងតាំង ក្រុមបុរោហិតរក្សាព្រះខាន់ជាថ្មី ដែលមានចំនួន៧នាក់។ ការអភិរក្សនេះ មានគោលបំណងចង់រក្សាវណ្ណៈក្សត្រ ឲបានគង់វង់អង្វែងឆ្ងាយក្នុងសង្គមជាតិខ្មែរផង និងទុកដានប្រពៃណីខ្មែរបុរាណ ដែលកើតចេញមកពីលទ្ធិព្រហ្មណ៍ផង។ បើយោងទៅតាមការរៀបរាប់ខាងលើនេះ យើងអាចកាត់ស្មានបានថា មនោគមវិជ្ជាជាតិខ្មែរក្នុងសម័យអន្តរកាលនោះ គឺពុទ្ធសាសនា និងព្រះមហាក្សត្រ តែជាស្តេច មានជាតិជាមនុស្សជួយតម្រាយធម៌ព្រះពុទ្ធក្នុងនគរ។ សម្មតិកម្មនៃបាវចនា មានក្នុងជំនាន់នោះ គឺជាតិ ពុទ្ធសាសនា និងព្រះមហាក្សត្រ។

**៣.សម័យកណ្តាល(សតវត្សទី១៥ដល់ទី១៨)**

ជាសម័យ ដែលស្រុកខ្មែរ កើតវិករវ ដោយសង្គ្រាមឈ្លានពានពីសំណាក់ប្រទេសជិតខាងផង និងមានសង្គ្រាមក្នុងស្រុករវាងខ្មែរនិងខ្មែរខ្លះទៀតផង វានាំឲប្រជាជាតិខ្មែរធ្លាក់ចុះទន់ខ្សោយ នាំឲអារ្យធម៌ជាតិចុះអន់ថយក្រោយទៅវិញទៀត។

ឧទាហរណ៍ ក្នុងផែនដី ព្រះបរមខត្តិយាមហាចន្ទរាជា(១៥១៦ ១៥៦៦)ឬមហាចន្ទ ក្រោយពីបានច្បាំងឈ្នះសៀមនៅខេត្តសៀមរាបមក ទ្រង់បានដូររាជធានី ពីភ្នំពេញ មកតាំងនៅលង្វែកដែលទីកន្លែងដ៏ល្អមួយ សំរាប់រៀបចំយុទ្ធសាស្ត្រយោធាការពាររាជធានី។

មកដល់ផែនដី ព្រះបរមិន្ទរាជា(១៥៦៦ ១៥៧៦) ជាព្រះរាជបុត្រមហាចន្ទ រហូតដល់ដល់ឆ្នាំ១៥៩៤ ក្នុងផែនដី ព្រះបាទជ័យជេដ្ឋា(១៥៨៥ ?)ជាបុត្រព្រះសត្ថា(១៥៧៦ ១៥៨៥)ជាព្រះអយ្យកោ(ចៅ)របស់ព្រះបរមិន្ទរាជា ដែលជាឆ្នាំដែលព្រះមហាឧភយោរាជ ព្រះនាមស្រីសុរិយោព័ណ៌ សុខចិត្តបើកទ្វារបន្ទាយលង្វែក ចុះចូលនឹងទ័ពសៀម តាមផ្លូវចរចារ ដើម្បីបញ្ចប់សង្គ្រាមនៅស្រុកខ្មែរ តាមការស្នើពី ព្រះចៅសៀម នរេន្ទ្រសូរ ឯចំណែកព្រះជ័យជេដ្ឋា ជាមហាក្សត្យខ្មែរ ទ្រង់បានរត់ចេញពីបន្ទាយលង្វែក ហើយមិនដឹងទៅលាក់ខ្លួននៅទីតំបន់ណាឡើយ (តាមឯកសារ ព្រះអង្គទៅសុគតឯខេត្តស្ទឹងត្រែង)។

ពេលដែលសៀមមានជ័យជំនះហើយ គេដកទ័ពចេញពីស្រុកខ្មែរ ដោយចាប់យកព្រះឧភ-យោរាជខ្មែរទៅស្រុកសៀមផង ហើយទុកឲមេហាមន្ត្រីសៀមម្នាក់ នៅត្រួតត្រាស្រុកខ្មែរ ដោយយកស្រុកឧដុង្គ ជាទីបញ្ជាការជាន់ខ្ពស់នៃអាជ្ញាធរសៀម នៅពេលនោះ មានព្រះរាមាធិបតីអុង ដែលអ្នកទាំងពួងហៅថា ព្រះរាមាជើងព្រៃ ជាព្រះអង្គវង្សធំមួយ ជាមេទ័ពខ្មែរល្បីមួយប្រកាសខ្លួនជាស្តេចខ្មែរ ហើយកេណ្ឌពលភ្លាម លើកទ័ពទៅស្ទាក់វាយកងទ័ពសៀមតាមផ្លូវខេត្តទ្រាំង ដើម្បីមិនឲព្រះមហាក្សត្យសៀមចុះទៅសមុទ្រចេញពីស្រុកខ្មែរបាន ស្ទាក់ផ្លូវឯខេត្តនគរវត្ត បាត់ដំបង ដើម្បីកុំឲទ័ពជើងគោកសៀមចេញពីស្រុកខ្មែរ ដើម្បីវាយដណ្តើមយកមកវិញនូវកេតនភ័ណ្ឌជាតិខ្មែរ ដែលសៀម គេប្រមូលគ្មានសល់អ្វីសោះពីបន្ទាយលង្វែកយកទៅស្រុកគេ ជាមួយគ្នានោះដែរ ព្រះរាមាជើងព្រៃ បានរៀបក្បួនទ័ពនៅ

ឯភ្នំពេញ ដើម្បី ទៅវាយស្រុកឧដុង្គ។ ពលទ័ពខ្មែរ នៅក្រោមអាជ្ញាធរសៀម នៅស្រុក

ឧដុង្គ ដឹងថាព្រះរាមាជើងព្រៃលើកទ័ពមក ក៏នាំគ្នារត់ចោលមេកងទ័ពសៀមអស់ មហាមន្ត្រីសៀម នៅសល់តែទ័ពលាវ២០០០នាក់ ក៏ច្បាំងចាញ់ទ័ពខ្មែរ ស្លាប់ និងនាំគ្នារត់ទៅស្រុកវិញអស់ តែជាអកុសលទ័ពខ្មែរឯទៀត ដែលមានបេសកកម្មវាយដណ្តើមយកកេតនភ័ណ្ឌជាតិខ្មែរ មិនអាចសម្រេចដូចបំណងបាន ព្រោះទ័ពសៀម បាននាំគ្នាឆ្លងដែនទៅស្រុកគេវិញទាន់។

បីឆ្នាំក្រោយមក ព្រះរាមាជើងព្រៃ ត្រូវបានជនជាតិបារាំងម្នាក់ឈ្មោះល្វីវេឡូហ្ស ជាមួយទាហានបារាំង២៤នាក់ទៀត ប្រើឧបាយកល ធ្វើឃាតព្រះអង្គ ព្រមទាំងមន្ត្រីខ្មែរជាច្រើននាក់ទៀតនៅក្នុងព្រះបរមរាជវាំងតែម្តង។ បន្ទាប់មក លោកល្វីវេឡូហ្ស ជាមួយទាហានបារាំង៤នាក់ និងទាហានខ្មែរជាច្រើន បាននាំគ្នាទៅអញ្ជើញ ព្រះអង្គតន់ ជាបុត្រកណ្តាលព្រះជ័យជេដ្ឋា ពីខេត្តស្ទឹងត្រែង ចូលសោយរាជសម្បត្តិ ក្នុងឆ្នាំ១៥៩៧ នៅស្រុកស្រីសន្ធរ។

មុនសៀមវាយយកបានបន្ទាយលង្វែក ស្រុកខ្មែរនៅជាស្រុករុងរឿងនៅឡើយ ក្រោយពីបែកបន្ទាយលង្វែកមក រហូតតមកដល់សតវត្សទី១៩ ជារយៈពេលគ្រោះដោកគ្រោះដាំ សំរាប់ស្រុកខ្មែរ ដែលនាំឲបាត់អស់នូវអ្វីៗគ្រប់បែបយ៉ាង ដូចយ៉ាងអារ្យធម៌ ទឹកដីកម្ពុជាក្រោម ត្រូវយួនបញ្ចូលជាឧបសម្ពន្ធ ឯបែកខាងមស្ទឹម ពាយ័ត្យ ត្រូវ សៀមបញ្ចូលជាខេត្តរបស់គេ។ មិនតែប៉ុណ្ណោះ ស្រុកខ្មែរ រស់ជានគរនៅក្រោមអំណាចសៀមយួន ដូចយ៉ាងព្រះបាទអង្គដួង (១៨៤៣ ១៨៦០)ជាព្រះមហាក្សត្យឡើងសោយរាជសម្បត្តិដោយមានការសម្របសម្រួល**ជាសហវិវិតរាជ្យ**(condominium)រវាងស្តេចសៀមនិងយួន លើស្រុកខ្មែរ។

ការបាត់ដឹងថា ជាតិខ្លួន ជាជាតិធ្លាប់មានអារ្យធម៌រុងរឿង ធ្វើឲជនជាតិខ្មែរមានសតិប្រហោង គ្មានមនោគមវិជ្ជាជាតិ។ វប្បធម៌ និងសង្គមធម៌ ដែលធ្លាប់មាន លែងលូតលស់ទៅមុខ មិនតែប៉ុណ្ណោះ ថែមទាំងចុះអន់ថយក្រោយទៅវិញទៀតផង ត្បិតជនជាតិខ្មែរគ្មានឱកាសនឹងសាងបន្តពីបុព្វបុរស ហើយក៏គ្មានលទ្ធភាព នឹងរក្សាគ្រងទុក ឲគង់វង្ស ទ្រព្យមត៏កអារ្យធម៍ជាតិខ្លួនទៅទៀត។ ក្នុងស្ថានភាពបែបនេះ យើងអាចសន្និដ្ឋានបានថា សម័យកណ្តាល ជាសម័យអន្ធកាគតសំរាប់ប្រជាជាតិខ្មែរ។

**៤.សម័យអាណាព្យាបាលបារាំងសែស(១៨៦៣ ១៩៥៣)**

បួនសតវត្សក្នុងអត្ថង្គត ឈាមជាតិខ្មែរហូរអស់ពីសព៌ាង្គ ក្បោះអស់កម្លាំងជាតិ ប្រជាជាតិខ្មែររស់នៅក្នុង**សមន្ធការ**(ប្រដូចនឹងខ្ទាក់ងងឹតសូន្យសុង) ត្រូវការអ្នកនាំផ្លូវ ឲចេញរួច ពីសហវិរិតរាជ្យ ជាឃាត ជាប្រយោជន៍ របស់សៀមយួន ដែលជាគ្រោះថ្នាក់ដល់ជាតិខ្មែរ នាំឲព្រះបាទអង្គដួង មានចក្ខុវិស័យ តាមការណែនាំរបស់បព្វជិតបារាំងម្នាក់ មាននាម សម្តេចម៉ុស មានបំណង ទៅពឹងនគរបារាំង ឲមកជួយសង្គ្រោះជាតិខ្មែរ ពីគ្រោះថ្នាក់ដល់អាយុជីវិត។

ក្នុងឆ្នាំ១៨៦៣ ព្រះបាទនរោត្តម(១៨៦០ ១៩០៤) ឡើងសោយរាជសម្បត្តិ បន្តពីព្រះបីតា សំរេចចិត្ត ចុះហត្ថលេខា សន្ធិសញ្ញានៃអាណាព្យាបាលបារាំង ជាមួយនឹងតំណាង ព្រះចៅអធិរាជណាប៉ូឡេអុងទី៣។

ចំពោះបារាំង សន្ធិសញ្ញានេះ គ្រាន់ជាការបន្តនយោបាយ រុលចូលនៃអាណានិគមបារាំង មកក្នុងតំបន់អាស៊ីអគ្នេយ៍ ពេលនោះបារាំង គេមើលឃើញថា ប្រទេសខ្មែរ អាចជាទ្វារផ្លូវទឹកតាមមហាន្ទីមេគុង បន្តពីសមុទ្យ សំរាប់ធ្វើពាណិជ្ជកម្ម ជាមួយប្រទេសចិន តែជាអកុសល លទ្ធភាពជាសក្តនុពលនេះ វាមានឧបសគ្គធម្មជាតិរារាំង នៅព្រំប្រទល់ខ្មែរលាវ មិនអាច ឲនាវាមានចំណុះធំ ឆ្លងកាត់បាន ការជួបប្រទះនូវបញ្ហានេះ ធ្វើឲបារាំងមានការខកចិត្ត បែរជាវិលតឡប់មកគិតរក ទាញយកប្រយោជន៍ពីធនធានធម្មជាតិខ្មែរ និងរកដីសម្បទាន សំរាប់វិនិយោគិនបារាំងសែសទៅវិញ។

អាណាព្យាបាលបារាំង បានបញ្ឈប់ការបន្តនៃមហិច្ឆតាទឹកដី និងសហវិរិតរាជសៀមយួន មកលើស្រុកខ្មែរបានពិតមែន តែវាពុំអាចស្តាបាននូវអ្វីៗ ដែលខ្មែរយើងបានបាត់បង់រួចទៅហើយ លើកលែងតែខេត្តខ្លះ ដូចជា បាត់ដំបង ពោសាត់ សៀមរាប ស្ទឹងត្រែង ម្លូព្រៃ។ ក្នុងទស្សនៈអាណានិគមបារាំងនៅក្នុងសាកលលោកក្នុងសម័យនោះ គេយកគោលលទ្ធិនៃការរុលចូល(pénétration)មកអន្ទងជនជាតិដែលរស់ក្រោមអាណានិគមរបស់គេ ដើម្បីបង្ហាញសុច្ឆន្ទះនៃការរុលចូលនេះ ដែលមានន័យដូចតទៅះ

**រុលចូល**គឺឈរលើមូលដ្ឋាន**ការដូរ**(échange)គ្នាទៅវិញទៅមក ក្នុងគតិកាតរភាព និងសមភាព រវាងប្រទេសអ្នកអាណានិគម និងប្រទេសអាណានិគម ដើម្បីការចំរើនលូតលាស់នៃមនុស្សជាតិ តួយ៉ាងនៅស្រុកខ្មែរ បារាំងគេនាំចូលនូវវិជ្ជាវិទ្យាសាស្ត្រ សាធារណសុខាភិ

បាល ការអប់រំជាតិទំនើប រដ្ឋបាលទំនើបអភិវឌ្ឍន៍សេដ្ឋកិច្ច ឈរលើការ រកសភាពចម្រើន នៃការរស់នៅរបស់ប្រជាពលរដ្ឋនិងរដ្ឋ ការគាំពារប្រទេសខ្មែរ ពីការឈ្លានពាន ពីសំណាក់បរទេស។ **ជាវិលោម**(inversement)នៅក្នុងការដូរនេះ ស្រុកខ្មែរ បានផ្គត់ផ្គង់តបវិញ ដល់ប្រទេសបារាំងនូវធនធានធម្មជាតិជាច្រើន ដែលជារូបធាតុដើម សំរាប់ឧស្សាហកម្ម ជាដីសម្បទាន សំរាប់**ធ្វើផលិតកសិកម្មដល់មាត្រដ្ឋានឧស្សាហកម្ម**(៨)ជាផ្សារលក់ដូរ ជាពិសេសជាមូលដ្ឋាន សំរាប់ធ្វើការវាតឥទ្ធិពលអាណានិគមបារាំងក្នុងដំបន់។

គោលលទ្ធិនេះ ខុសពីគោលលទ្ធិ**វាតត្បាត** គឺការវាយយកប្រទេសមួយមកដាក់ ជាប្រទេសចំណុះឬបញ្ចូលជា ឧបសម្ព័ន្ធ ដោយប្រើនយោបាយបំបាត់ពូជសាសន៍ រំលាយវប្បធម៌ប្រជាពលរដ្ឋដើម។

តែយើងដឹងថា គោលលទ្ធិទាំងពីរនេះ វាមានធាតុដូចគ្នា ទី១ជាការទាក់ទង រវាងប្រទេសមានអនុភាពនឹងប្រទេសទន់ខ្សោយ ទី២គឺប្រទេសមានអនុភាព គេតែងតែស្វែងរកប្រយោជន៍របស់គេជាមុន ព្រោះគោលការណ៍នៃការស្វែងរកប្រយោជន៍របស់គេនោះហើយ ជាមូលហេតុចម្បងរបស់គេ។

ក្នុងសម័យអាណាព្យាបាលបារាំង ទោះបីអ្នកប្រាជ្ញបារាំងសែស គេបានធ្វើការសិក្សាម៉ត់ចត់អំពីអារ្យធម៌ខ្មែរ នាំឲខ្មែរយើងភ្ញាក់ឡើងវិញថា ជាតិសាសន៍ខ្លួន ធ្លាប់មានវប្បធម៌រុងរឿងប្រជាជាតិខ្លួន ធ្លាប់ជាមហានគរ តែអតីតកាលដោយកិត្តិគុណនេះ វាមានភាពជាការអាក់អន់ចិត្ត(frustration)ក្នុងសតិខ្មែរ ជាងភាពជាការយល់ដឹង(conscience)អំពីកម្លាំងជាតិខ្មែរ ព្រោះប្រជាជាតិខ្មែរ នៅពេលដែលខ្លួនភ្ញាក់រលឹកនោះ រស់ជាប្រជាជាតិខ្ញុំបរទេស(បារាំង) ទោះបី មានប្រាសាទអង្គរវត្ត ជាភស្តុតាងជានាមរូប នៃឥន្ទ្រិយ(grandeur)ជាតិ តែរាស្ត្រខ្មែរស្ទើរតែមួយនគរ រស់នៅក្នុងខ្ទមប្រកស្លឹក ជាប្រជាពលរដ្ឋខ្ញុំបរទេស។ ក្នុងភាពផ្ទុយស្រឡះនេះ ប្រជាជាតិខ្មែរពុំអាចមានមនោគមវិជ្ជាជាតិបាននោះឡើយ ព្រោះប្រជាជាតិខ្មែរ រស់នៅបន្តក្នុងឥទ្ធពលវប្បធម៌បរទេសជានិច្ច មានសៀមយួន និងបារាំង។

សម័យអាណាព្យាបាលបារាំង គ្រាន់តែជាសុបិន្តដ៏ល្អមួយប៉ុណ្ណោះសំរាប់ប្រជាជាតិខ្មែរ ទាំងស្តេចទាំងរាស្ត្រ នាំគ្នាដេកលក់មានសុខ ជិតមួយសតវត្ស ដេកចាំព្រះបាទធម្មិក មកជួយកសាងមហានគរឡើងវិញ ព្រោះបារាំង គេប្រាប់ខ្មែរថា ខ្មែរជាពូជសាងប្រាសាទ ជាពូជមាន

ស្តេចមានសាសនា ជាគ្រឹះ តែពេលនេះ មានបារាំងការពារនូវអ្វីដែលខ្មែរធ្លាប់មាន ហើយជាអ្នកនាំផ្លូវ ឲដើងឡើងវិញ នូវមនោគមវិជ្ជាខ្មែរ គឺវប្បធម៌សម័យថ្មី ដែលបារាំងគេនាំចូលស្រុកខ្មែរ គឺអាណាព្យាបាលបារាំងហ្នឹងឯង ព្រោះគេជាអ្នករំដោះជាតិខ្មែរឲ្យរួចទុក្ខភ័យ។

**សេចក្តីសន្និដ្ឋាន**

នៅទីនេះ យើងមិនលើកយកបណ្តាសម័យបន្ទាប់ពីអាព្យាបាលបារាំងមកធ្វើប្រធានសិក្សាបន្តនោះឡើយ ព្រោះវាជាប្រធានធំមួយ ត្រូវចាំបាច់លើកវា យកមកពិចារណា ដាច់ឡែកសម័យបន្តនោះ ជាសម័យ ប្រយុទ្ធនយោបាយផង និងជាសម័យលុបលើដោយសីហនុនិយមផង ឬសម័យសង្គមនិយម។

ដូចយើងបានជំរាបជូន ជាយោបល់ផ្ទាល់ ដល់ប្រិយមិត្តអ្នកអាន អំពីមនោគមវិជ្ជាជាតិខ្មែរតាំងពីបុរាណកាល មកដល់សម័យអណាព្យាបាលបារាំង បើយើងធ្វើសង្ខបទៅ ឃើញថា នៅក្នុងផ្នត់គំនិតខ្មែរ ជាទូទៅ គឺសាសនា និងព្រះមហាក្សត្រនេះហើយជាមនោគមនវិជ្ជាជាតិខ្មែរ។ ឈរលើមូលគំនិតនះឯង ទើបខ្មែរយើងភាគច្រើន តែងតែមានជំនឿថា ប្រជារាស្ត្រខ្មែរជាអ្នករាជានិយមស្រលាញ់ពុទ្ធសាសនា។

មូលគំនិតនេះ បង្ហាញឲយើញថា ជនជាតិខ្មែរ ជាជនជាតិ មាន**ការគោរព**(culte)ទៅលើវត្ថុដែលមានលក្ខណៈជា”អ្នកការពារ”ឬ”រ័ក្ស”លើសេចក្តីសុខរបស់ជីវិតខ្លួន អ្វីដែលជាទុក្ខ ត្រូវចាំបាច់ មានអ្នកការពារមកជួយរំដោះ ដូចយ៉ាងការរង់ចាំជាអសារ ព្រះបាទធម្មិក។ ក្នុងការគោរពនេះ មានតាំងពីបុរាណកាលមកម្លេះ ជាបុព្វវប្បធម៌ខ្មែរ គឺអ្វីជាធម្មជាតិសុទ្ធតែមានអ្នកការពារ គឺ”អ្នកតា”ដូច្នេះជីវិតមនុស្ស រស់នៅក្នុង **អនិស្សរភាព**(ចំណុះ)ជានិច្ច នៃអ្នកការពារ ដើម្បីឲមានសេចក្តីសុខ។ សម័យក្រោយៗមកទៀត អ្នកការពារគឺព្រះមហាក្សត្យ ដែលមានងារជារ័ក្ស ដូចយ៉ាង ខ្មែរភាគច្រើនជឿថា បើស្រុកអត់ស្តេច ជាតិត្រូវរលាយ។ យើងអាចសួរថា តើសាសនា ដែលជាគូរជីវិតនឹងព្រះមហាក្សត្យ មានសារៈសំខាន់អ្វីដែរ ក្នុងមនោគមវិជ្ជាជាតិខ្មែរ?នៅក្នុងផ្នត់គំនិតខ្មែរ សាសនា និងមហាក្សត្យ ជាអង្គភាពតែមួយឥតអាចបែងចែកបាននោះឡើយ សាសនាជាអ្នកទ្រទង់របបរាជានិយម ឯចំណែក មហាក្សត្យ ជាអ្នកការពារសាសនា។ ការពឹងគ្នាទៅវិញទៅមកនេះ មាននៅក្នុងគោលការណ៍នៃលទ្ធិ

ព្រាហ្មណ៍ ដែលជាសាសនាជាតិខ្មែរក្នុងសម័យអង្គរ គឺគោលការណ៍”វណ្ណវិភាគ”សម្ព័ន្ធនេះរិតតែមានខ្លាំងឡើង នៅពេលដែលព្រះបាទជ័យវរ្ម័នទី២ យកលទ្ធិទេវរាជ ជាគ្រឹះនៃរបបរាជានិយម។

បើទោះបីមកដល់សម័យពុទ្ធសាសនា បានចំរើនថ្កុំថ្កើតនៅស្រុកខ្មែរ មានឧត្តមធម៌ ជាអ្នកដាស់តឿនសត្វលោក តែពុទ្ធសាសនា មិនបាន ឬមិនអាច យកព្រហ្មញ្ញសាសនាជាសត្រូវធម៌នោះឡើយ ព្រោះព្រហ្មញ្ញសាសនាបាន ចាក់ឫសកែវ អស់ច្រើនសតវត្សរួចមកហើយ ក្នុងសតិអ្នកដឹកនាំ ជាពិសេស វាក្លាយជាទំនៀមជាតិ ជាតំណាងនៃសេចក្តីរុងរឿងនៃវណ្ណៈក្សត្រិយ ដែលខ្មែរយើងភាគច្រើន តែងតែទុកជាអ្នកការពារសេចក្តីសុខនៃប្រជារាស្ត្រ ដូចបានជំរាបជូនខាងលើរួចមកហើយ ដូច្នេះពន្លឺនៃពុទ្ធសាសនាក្នុងសតិខ្មែរ គឺកើតចេញមកពីបរមីព្រះមហាក្សត្រ ដូចយ៉ាងគេនិយាយថា បើស្តេចគ្រប់គ្រងនគរតាមទសពិជរាជធម៌ គឺច្បាស់ជាពុទ្ធសាសនាមានការចំរើនក្នុងព្រះនគរ ដែលជាសាសនាទ្រទ្រង់រាជបល្ល័ង្គ ដូចគ្នាដែរនឹងព្រហ្មញ្ញសាសនា បើមានភាពខុសគ្នាបន្តិចបន្តួចនៃតួនាទីនៃការគាំទ្រនេះ គឺថិតនៅលើមធ្យោបាយតែប៉ុណ្ណោះ មួយសំអាងលើអាទិទេព មួយសំអាងលើគោលការណ៍បុណ្យបាប មួយពឹងលើអាទិទេព មួយជឿលើកម្មផលដែលបុគ្គលម្នាក់ៗបានកសាងពីអតីជាតិ។

រួមសេចក្តីមក មនោគមនវិជ្ជាជាតិខ្មែរ គឺ”សាសនា និងមហាក្សត្រ”គឺគំនិតយកគោលការណ៍**រស់ដោយជំនួយ**(៩)ដែលជា ការត្រិះរិះអកម្ម ផ្ទុយពីគំនិត”ខ្លួនទីពឹងខ្លួន”ដែលជាការត្រិះរិះសកម្ម។

១ ល័ក្ខខ័ណ្ឌឥរិយាបថ=មារយាទ សណ្តាប់ធ្នាប់ ឫកពា។

២ របបជីវភាព=Mode de vie។

៣ អំណាចជាទីស្រឡាញ់=Pouvoir charismatique។

៤ បន្ទំខ្លួន=se vanter។

៥ វណ្ណៈវិភាគ=Division sociale។

៦ សង្គមនិម្មាណ=structure sociale។

៧ កម្លាំងពល=Force physique។

៨ ធ្វើផលិតកសិកម្មដល់មាត្រដ្ឋានឧស្សាហកម្ម=Une production de l’agriculture à l’échelle industrielle។

# ២

## រយៈពេលមានគភ៌កូនឯករាជ្យជាតិ
## (១៩៤៦-១៩៥៣)

### អ្វីទៅដែលហៅថាឯករាជ្យជាតិ ?

និយមន័យនៃពាក្យឯករាជ្យគឺ:ជាទូទៅ ពាក្យឯករាជ្យ គឺកំណត់លើអវត្តមាន នៃទំនាក់ទំនង រវាងមូលហេតុនឹងផលប្រតិកម្ម អវត្តិមាននៃការទទួលឥទ្ធិពល និងអវត្តិមាន នៃការទទួលសេចក្តីបង្ខិតបង្ខំ។

ក្រោយសង្គ្រាមលោកលើកទីពីរមក បារាំងគេមានបំណងនឹងបន្ត របបអាណាព្យាបាលគេនៅស្រុកខ្មែរ តែចំណង់នេះ មានឧបសគ្គធំៗជាច្រើន ដូចយ៉ាង និន្នាការ មាននៅក្នុងគតិនៃប្រទេសអានិគម ទាមទារឯករាជ្យ ដែលមានសហរដ្ឋអាមេរិក ជាមហាអំណាចពិភពលោក គាំទ្រតាមផ្លូវចិត្តនូវចលនាគតិនេះផង ការប្រកាសឯករាជ្យជាតិនៅកម្ពុជា នាថ្ងៃទី១២មិនាឆ្នាំ១៩៤៥ ពីសំណាក់ព្រះមហាក្សត្យខ្មែរ ព្រះបាទ *នរោត្តម.សីហនុ* ដែលជាការប្រកាសមួយស្រប តាមច្បាប់ខ្មែរ ដែលវាអាចលុបបាននូវសន្ធិសញ្ញាអាណាព្យាបាលបារាំង។ ពេលនោះលោក *ស៊ឺង-ង៉ុកថាញ់* ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី តែដល់ពេលពួកសម្ព័ន្ធមិត្ត គេចូលមកស្រុកខ្មែរ ហើយឲបារាំង ចាប់លោកបញ្ជូនទៅស្រុកបារាំងភ្លាម(១៥តុលាឆ្នាំ១៩៤៥)ដោយចោទលោកថាចូលដៃជប៉ុន នាំចោទជា កំហិតតាមផ្លូវច្បាប់ ដល់បារាំងអំពីលក្ខន្តិកៈរបស់ប្រទេសខ្មែរក្រោយពីបានប្រកាសឯករាជ្យ។ កំហិត(contrainte)នេះ តម្រូវឲបារាំងចរចារជាថ្មី ជាមួយរាជរដ្ឋាភិបាលខ្មែរ ដើម្បីរកមូលដ្ឋានច្បាប់ថ្មី សំរាប់ធ្វើឲស្របច្បាប់នៃការវិលត្រឡប់ចូលមកស្រុកខ្មែរវិញ ច្បាប់ថ្មីនោះគឺ កិច្ចសន្យាបណ្តោះអាសន្ន(៧មករាឆ្នាំ១៩៤៦)អនុញ្ញាត នូវវត្តមានអាជ្ញាធរបារាំងនៅស្រុកខ្មែរ ក្នុងរយៈពេលអន្តរកាលមួយ តែកិច្ចសន្ទាបណ្តោះអាសន្ននេះ វាមានតម្លៃជាកិតិយុត្ត បញ្ចប់នូវសន្ធិសញ្ញាអាណាព្យាបាលបាំរាំងនៅស្រុកខ្មែរដែរ ក្នុងកិច្ចសន្ទនេះ បានគ្រោងទុកនូវការបោះឆ្នោតជ្រើសរើសសមាជិកសភាបញ្ញត្តច្បាប់ នៅថ្ងៃទី១កញ្ញាឆ្នាំ១៩៤៦ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ។ ពេលនោះ មានគណបក្សនយោបាយជាច្រើន

បានចូលប្រណាំងប្រជែកដណ្ដើមអាសនៈក្នុងសភានោះ ដូចជាៈគណបក្សប្រជាធិបតេយ្យ ដឹកនាំដោយព្រះអង្គម្ចាស់ *ស៊ីសុវត្ថិ.យុត្តិវង្ស*;គណបក្សសេរីភាព ដឹកនាំដោយទ្រង់ន *រោត្តម.នរិន្ទដេត*;គណបក្សខេមរប៉ុន្នការ ដឹកនាំដោយលោក *លន់.នល់*;គណបក្សតំកើងប្រជាជាតិ ដឹកនាំដោយលោក *យ៉ែម.សំបូរ*;គណបក្សចំរើនជាតិ ដឹកនាំដោយលោក *ជា.ជិនកុក*;គណបក្សត្អួសានមានជ័យ ដឹកនាំដោយលោក *ម៉ៅ.ចយ*;គណបក្សរួមជាតិ;គណបក្សប្រជាជន; គណបក្សរូបសំបុកឃ្មុំ ដឹកនាំដោយលោក *ម៉ម.សុទ្ធ*(១);គណបក្សរូបកណ្ដៀវ;គណបក្សរូបកណ្ដាប់ស្រូវ ដឹកនាំដោយលោក *សំ.ញៀន*។

គណបក្សដែលបានឈ្នះគេដាច់ គឺគណបក្សប្រជាធិបតេយ្យ ទទួលបានសម្លេងច្រើនជាងគេនៅក្នុងសភាបញ្ញត្តច្បាប់ បន្ទាប់មក គណបក្សសេរីភាព ដែលជាគណបក្សមានការគាំទ្រពីអាជ្ញាធរអាណាព្យបាលបារាំង។ ភាពមិនដូចគ្នារវាងគណបក្សប្រជាធិបតេយ្យ និងគណបក្សសេរីភាព គឺ គណបក្សទី១ មានគោលបំណង ទាមទារឯករាជ្យជាតិពីបារាំង ឯចំណែក គណបក្សទី២ គេមានគោលបំណង ទុកស្ថានភាពនៃការទាក់ទង ខ្មែរ.បារាំង ឲនៅដដែល ជាបណ្ដោះអាសន្នសិន។ ក្នុងខែកក្កដា ព្រះអង្គម្ចាស់ *ស៊ីសុវត្ថិ.យុត្តិវង្ស* ដែលខ្មែរយើងភាគច្រើនទុកជាបីតារដ្ឋធម្មនុញ្ញ ទ្រង់ប្រឈួនរោគសគត មួយខែក្រោយពីបានប្រកាស ឲប្រើរដ្ឋធម្មនុញ្ញទី១នៃរាជាណាចក្រកម្ពុជា(១៦ឧសភាឆ្នាំ១៩៤៧)ដែលមានរបបនយោបាយដឹកនាំជាតិជារបប រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

បន្ទាប់មក មានការបោះឆ្នោតជាសាកល នៅថ្ងៃទី២១ធ្នូ ក្នុងឆ្នាំដដែល ដើម្បីជ្រើសរើសសមាជិករដ្ឋសភា។ គណបក្សប្រជាធិបតេយ្យបានទទួលអាសនៈច្រើនជាងគេដដែល លោក *អៀវ.កើស*បានត្រូវតំណាងរាស្ត្រ បោះឆ្នោតឲលោកធ្វើជាប្រធានរដ្ឋសភាដំបូងនៃសភាជាតិខ្មែរ។ ក្នុងនីតិកាលទី១នៃសភាជាតិនេះ មានដំណើររអាក់រអួលណាស់ ព្រោះហ្លួងសីហនុ តែងតែធ្វើការបំពានជានិច្ច ចេះតែកែរដ្ឋធម្មនុញ្ញត្រឡប់ត្រឡិន ដើម្បីរកប្រយោជន៍ខ្លួនផ្ទាល់។ មកដល់ថ្ងៃទី១៧កញ្ញាឆ្នាំ១៩៤៩ ហ្លួង *សីហនុ* បានរំលាយរដ្ឋសភានេះទៅ គេសង្កេតឃើញថា គ្មានប្រតិកម្មជាអវិជ្ជមានពីសំណាក់ប្រជារាស្ត្រខ្មែរទេ នៅចំពោះមុខទង្វើហ្លួង *សីហនុ*នេះ ព្រោះខ្មែរម្នាក់ៗភ័យខ្លាចស្លាប់។ ថ្ងៃទី៨វិច្ឆកា រាជាណាចក្រខ្មែរ យល់ព្រមទទួលយកលក្ខន្តិកៈជាប្រទេសឯករាជ្យនៅក្នុងសហភាពបារាំងសែស លក្ខន្តិកៈនេះ ប្រគល់សិទ្ធិ ឲបារាំងបន្ត

គ្រប់គ្រងកិច្ចការ នយោបាយការបរទេស ការពារជាតិ និងយុត្តិធម៌។ ថ្ងៃទី៣មីនាឆ្នាំ ១៩៥១ មានការបោះឆ្នោតជាថ្មីរើសសមាជិកសភាជាតិ គណបក្សប្រជាធិបតេយ្យទទួលជ័យជំនះម្តងទៀត។ លោក*ស៊ឺង.ង៉ុកថាញ់* បានវិលត្រឡប់មកស្រុកវិញ នៅថ្ងៃទី១៣តុលាក្នុងឆ្នាំដដែល។ អ្នកភ្នំពេញច្រើនកុះករមាន ទាំងព្រះសង្ឃ អ្នករាជការ ជនធម្មតា យុវជន នាំគ្នាធ្វើដំណើរ ទៅទទួលលោកនៅព្រលានយន្តហោះ ដូចជាវិរបុរសជាតិ។ ប្រជាប្រិយភាពនេះ ក៏ក្លាយជាគ្រោះថ្នាក់សំរាប់លោកតែម្តង ព្រោះហ្លួងសីហនុ ទ្រង់ទុកវា ជាការគំរាមកំហែកដល់រាជឯកសិទ្ធិរបស់ទ្រង់ដូច្នេះលោកស៊ឺង.ង៉ុកថាញ់ ក៏ក្លាយជាសត្រូវរបស់ហ្លួង*សីហនុ*ផង ជាសត្រូវរបស់របបរាជានិយមផង។

ការផ្ទុយគ្នាស្រឡះ មានលក្ខណៈជាវិវាទ រវាងហ្លួង*សីហនុ* និងលោក*ស៊ឺង.ង៉ុកថាញ់* គឺគំនិតទាមទារឯករាជ្យ វិវាទនេះ តម្រូវ ឲលោក*ស៊ឺង.ង៉ុកថាញ់* រត់ចូលព្រៃ ដើម្បីរក្សាសន្តិសុខរបស់លោកផង និងអាចឲលោកមានលទ្ធភាពបន្តនយោបាយរំដោះជាតិពីអាណាព្យាបាលបារាំងជាបន្ទាន់ផង។ បើលោកមិនរត់ចូលព្រៃនោះទេ វាសនាលោកគឺពិតដូចជាលោកអ៊ីវ.កើសជាពុំខាន ព្រោះជំនាន់នោះ អ្នកណាមានគំនិតខុសពីហ្លួងសីហនុ គឺបារាំងគេទុកជាសត្រូវរបស់គេដែរ ដូច្នេះ ការរត់ចូលព្រៃជាចម្លើយតែមួយគត់សំរាប់អ្នកប្រឆាំងដាច់ខាតនឹងគំនិតហ្លួង*សីហនុ*។

រយៈពេលមានគក៏នោះ ជារយៈពេលមានសារៈសំខាន់ណាស់ក្នុងជីវិតនយោបាយខ្មែរ ព្រោះក្នុងពេលនោះ មានពន្លឺថ្មីមួយ ចាំងចែងឡើងក្នុងពិភពលោក គឺគោលការណ៏នៃ"ប្រជាពលរដ្ឋនិមួយៗមានសិទ្ធិនឹងសំរេចនូវជោគវាសនាខ្លួនដោយខ្លួនឯង"ដែលនាំបើកវិញ្ញាណប្រជាពលរដ្ឋទន់ខ្សោយ ឲស្គាល់នូវសិទ្ធិរបស់ខ្លួនថា វាមានតម្លៃឥតអាចនរណាទិញឬបង្ខំបាននោះឡើយ។ តែនៅពេលជាមួយគ្នានោះដែរ ពិភពលោករស់នៅក្នុងការប្រឈមមុខដាក់គ្នា រវាងសហរដ្ឋអាមេរិកនឹងសហភាពសូវៀត ដែលគេឲឈ្មោះថា"សង្គ្រាមត្រជាក់"គឺជា សង្គ្រាមលោកសេរីនឹងលោកកុម្មុយនិស្ត ដែលតម្រូវឲប្រទេសតូចៗធ្វើការជ្រើសរើសរកបង្អែកនយោបាយខ្លួន។

មួយទៀត គឺជ័យជំនះពួកកុម្មុយនិស្តចិនលើពួកអ្នកជាតិនិយមចិន ដែលជាកំណើតសាធារណរដ្ឋប្រជាមានិតចិននៅថ្ងៃទី១តុលាឆ្នាំ១៩៤៩ នាំបង្កើតជាស្ថានភាពថ្មីមួយនៅ

ឥណ្ឌូចិនបារាំង ព្រោះទ័ពកុម្មុយនិស្តយួន គេចាប់មានបង្អែកដ៏មាំមួយសំរាប់ប្រឆាំងពេញកម្លាំងនឹងកងទ័ពបារាំង។ ឯចំណែកនៅស្រុកខ្មែរវិញ អ្នកចេះដឹងមួយចំនួនតូច ចាប់ផ្តើមដែរធ្វើសកម្មភាពប្រឆាំងនឹងបារាំង គំនិតនេះ វាមានឫសតាំងពីឆ្នាំ១៩៣៦ ដែលពួកគាត់នាំគ្នា បង្កើតកាសែត"នគរវត្ត"ក្នុងគោលបំណងដាស់មនសិកាជាតិខ្មែរឲភ្ញាក់ដឹង ពីតម្លៃជាតិសាសន៍ នឹងប្រជាជាតិខ្មែរ ដែលជាប្រជាជាតិមួយ ធ្លាប់មានអារ្យធម៌ខ្ពង់ខ្ពស់មួយដែរក្នុងពិភពលោក។

ជំនាន់នោះ បញ្ហាប្រឈមមុខ(défi)របស់អ្នកស្នេហាជាតិទាំងនោះ មានបីយ៉ាង ទី១.ទាមទារឯករាជ្យជាតិ ពីបារាំង ទី២.រំដោះកម្ពុជាក្រោម ពីការតាំងទីនៃជាតិសាន៍យួននៅក្នុងទឹកដីខ្មែរ ទី៣.ទប់ទល់ ទុកជាមុន នៃឥទ្ធិពលចលនាកុម្មុយនិស្តយួន នៅឥណ្ឌូចិន។ គួរដឹងដែរថា មនោគមវិជ្ជានៃកាសែត"អង្គរវត្ត"គឺ"សេរីនិយម" និង"ជាតិនិយម"ដែលមានលោក*ស៊ឺង.ង៉ុកថាញ់* ជាតំណាងនៃឧត្តមគតិនេះ ហើយត្រូវបាន ហ្លួង*សីហនុ* ទុកជាសត្រូវរបស់ព្រះអង្គផ្ទាល់ផង និងជាសត្រូវជាតិខ្មែរផង ដូចដែរបានជំរាបខាងលើរួចមកហើយ ដូច្នេះពាក្យ"ខ្មែរសេរី"ត្រូវបានខ្មែរ សីហនុនិយម ធ្វើយុទ្ធនាការ ដោយការប្រមាណ ទុកជាវេរចនសព្ទនឹងពាក្យ "ឆ្កែក្បត់ជាតិ"ឧទាហរណ៍:ពេលដែលលោកសម.សារីគាត់រត់ចូលព្រៃ ហ្លួង*សីហនុ* បង្គាប់ឲបរិវារទ្រង់ គូររូបលោក*សម.សារី* ជាឆ្កែមានក្បាលជាមនុស្ស ហើយតែងបទចម្រៀង ឲយុវជនច្រៀងប្រមាថលោកថា:*សម.សារី ជាឆ្កែក្បត់ជាតិ។* ទង្វើនេះឯងជាការបង្ហាញភាពកោងកាចរបស់ហ្លួង*សីហនុ*។

ក្នុងរយ:ពេលមានគភ៌នោះ បរិយាកាសនយោបាយនៅស្រុកខ្មែរ ជាបរិយាកាសខ្មៅងងឹត ពួកប៉ូលីសសម្ងាត់បារាំងសែស បានប្រើល្បិចបង្កើតចលនា"នាគខ្មៅ"សំរាប់ប្រឆាំងនឹងពួកអ្នកប្រឆាំងនឹងអំណាចអាណានិគមខ្លួន ដូចយ៉ាងការចាប់មាជិកគណបក្សប្រជាធិបតេយ្យ ជាច្រើនដាក់គុក អ្នកខ្លះទៀតត្រូវគេធ្វើទារុណកម្ម អ្នកខ្លះទៀតត្រូវគេបញ្ជូនទៅដាក់គុកសំរាប់ជនឧក្រិដ្ឋនៅមណ្ឌលប៉ូលូកុងដ័រ។ នយោបាយបង្រាបអ្នកប្រឆាំងរបស់បារាំង និង*សីហនុ* កើនកំរិតខ្លាំងឡើងៗជានិច្ច ដូចយ៉ាង នៅថ្ងៃទី១៤មករាឆ្នាំ១៩៥០ មានការធ្វើឃាតដោយបានចោលគ្រាប់បែកដៃ លោក*អៀវ.កើស* អតីតប្រធានរដ្ឋសភា និងជាអគ្គលេខាធិការគណបក្សប្រជាធិបតេយ្យ។ ឃាតកម្មនយោបាយនេះ ធ្វើឲមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅស្រុក

ខ្មែរ ក្នុងមតិមហាជន មានជំនឿថា ឃាតកម្មនេះជាស្នាដៃរបស់ហ្លួង*សីហនុ*តែម្តង ព្រោះទ្រង់ស្អប់ផង និងច្រណែនផង នឹងប្រជាប្រិយភាពនៃគណបក្សប្រជាធិបតេយ្យ តែក្រោយបន្តិចមក ប៉ូលិស បានផ្តល់បត៌មានថា គេចាប់បានឃាតករ ឈ្មោះនូយ៉ា ជាសមាជិកនៃគណបក្សសេរីភាព តែអ្នកភ្នំពេញ នាំគ្នាខ្សឹបខ្សៀវថា រឿងហ្នឹងជារឿងស្លិតភ្នែកសុទ្ធសាត ព្រោះវាគ្មានហេតុផលអ្វីបន្តិចទាល់តែសោះ ដែលនាំឲគណបក្សសេរីភាពធ្វើឃាតលោក *អៀវ.កើស។*
តែទោះបីយ៉ាងណា ក៏គេនៅតែទុកឃាតកម្មនេះជាឃាតកម្មនយោបាយ គឺមានបនរភពពីទំនាស់នយោបាយរបស់ហ្លួងសីហនុ ព្រោះទ្រង់មិនពេញចិត្តនឹងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនេះទេ ហើយក៏មិនយល់ស្របដែរ នឹងគោលនយោបាយ របស់រាជរដ្ឋភិបាលនៃគណបក្សប្រជាធិបតេយ្យ ដែលមានទស្សនៈផ្ទុយពីព្រះអង្គ គឺសេរីនិយម ប្រជាធិបតេយ្យ និងឯករាជ្យនៃកម្ពុជា ជាបន្ទាន់។
ទំនាស់នេះ វាក្លាយជានិមិត្តរូបនៃទំនាស់ រវាងអំណាចសម័យនឹងអំណាចចាស់ គឺថាលទ្ធិប្រជាធិបតេយ្យនឹងរាជាធិបតេយ្យ ទោះបីមានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ថាលទ្ធិដឹកនាំជាតិ ជាលទ្ធិរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ:*ព្រះមហាក្សត្យគ្រងរាជ្យសម្បត្តិ ក៏ប៉ុន្តែព្រះអង្គមិនមែនជាអ្នកដឹកនាំជាតិទេ* ក៏ហ្លួងសីហនុមិនបានយកចិត្តទុកដាក់នឹងគោលការណ៍នេះដែរ ព្រោះវាធ្វើឲ ហ្លួង*សីហនុ* ឈឺចុកចាប់ណាស់។ តែទ្រង់មិនដេកនៅស្ងៀម ទ្រាំលេបទុក្ខនេះឡើយ ពេលនោះ ទ្រង់សង្កេតឃើញមានច្រកមួយ អាចយកមកធ្វើជាឧបាយកល ដើម្បីដណ្តើមរាជអំណាចវិញបាន គឺផ្លូវ”ជាតិនិយម”ដែលកំពុងនៅទំនេរ ព្រោះលោក*ស៊ឺង.ង៉ុកថាញ់* បានរត់ចូលព្រៃបាត់ទៅហើយ។ ដូច្នេះទ្រង់មិនឲឱកាសល្អនេះឆ្លងផុតទេ ដូចយ៉ាង ក្នុងឆ្នាំ១៩៥២ ទ្រង់ចាប់ផ្តើមប្តូរនយោបាយតឹងតែងប្រឆាំងនឹងអ្នកជាតិនិយម ដែលសុទ្ធតែជាអ្នកប្រជាធិបតេយ្យដែរ ការដូរនេះគឺ ទ្រង់ចាប់ផ្តើម ដើរតួជាអ្នកជាតិនិយមជំនួសលោក*ស៊ឺង.ង៉ុកថាញ់* ដោយយកយុទ្ធនាការទាមទារឯករាជ្យជាបន្ទាន់ពីបារាំង ដែលមានឈ្មោះថា”ព្រះរាជបូជនីយ៏កិច្ចសម្រាប់ឯករាជ្យកម្ពុជា”ជាមនោគមវិជ្ជាទ្រង់ផង ជាមធ្យោបាយផង សំរាប់សម្លាប់គូរសត្រូវនយោបាយផង និងជាការសម្របនឹងនិន្នាការនៃប្រជាពលរដ្ឋញខ្មែរ ចង់បានឯករាជ្យជាបន្ទាន់ផង។ ត្រូវកត់សំគាល់ថា នៅថ្ងៃទី១៦មិនា ថ្ងៃផ្តើមព្រះរាជបូជនីយ៏កិច្ចនេះ ទ្រង់បានប្រើកល្បិចទំលាក់រាជរដ្ឋាភិបាលនៃគណបក្សប្រជាធិបតេយ្យ ដែលមានលោកហុយ

កន្ទុល ជានាយករដ្ឋមន្ត្រី ដើម្បីបង្កើតរដ្ឋាភិបាលថ្មី ដឹកនាំដោយព្រះអង្គផ្ទាល់ ក្នុងគោលបំណងដណ្តើមអំណាចរដ្ឋ។ បន្ទាប់មកទៀត ដើម្បីបំបាត់សម្លេងអ្នកប្រជាធិបតេយ្យ ហ្លួងបានរំលាយរដ្ឋសភានៅថ្ងៃទី១៣មករាឆ្នាំ១៩៥៣ ហើយប្រកាសប្រជាជាតិ មានអាសន្ន ក្នុងគោលបំណងដណ្តើមអំណាចនីតិបញ្ញតិថែមទៀត គឺថា អំណាចរដ្ឋទាំងអស់ ដូច្នេះហ្លួង *សីហនុ* ក៏បានក្លាយជាមហាក្សត្រផ្តាច់ការ ដែលវាផ្ទុយស្រឡះនឹងរដ្ឋធម្មនុញ្ញជាតិខ្មែរ។ សួរថា តើល្បិចកល់នេះ គេអាចទុកវា ជារដ្ឋប្រហារបានដែរឬទេ? តើមាននរណាខ្លះនៅពីក្រោយឧបាយសម្ងាត់នេះ?

អាជ្ញាធរអាណាព្យាបាលបារាំង? វរជនខ្មែរ? បញ្ញវន្តជន? ឬជាឆន្ទៈប្រជាពលរដ្ឋ?

យើងដឹងថានៅពេលនោះអ្នកដែលក្តាប់អំណាចនយោបាយស្របច្បាប់ គឺគណបក្សប្រជាធិបេតយ្យះ

តើនៅក្នុងបក្សនេះ មាននិន្នាការនយោបាយតែមួយឬទេ?

តើពាក្យជាតិនិយមជាគោលនៃការរួបរួមជាតិខ្មែរឬទេ?

ដូចយើងបានជំរាបពីខាងលើរួចមកហើយថា តាំងពីដើមដំបូងមកម្លេះ ហ្លួង *សីហនុ* ទ្រង់បានបង្កើតបរិយាកាសនៃជម្លោះនយោបាយរួចស្រេចទៅហើយ គឺជំហរនៃការប្រឆាំងរបស់ទ្រង់នឹងការដាំលទ្ធិប្រជាធិបតេយ្យនៅក្នុងស្រុកខ្មែរ។ ជំហរនេះ វាជារបងការពារបុព្វសិទ្ធិនៃអំណាចមហាក្សត្រផង និងជាការសំដែងឲយើញនូវខ្សែបន្ទាត់នយោបាយផ្ទាល់របស់ព្រះអង្គផង វាក៏ជាគភ៌(fœtus)នៃសីហនុនិយមហ្នឹងឯង។ រូបភាពនៃការពុះជាពីរនេះ(clivage)ក៏ក្លាយជាការពិតក្នុងជីវិតនយោបាយខ្មែរ បំបែកអ្នកជាតិនិយមខ្មែរជាពីរបក្សពួកប្រឆាំងគ្នា ក្រុមទី១ ជាអ្នករាជានិយមដោយគ្មានលក្ខណ ក្រុមទី២ ជាអ្នកប្រជាធិបតេយ្យ។ ក្នុងជួរអ្នកប្រជាធិបតេយ្យនោះទៀត មានជាកូនក្រុមពីរ អ្នកប្រជាធិបតេយ្យសេរី ដែលយើងហៅថាអ្នកស្តាំនិយម និងអ្នកសង្គមនិយម ដែលយើងហៅថាអ្នកឆ្វេងនិយម។ ក្នុងជីវិតនយោបាយប្រេះឆារនេះ ក៏មានពួកអ្នកឱកាសនិយម និងពួកកុម្មុយនិស្ត ដេករង់ចាំឱកាសល្អ ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន ឬក្រុមខ្លួន។ គណបក្សប្រជាធិបតេយ្យក៏មិនអាចជៀសវាងផុត ពីសភាពប្រេះឆារនេះដែរ ទោះបី ខ្លួនមានការគាំទ្រពីសំណាក់ប្រជាជនភាគច្រើនយ៉ាងណាក៏ដោយ តែសភាគភាព(homogénéité)ដែលមានក្នុងគណបក្សប្រជាធិបតេយ្យ ជាស

ភាគភាពនៃសម្លេងអ្នកបោះឆ្នោត មិនមែនជាសភាគភាពនៃកម្លាំងរួមនយោបាយនោះ ឡើយ ដូចយើងបានឃើញស្រាប់ហើយ ក្នុងរយៈពេលតែមួយទសវត្សប៉ុណ្ណោះ(១៩៤៦ ១៩៥៦) បក្សនេះ បានរលាយដោយខ្លួនឯង ដូចអំបិលត្រូវទឹកក្តៅអីចឹង សភាពនេះក៏មិនខុសពីគណ បក្សឯទៀតៗនោះដែរ។

**មូលហេតុ**

មូលហេតុមានច្រើនណាស់ ដែលយើងសាកល្បងយកវាមកពិនិត្យនៅទីនេះ៖

**១.សង្គមខ្មែរ**

ស្នូលនៃសង្គមខ្មែរ គឺគ្រួសារ ជាសង្គមចេកម្លៃទៅលើមាតា(អរិយធម៌ដើមខ្មែរ)ជាសង្គមមាន ការវិវត្តន៍ជាបញ្ឈរ(vertical)ច្រើនជាងការវិវត្តន៍ជាផ្តេក(horizontal)ព្រោះអរិយធម៌ដើមរបស់ ពូជសាសន៍ខ្មែរ មុនបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា មានធាតុជាការគោរពកោតខ្លាចអ្នក មានគុណ(ម្តាយ)ដែលក្រោយមក វាក្លាយទៅជាការគោរព**អ្នកត្រួត**(chef) ដែលខ្មែរយើងមាន ទម្លាប់ហៅវាថា **លោក បង** ឬ **មេ** ហើយអ្វីដែលមានសភាពជា"ផ្តេក"ខ្មែរយើកមិនសូវយកចិត្ត ទុកដាក់នោះឡើយ។ ធាតុបែបនេះ សំរួលនូវការរីកចំរើននៃអំណាច ជាងការលូតលាស់ សាមគ្គីភាពនៅក្នុងសង្គម។ ហេតុនេះឯងបានជាអំណាចផ្តាច់ការ ដុះលូតលាស់ឆាប់ ណាស់ ក្នុងសង្គមខ្មែរ ព្រោះមកពីកង្វាស់សាមគ្គីភាពនៃរាស្ត្រ ជាអវត្តមាននៃនិយតកម្ម ដែល អាចទុកជាអំណាចទប់នឹងអំណាចនៃអ្នកដឹកនាំ។ យើងអាចប្រៀបសង្គមខ្មែរដូចជា ដីមាន ជីជាតិដ៏ល្អ តែដីនេះ គឺសំរាប់តែដាំដើម"សក្តិភូមិ"អាចឲវាមានផលជាបរិបូរណ៍ គឺផ្លែ"អំណាច ផ្តាច់ការ"ជាផ្លែស្លែង មានជាតិពិសពុលដល់ប្រជាជាតិខ្មែរ។

បូកនឹងទំនៀមដើមនេះ វាមានការលុកចូលនៃលទ្ធិព្រាហ្មណ៍មកក្នុងស្រុកខ្មែរ ដែលនាំឲរិតតែ ពង្រឹងអំណាចបញ្ឈរ ដែលជាកម្លាំងជាន់មិន ឲសាមគ្គីភាពនៃរាស្ត្រ ដែលជាកត្តា អាចនាំ បង្កើតអំណាចផ្តេក ដើបរួចបាន ព្រោះលទ្ធិថ្មីនេះ មានបែងចែកសង្គមជាកស្តិ(វណ្ណៈ)។ រីឯ ឥទ្ធិពលពុទ្ធសាសនាវិញ ក៏មិនបានបញ្ច្រាស(inverser)ស្ថានភាពនេះដែរ ព្រោះពុទ្ធសាសនាជា លទ្ធិ ឈរលើការខិតខំប្រឹងប្រែង រកសេចក្តីសុខ ដោយខ្លួនឯងផ្ទាល់ ហើយជាសាសនារស់នៅ ក្នុង សាមគ្គីភាពរវាងរបបរាជានិយម និងខ្លួន មិនអាចអ្នកណាម្នាក់ រញ្ជួយវាបាន។ យើង

លើកមកនិយាយក្នុងចំណុចទី២នេះ មិនមែនសំដៅលើធម៌ព្រះពុទ្ធនោះឡើយ គឺសំដៅលើអង្គការសនានៅក្នុងស្រុកខ្មែរតែប៉ុណ្ណោះ។ បន្តមកទៀត ស្រុកខ្មែរបានរស់ នៅក្រោមការត្រួតត្រារបស់បរទេសអស់រយៈពេលច្រើនសតវត្ស ពីសៀម យួន រហូតមកដល់បារាំង នាំឲខ្មែរយើងគ្មានឪកាសធ្វើការកែទម្រង់សង្គមខ្លួនដោយខ្លួនឯង ឲវាចាកផុតពីទម្លាប់ចាស់មិនល្អ ដែលនាំឲវាដើរទៅមុខមិនរួច មិនតែប៉ុណ្ណោះ ក្រោមការត្រួតត្រាបរទេស ខ្មែរយើងគិតតែពីនាំគ្នាឈ្លោះគ្នា ដើម្បីបំរើប្រយោជន៍បរទេស ដែលជាកត្តា នាំឲគេងាយស្រួលត្រួតស្រុកខ្មែរ ព្រោះជនខ្មែរម្នាក់ៗ មិនសូវមានការយល់ដឹងអំពីប្រយោជន៍រួម ដែលជាកត្តាអាចបង្កើតសាមគ្គីភាព។ បើនិយាយឲខ្លី គឺខ្មែរម្នាក់ៗមានគំនិត ជ្រើសរើសវាសនាខ្លួន សំរាប់តែខ្លួនឯងតែប៉ុណ្ណោះ។

**២.ចិត្តគំនិតខ្មែរ**

ក្នុងវគ្គនេះ លោក*ប៉ុន.ចន្ទម៉ុល* បានធ្វើវិភាគយ៉ាងលំអិតរួចហើយ ដូច្នេះ យើងគ្មានអ្វីបន្ថែមលើការសិក្សារបស់លោកទៀតទេ គ្រាន់តែធ្វើការរំលឹកជាសង្ខេបតែប៉ុណ្ណោះ ដើម្បីជូនដល់អ្នកអាន ដែលមិនទាន់បានអានវណ្ណកម្មដ៍ប្រណិតរបស់មហាបុរសខ្មែរនេះ។ តាមលោកប៉ុន.ចន្ទម៉ុល ចរិតខ្មែរដែលនាំឲជាតិខ្មែរស្លាប់មានច្រើនៈគំនិតមានតែអញ គំនិតលួចយកយោបល់គេ គំនិតខ្លាចនយោបាយ គំនិតសងសឹកសួរពូជ គំនិតផ្តាញ់ផ្តាល គំនិតលោភជ្រៃចពង្រីល គំនិតចង្រៃ។ ល។

យើងមានយោបល់បន្ថែមថា នៅពេលណាខ្មែរយើងនាំគ្នារំលឹកអំពីអរិយធម៌ថ្កុំថ្កើងជាតិខ្មែរធ្លាប់មានក្នុងសម័យបុរាណ គឺយើងកំពុងគិតដោយឥតដឹងខ្លួន ថាអ្វីដែលយើងធ្លាប់មាននោះ វាបាត់អស់ទៅវិញហើយ ម្យ៉ាងទៀត នៅពេលណាខ្មែរយើងនិយាយថា ប្រជាជាតិខ្មែរជាមហានគរ គឺយើងនាំគ្នានិយាយដោយឥតដឹងខ្លួនដែរថា នគរខ្មែរធ្លាប់ជា នគរចក្រពត្តិនិយម ប្រើអំណាចយោធាដើម្បីវាត ឬពង្រីងទឹកដីទៅលើប្រទេសជិតខាងខ្លួន ដូចនគរខ្មែរត្រូវបានសៀមឈ្លានពានទឹកដីពីអតីតកាល ហើយបច្ចុប្បន្ននេះ កំពុងរងគ្រោះនឹងការវាតទឹកដីពីសំណាក់យួនកុម្មុយនិស្តនោះដែរ។ ការរំលឹងនេះ គឺធ្វើឡើងនៅក្នុងអារម្មណ៍ហៅ ជាអវិជ្ជមាន និយាយចោល ដែលចេញមកពីអត្តា(moi) ត្បិតនៅក្នុងចិត្ត(soi)ខ្មែរម្នាក់ៗ យើងដឹងច្បាស់ថា កេរ្តិ៍នៃអតីតកាល វាស្ទើរលែងមានលទ្ធភាពជាសសរទ្រទ្រង់វប្បធម៌ និងសង្គម

ធម៌ខ្មែរបានទៀតទៅហើយ លើកលែងនៅសល់មាន តែភាសា អក្សរ ទំនាមទំលាប់ខ្លះ និង ពុទ្ធសាសនា ហើយបើយើងលើកយកអរិយធម៌ដើម(មូលធម៌ខ្មែរ/មន មុន គ.ស.)របស់ខ្មែរ មករំលឹកវិញ វាមិនអាចជាទំនៀមខ្មែរ សំរាប់យកវាមកធ្វើជាលំអាន(modèle)សំរាប់សង្គម សម័យនោះដែរ ដូចយ៉ាងជឿព្រលឹង អារក្ស អ្នកតា;ទុកស្ត្រីជាធំ;បាចទឹកបញ្ចូលស្រែ;ផ្សាំង សត្វ;កប់ខ្មោចក្រោមថ្មដុល ក្នុងក្រឡ;ភាសាមានអន្តរបទ(infixe)។ ល។

យើងនិយាយនេះ មិនមែនមានន័យថា ខ្មែរយើងត្រូវនាំគ្នាបំភ្លេចចោលអតីតកាលជាតិ រុងរឿងនោះទេ តែអ្វីដែលធ្លាប់មានកើតនោះ ត្រូវរំលឹកឡើងបែបឧបទេស(didactique) ដើម្បីឲមើលឃើញវិជ្ជាខ្មែរ ដែលជាជាវស្នីជាតិ ខេលវាមានលើសលប់ លើអវិជ្ជា លើកម្លាំង បាយ លើគំនិតសងសឹក ដែលសុទ្ធជាកំណប់ទុក្ខជាអាថ៌កំបាំង មានច្រើនអនេក នៅក្នុង សតិខ្មែរយើង។

មួយវិញទៀត នៅក្នុងចរិកមិនល្អខ្មែរ មានបង្កើតវប្បធម៍"ភរកុហក" ជាដំបូងសំរាប់រករស់ បន្តៗក្រោយមក វាក្លាយជាការភូតភរជាសាធារណៈ រហូតទៅជាវប្បធម៌សង្គមខ្មែរបច្ចុប្បន្ន យកការភូតភរនេះ ជារបបជីវភាព(mode de vie)តែម្តង។ របបនេះ វាមានប្រភពចេញពី ទម្លាប់រស់ក្នុង"រស់ដោយជំនួយ"(assistanat)ពីខាងក្រៅ ដែលនាំឲខ្មែរយើងគ្មានការទទួល ខុសត្រូវលើអ្វីដែលខ្លួនបានធ្វើ ព្រោះយល់ឃើញថាខ្លួនជាជនរងគ្រោះជានិច្ច ដូចយ៉ាង កំហុស ខ្លួន គឺអ្នកទីទៃ ជាអ្នកទទួលខុសត្រូវ។

### ៣.ធាតុនៃគណបក្សនយោបាយ

គណបក្សនយោបាយ ដែលកកើតឡើង គ្មានការចែកដាច់ ក្នុងការត្រិះរិះរបស់ខ្លួន នូវអ្វីដែល ជានយោបាយ អ្វីជាមនោគមនវិជ្ជា ដែលជាស្នូលរបស់គណបក្ស។ ហើយភាគច្រើន មិនពិត ប្រាកដជាគណបក្សនយោបាយ វាគ្រាន់តែជាក្រុមនៃមនុស្ស ឬបក្សពួក គ្មានស្ថិរភាព មិន ឋិតថេរ ហើយងាយប្រែទ្រង់ទ្រាយរហ័សណាស់។ ជួនកាលបង្កើតឡើងសំរាប់តែបុគ្គលម្នាក់ សំរាប់អ្នកនោះ ស្វែងរកអ្នកគាំទ្រខ្លួន ជាងកម្មវិធីនយោបាយខ្លួន ជួនកាល កម្មវិធីនោះ វា អត់មានផង។ ពេលនោះ មានតែគណបក្សប្រជាធិបតេយ្យទេ ដែលគេអាចចាត់ទុកបានថា ជាគណបក្សមានការគាំទ្រពីសំណាក់មហាជន(masse)ពិតប្រាកដ ព្រោះខ្លួនបានបង្ហាញ

គោលដៅនយោបាយខ្លួនច្បាស់លាស់ គឺការទាមទារឯករាជ្យឲជាតិជាបន្ទាន់ តែនៅពេលដែល ហ្លួង*សីហនុ*ទ្រង់យកប្រធានបទនេះមកធ្វើជាកម្មវិធីនយោបាយរបស់ទ្រង់ ក៏ស្រាប់តែឃើញ មានសមាជិកជាច្រើន នាំគ្នាបែរទៅគាំទ្របុគ្គល*សីហនុ*វិញអស់ ព្រោះពួករត់ចូលក្រុមផ្សេង (transfuge)ទាំងនោះ គាត់គ្មានមនោគមនវិជ្ជាទេ ហើយក៏មិនមែនជាអ្នកនយោបាយពិត ប្រាកដែរ។ គេសង្កេតឃើញ នៅពេលណា**អ្នកនយោបោក**ណាម្នាក់ គេចង់ដូរអាវនយោបាយ អ្នកនោះ តែងតែលើកហេតុផលថា គេជាវរជនបច្ចេកទេស(élite technique)នៅទីកន្លែងណា ក៏ដោយ ក៏គេអាចបំរើជាតិបានដែរ ពួកបែបនេះ គេហៅថា អ្នកឱកាសនិយម តែជា អកុសលណាស់ នៅក្នុងជីវិតនយោបាយខ្មែរ ពួកហនយ៉ូនេះ វាមានចំនួនច្រើនជាងអ្នក ស្នេហាជាតិ។

**៤.ហ្លួងសីហនុ**

នៅស្រុកខ្មែរជំនាន់នោះ ទ្រឹស្តី"ទេវរាជ"នៅមានឥទ្ធិពលខ្លាំងណាស់ ក្នុងសង្គមខ្មែរ។ ការដូរពី របបរាជានិយមផ្តាច់ការ មករាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ បានដោយឥតបង្ហូរឈាមនោះ និងជ័យជំនះជាសុទ្ធិនៃគណបក្សប្រជាធិបតេយ្យ មិនជាកត្តាគ្រប់គ្រាន់ សំរាប់អាចប្តូរចិត្ត គំនិតខ្មែរ ទំនៀមសង្គម ចរិតអ្នកចេះដឹង និងជីវិតនយោបាយខ្មែរ បាននោះទេ។ ពេលនោះ នៅក្នុងសង្គមខ្មែរ នៅមានជានិច្ច ព្យាកុលភាព រវាងលោកិយ(temporel)និងសាសនចក្រ (spirituel)ដូចយ៉ាង ហ្លួង*សីហនុ*ទ្រង់ជាមហាក្សត្រលោកិយផង ជាបុគ្គលពិសិដ្ឋមានជាតិជា ព្រះផង ការនេះ នាំឲទ្រង់យល់ដឹងភ្លាមអំពីការមានប្រៀប(avantage)របស់ទ្រង់លើអ្នក ជាតិនិយមឯទៀតៗ ដូច្នេះ ទ្រង់ យកវាមកប្រើ ដើម្បីរកអត្ថប្រយោជន៍ គឺអំណាចផ្តាច់ការ ដោយយកជំនឿ ទុកបុគ្គលជាវត្ថុសំរាប់បូជា(culte de personnalité)ជាមធ្យោបាយ ដើម្បី ស្វែងរកប្រជាប្រិយភាពរបស់ទ្រង់ ក្នុងគោលបំណងដណ្តើមយកអំណាចពីប្រជារាស្ត្រតែ ម្តង ដើម្បីតែអំណាចតែប៉ុណ្ណោះ។ ចិត្តគំនិតបែបនេះ វាជាបដិបក្ខមិត(antithèse)នឹងពហុ បក្ស ក្នុងលទ្ធិប្រជាធិបតេយ្យសេរី តែគេដឹងថា រឿងខ្លាចខុសនឹងច្បាប់ វាគ្មានមាននៅក្នុង គុណសម្បត្តិរបស់ហ្លួង*សីហនុ* នោះឡើយ។

មូលហេតុមានច្រើនទៀត ដែលយើងពុំអាចយកមកធ្វើវិភាគនៅទីនេះ តែយើងនឹងលើក

យកវាមកធ្វើនៅថ្ងៃមុខទៀតនៅក្នុងអត្ថបទរបស់យើង។

## សេចក្ដីសន្និដ្ឋាន

រយៈពេលមានគភ៌នេះ វាមានមុខពីរ មួយជាសេចក្ដីសង្ឃឹម មួយទៀត ជាសេចក្ដីអស់សង្ឃឹម សំរាប់ប្រជាពលរដ្ឋខ្មែរ ដែលធ្លាប់រស់ និងកំពុងបន្តរស់ នៅក្រោមអំណាចបរទេស មានសៀម យួន បារាំង អស់ជាងពីរសតវត្សរ៍មកហើយ ស្រាប់តែមានឱកាសជាអំណោយផង អាចឲខ្មែរ ងើបបំរះពីនឹមបរទេសបាន ក៏នាំគ្នាខិតខំដើររកអ្នកដឹកនាំជាតិពិតប្រាកដ ដើម្បីឲគាត់ដឹកនាំចលនារំដោះជាតិពីសភាពខ្ញុំគេ។  នៅពេលនោះ ជាដំបូង សេចក្ដីសង្ឃឹមរបស់ខ្មែរយើង គឺគណបក្សប្រជាធិបតេយ្យ ជាគណបក្ស មានឈ្មោះថ្មី ជាពាក្យ ដែលខ្មែរមិនដែលបានឮ គឺទុករាស្ត្រជាម្ចាស់អំណាច មានគំនិតជាថាមវន្ត អាចប្រស់ព្រលឹងខ្មែរស្នេហាជាតិឲរស់បានវិញ មានសកម្មភាព ស្របនឹងគំនិតបំរើជាតិ ក្នុងគោលការណ៍រកប្រយោជន៍រួម និងគោរពសេរីភាពប្រជាពលរដ្ឋ ដែលជាកម្លាំងសំរាប់យកមកទាមទារឯករាជ្យជាតិពីបារាំង តែជាអកុសល មុខទី១ប្រកបដោយវិរិយៈ(énergie)និងសទ្ធា(confiance)នេះ ត្រូវបានចរិតចង្រៃខ្មែរ ដែលលោក *ប៉ុន.ចន្ទម៉ុល* បង្ហាញប្រាប់ក្នុងវណ្ណកម្មលោក ដែលជាផ្ការផោម វាបានរីកខុសរដូវ នាំក្លិនស្អុយរបស់វា មកធ្វើឲខ្យល់ក្រអូបដូចផ្កាឈូកស ដែលកំពុងរីកក្នុងស្រះទឹកថ្លាខ្យងខ្មែរ ឲរំសាយអស់ក្លិនបុប្ផាក្រអូបទៅវិញអស់ នាំឲរាស្ត្រគ្រលងគ្រលោងយំ លាយនឹងសោច ឥតស្ដើយឡើយ។ បរិយាកាសក្នុងរយៈពេលគភ៌នោះ មានការបួកឡូក ដោយគំនិតស្នេហាជាតិផង និងចរិតចង្រៃខ្មែរផង ហើយ អ្នកដែលឆ្លៀតរកចំណេញបានក្នុងភាពច្របូកច្របល់នោះ គឺហ្លួង *សីហនុ* ទ្រង់ដើរតួជាអ្នកកសាងផង និងជាអ្នកបំផ្លាញផង ក្នុងគោលបំណងតែមួយគត់ គឺអំណាចរបស់ទ្រង់។  រួមសេចក្ដីមក រយៈពេលនេះ មិនមែនមានគភ៌កូនភ្លោះ ឯករាជ្យជាតិ និងលទ្ធិប្រជាធិបតេយ្យទេ គឺមានគភ៌ កូនសីហនុនិយមទៅវិញ។  សីហនុនិយមនេះ ជាពូជស្មៅព្រៃ ដុះពាសពេញក្នុងសួនច្បារលទ្ធិប្រជាធិបតេយ្យ សំរាប់សម្លាប់ផលរបស់ប្រជាជាតិខ្មែរ។

**គន្ថនិទេស**[1]

[១] **ចរិតខ្មែរ** និពន្ធដោយលោក ប៉ុណ-ចន្ទម៉ុល ;
**កំណត់ការចងចាំរបស់អ្នកបំរើមាតុភូមិខ្មែរមួយរូប** និពន្ធដោយលោក សឺន-សាន ;
**អរិយធម៌ខ្មែរ** និពន្ធដោយអ្នកស្រីត្រឹង-ងា។

# ៣

# សម័យឯករាជ្យ

## (១៩៥៣ ១៩៧០)

## រយៈពេលពីឆ្នាំ១៩៥៣ដល់១៩៥៥

### បុព្វយោគ

បារាំងសុខចិត្តប្រគល់ឯករាជ្យទាំងស្រុងឲខ្មែរ ប្រកាសឡើងជាផ្លូវការដោយមហាក្សត្យខ្មែរ នៅថ្ងៃទី៩វិច្ឆិកាឆ្នាំ១៩៥៣។ ចំពោះខ្មែរយើងភាគច្រើន ជោគជ័យជាប្រវត្តិសាស្ត្រនេះ គឺពិតជាស្នាដៃឥតប្រកែកបានរបស់ហ្លួងសីហនុ ដូច្នេះព្រះអង្គមានគុណជាភិយ្យោភាពចំពោះប្រជាជាតិខ្មែរ សមសុក្រិតថ្វាយឋានៈជា"រាជបិតាឯករាជ្យជាតិខ្មែរ"។ ឋានៈជាសារាណីយនេះ គឺសមមូល្យ(équivalent)នឹងបិតារបស់ប្រជារាស្ត្រ ដែលកំពុងរស់នៅក្រោមឆាយារាជបារមីព្រះបាទធម្មិក ជាស្តេចល្បីល្បាញអាចយកជ័យជូនជាតិបាន។

តាមលោកសឺន.សាន នោះបីគណបក្សប្រជាធិបតេយ្យ ទទួលការរងគ្រោះយ៉ាងខ្លាំងពីនយោបាយហ្លួងសីហនុប្រឆាំងនឹងខ្លួនយ៉ាងណាក៏ដោយ ពួកអ្នកដឹកនាំគណបក្ស សំរេចចិត្តក្នុងផលប្រយោជន៍ជាតិ ផ្តួចផ្តើមធ្វើមហាបាតុកម្មប្រជារាស្ត្រ គាំទ្រទាំងស្រុង បេសកកម្មព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យកម្ពុជា របស់ហ្លួងសីហនុ តែលោកបន្ថែមថា:"*ពួកបារាំងសែសចុះខ្សោយដោយសារបរាជ័យនៅឌៀនបៀនភូ ក៏បានសុខចិត្តយល់ព្រមប្រគល់ឯករាជ្យពេញលេញដល់យើងវិញ(១)*"។

តែក្នុងគតិខ្មែរអ្នកសង្គមនិយម ឬអ្នកវឌ្ឍននិយម(ឆ្វេងនិយម) ឋានៈ"បិតាឯករាជ្យខ្មែរ" របស់ហ្លួងសីហនុ គឺជាប្រជាភិថុតិ ប្រយោជន៍បំភាន់គំនិតរាស្ត្រ:"*ប៉ុន្តែព្រះករុណា វាំងនិងជើងវាំង បានឆ្លាតចេះលាក់ពុតអាក្រក់នេះ ដោយបានប្រើប្រជាភិថុតិ(démagogie)ប្រយោជន៍បំភាន់គំនិតរាស្ត្រថា ព្រះករុណានេះហើយ ដែលទ្រង់ប្រោសមេត្តាប្រទានរដ្ឋធម្មនុញ្ញឲមករាស្ត្រខ្មែរ ព្រមទាំងបានតាំងព្រះអង្គឯងជាអ្នកដណ្តើមយកឯករាជ្យផង(២)*"។

ឯចំណែកចលនាខ្មែរសេរីវិញ ដែលមានលោកស៊ឺង.ង៉ុកថាញ់ ជាប្រមុខ យល់ឃើញថា ឯករាជ្យជាតិ ដែលហ្លួងសីហនុយកវាមកធ្វើជាកម្មសិទ្ធិខ្លួន ជាឯករាជ្យសំរាប់តែរំលេចព្រះសង្ហារថ្លៃថ្លានៃវណ្ណៈក្សត្រ និងជាឧបករណ៍នយោបាយ និងយុទ្ធសាស្រ្ត អាណានិគមបារាំងនៅឥណ្ឌូចិនតែប៉ុណ្ណោះ ដូចកាលបារាំងគេលុកចូលមកក្នុងស្រុកខ្មែរក្នុងឆ្នាំ១៨៦៣នោះដែរ។ ឧទាហរណ៍ជាក់ស្តែងគឺ បារាំងគេប្រគល់ទឹកដីខ្មែរកម្ពុជាក្រោមឲទៅយួន ឥតមានបានប្រាប់ម្ចាស់ទឹកដីនោះឡើយ។ បេសកកម្មព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យកម្ពុជា របស់ហ្លួងសីហនុ គឺគ្រាន់តែជាល្បែងល្ខោន(jeu de rôle)មានបារាំង និងសីហនុ ជាតួឯក នាំគ្នាលេងរឿងល្ខោន បំភាន់ចិត្តរាស្រ្តខ្មែរ ក្នុងគោលបំណងសម្លាប់គំនិតអ្នកស្នេហាជាតិ ដែលស្រឡាញ់លទ្ធិប្រជាធិបតេយ្យសេរីពិតប្រាកដ។ ការប្រគល់ទឹកដីខ្មែរកម្ពុជាក្រោមឲទៅយួន ជាពស្តុតាង បង្ហាញការបរាជ័យខ្លាំងណាស់ នៃបេសកកម្មអាណាព្យាបាលបារាំង(១៨៦៣ ១៩៥៣)ក្នុងការការពារបូរណភាពទឹកដីខ្មែរ។

ដូចលោក លោកស្រីមិត្តអ្នកអានបានជ្រាបរួចដែរមកហើយ នូវវិវទកម្មនៃឋានៈ”បិតាឯករាជ្យ”របស់សម្តេចសីហនុនេះ ដូច្នេះខ្ញុំមិនលើកមកបង្ហាញជូនបន្ថែម ជាឧទាហរណ៍នៅទីនេះទៀតទេ ខ្ញុំគ្រាន់តែធ្វើសេចក្តីសន្និដ្ឋានថា រឿងនេះគឺច្បាស់ជាគ្មានភាពជា”ឯកច្ឆន្ទ" ក្នុងគតិខ្មែរជាទូទៅ ខ្មែរម្នាក់ៗ តែងតែមានគំនិតខុសគ្នា ព្រោះវាជារឿងនយោបាយ ដូច្នេះភាពមិនស្របគ្នា គឺជាការធម្មតាទៅវិញទេ តែរឿងសំខាន់ដែលយើងគួរលើកវា មកពិចារណាគឺសម័យឯករាជ្យ តើវា ជារស្មីនៃភាពចម្រើន ដល់ប្រជាជាតិខ្មែរដែរឬទេ ?

## សមាសភាគនៃសង្គមខ្មែរ

ពិនិត្យលើសម័យមួយ តម្រូវឲយើងស្គាល់នូវសមាសភាគនៃសង្គមក្នុងសម័យនោះ។ សមាសភាគនោះ វាមានដូចរៀបរាប់ ជាសង្ខេបខាងក្រោមនេះ៖

### ១.ព្រះរាជវាំង និងព្រះរាជវង្ស

ព្រះរាជវាំងខ្មែរ លែងជាមជ្ឈមណ្ឌលនៃអំណាចដូចសម័យបុរាណនោះឡើយ។ តាំងពីបែកបន្ទាយលង្វែកមក(១៥៩៤) គ្រប់មហាក្សត្យខ្មែរ លែងមានអំណាចដូចស្តេចច័ក្រក្នុងសម័យ

បុរាណទៀតហើយ មិនតែប៉ុណ្ណោះ ថែមទាំងរស់ជាខ្ញុំបរទេស ដូចយ៉ាងក្នុងរាជ្យព្រះបាទអង្គដួង (១៨៤១ ១៨៦០)ក៏ដូចព្រះបាទនរោត្តម(១៨៦០ ១៩០២)នៅអមព្រះរាជាខ្មែរ មានមហាមន្ត្រីសៀម ជាអ្នកសំរេចកិច្ចការរដ្ឋពីលើស្តេចខ្មែរ ហើយនៅពេលដែលមហាមន្ត្រីនោះ ដឹងពីបំណងស្តេចនរោត្តមចង់ចុះហត្ថលេខានៃសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំង មហាមន្ត្រីនោះខឹងណាស់ ដកស្បែកជើងខ្លួន យកទៅវៃក្បាលហ្លួងនរោត្តម ការនេះបញ្ជាក់ឲយើញថាទាសភាព ស្តេចខ្មែរចំពោះស្តេចសៀម គឺថិតនៅក្នុងកំរិតជា”ខ្ញុំនឹងម្ចាស់”។ មកដល់ជំនាន់អាណាព្យាបាលបារាំង ស្តេចខ្មែរ តាំងពីនរោត្តម ស៊ីសុវត្ថិ ស៊ីសុវត្ថិមុនីវង្ស មកដល់ស្តេចនរោត្តមសីហនុ ស្តេចទាំងនោះ មានមុខនាទីជាស្តេចប្រថាប់ត្រាតែប៉ុណ្ណោះ គ្រប់កិច្ចការរដ្ឋទាំងអស់ គឺអាជ្ញាធរអាណាព្យាបាលបារាំង គេជាអ្នកសំរេច។

ម្យ៉ាងមួយវិញទៀត ក្នុងរាជ្យហ្លួងស៊ីហនុ នាំបង្កឲមានជម្លោះជាកំបាំង ដែលធ្លាប់មានពីអតីតលមក រវាងពង្សាលី នរោត្តម នឹងស៊ីសុវត្ថិ ព្រោះតែគ្មានសាមគ្គីវណ្ណៈនៅក្នុងព្រះរាជវង្ស។ ជាពិសេសទៅទៀត នៅក្នុងព្រះរាជវង្ស មានបែងចែកជាច្រើនស្រទាប់នៃជាតិក្សត្រ ដែលនាំឲមានបង្កើតជាវណ្ណៈ ស្តេចធំ ស្តេចតូច ស្តេចអ្នកមាន ស្តេចអ្នកក្រ ស្តេចមានយសស័ក្តក្នុងរាជក្រមការ ស្តេចឥតមានការធ្វើ រស់បែបជាអ្នកកំហែងយក(extorqueur)អ្វីគ្រប់បែបយ៉ាងពីមនុស្សកញ្ចោត(innocent)ទុកជារបរចិញ្ចឹមជីវិត។ រូបភាពក្នុងរាជត្រកូលបែបនេះ នាំធ្វើឲស្អប់កិត្តិនាមវណ្ណៈក្សត្រ ដែលនាំឲរាស្ត្រលែងចង់គោរពកោតបារមី រហូតលួចមើលងាយនៅក្នុងចិត្តថា ពូជស្តេចជាពូជឥតចេះជួយគ្នាផង តើចង់តាំងខ្លួន ជាអង្គម្ចាស់(prince) ជួយដោះទុក្ខរាស្ត្រម្តេចហ្នះបាន។ ម្យ៉ាងមួយវិញទៀត ចរិតសាវ៉ានៃហ្លួងសីហនុនាំបង្កើតអរិភាព(hostilité)ក្នុងរាជវង្ស ដែលមានអង្គម្ចាស់ខ្លះ មានគម្រិះថា ជាគ្រោះមរណៈដល់របបរាជានិយមទៅទៀត។

**២.រាជក្រមការ**

ដូចមាននៅគ្រប់បណ្តាប្រទេសទើបតែបានទទួលឯករាជ្យ នៅស្រុកខ្មែរ រាជក្រមការ ជាវណ្ណៈពិតមួយក្នុងសង្គមខ្មែរ ជាទូទៅ វណ្ណៈនេះ មានភក្តីភាពនឹងរបបរាជានិយម តែភក្តីភាពនេះមានការចុះអន់ថយ នៅពេលដែលលទ្ធិប្រជាធិបតេយ្យចាប់ផ្តើមដុះឡើងក្នុងស្រុកខ្មែរ ព្រោះ

វានាំឲ្យខ្លួនចាប់ចេះដឹងពីតួនាទីរបស់ខ្លួន ជាអ្នកបំរើជាតិ ដែលដើមឡើយខ្លួនយល់ថាជាសិទ្ធិសំរាប់តែត្រួតត្រាប្រជារាស្ត្រ ដើម្បីបំរើមហាក្សត្យ។ តែទោះបីស្មារតីនេះចាប់ផ្តើមមានកំណើតក្នុងគតិរបស់អង្គក្រមការយ៉ាងណាក៏ដោយ តែវាមិនអាចជាកត្តា អាចប្តូរនៃឫសកែវក្នុងចិត្តគំនិតនាម៉ឺនចាស់(mandarin)នោះដែរ ហេតុនេះឯង គេចាប់ផ្តើមសង្កេតឃើញមានអរិភាពរវាងមន្ត្រី(fonctionnaire)មានវ័យក្មេង ដែលបានសិក្សាក្នុងសាលារដ្ឋបាល ដែលអាណាព្យាបាលបារាំងគេបង្កើតឡើងតាំងពីឆ្នាំ១៩០៧ តែមានការកែទម្រង់ជាថ្មីក្នុងកំឡុងឆ្នាំ១៩២០ ដើម្បីបង្រៀនជាថ្មីនូវលំនាំរដ្ឋបាលសម័យ។ តែចិត្តគំនិតថ្មីនេះ បានទង្គិចយ៉ាងខ្លាំងនឹងទម្លាប់ចាស់ មន្ត្រីថ្មីខ្លះ ដែលមានមនសិការជាតិខ្ពង់ខ្ពស់ មិនព្រមចាញ់ ហើយតាំងចិត្តយកវិធី និងចិត្តគំនិតសម័យ មកអនុវត្តន៏ មិនគិតក្លាចខូចអត្ថប្រយោជន៏ ឯចំណែកមន្ត្រីខ្លះទៀត ទន់ទោរតាមទម្ងន់ទម្លាប់ចាស់ ព្រោះជ្រួលច្រាស់រកប្រយោជន៏ផ្ទាល់ខ្លួន។ តែទោះបីយ៉ាងណា ទម្លាប់ចាស់នៅមានប្រៀបលើគតិ(esprit)ថ្មីជានិច្ច ព្រោះ៩០ឆ្នាំក្រោមអាណានិគមបារាំងម្ចាស់អំណាចនេះ គេមិនបានយកចិត្តទុកដាក់លើកំណែទំរង់ចិត្តគំនិតប្រជារាស្ត្រខ្មែរនោះឡើយ ព្រោះគេខ្លាចប្រជាពលរដ្ឋមានគំនិតថ្មី ក្លាយជាសត្រូវនឹងគណៈចាស់ គឺវាជានិយមនេះឯង ដែលបារាំង គេមានតួនាទីដាច់មុខជាអ្នកការពារសុវត្ថភាព។

### ៣.បញ្ញវន

បញ្ញវននៅទីនេះ គឺយើងមិនយកនិយមន័យ បែបប្រទេសបស្ចិមមកប្រដូចនោះទេ ព្រោះក្នុងទស្សនៈ(concept)ខ្មែរ ពាក្យបញ្ញវននេះ វាមានន័យវិតត្បិតណាស់។ តាមគំនិតខ្មែរជាទូទៅ បញ្ញវន គេសំដៅតែអ្នកមានសញ្ញាប័ត្រថ្នាក់ឧត្តមសិក្សាតែប៉ុណ្ណោះ ដែលភាគច្រើនជាអ្នកបច្ចេកទេស។ តែយើងដឹងថា នៅដើមសម័យឯករាជ្យ អ្នកមានសញ្ញាប័ត្រថ្នាក់ឧត្តមសិក្សាមានតិចតួចបំផុត ស្ទើតែមិនលើសពីចំនួនម្រាមដៃទាំងពីរផង ព្រោះនៅស្រុកខ្មែរគ្មានមហាវិទ្យាល័យទេ អ្នកមានសញ្ញាប័ត្រសាកលវិទ្យាល័យបីបួនគ្រាប់នោះ គឺបានមកពីបរទេស ជាពិសេសពីបារាំងហ្នឹងឯង។ ខ្មែរដែលបានរៀនសូត្រនៅក្នុងប្រទេស នាំគ្នាទុកខ្លួនឯងត្រឹមតែជាអ្នកចេះដឹងតូចតែប៉ុណ្ណោះ ព្រោះខ្លួនខ្លាចអ្នកផងសើច បើនិយាយថាខ្លួនជាអ្នកចេះដែរ នាំគ្នាទុកបារាំង សៀម យួន គេជាអ្នកប្រសើរជាងខ្លួនជានិច្ច បើខ្មែរណាបានទៅរៀននៅ

ស្រុកសៀម យួន គឺសុទ្ធជាអ្នកគ្រាន់បើជាងខ្មែរអាយ ហើយបើមានសញ្ញាប័ត្របារាំង គឺខ្មែរយើងនាំគ្នាអច្ឆារីទចំពោះបុគ្គលនោះ ព្រោះគេជាជាអច្ឆរិយជន។ ហិនមានៈ កើតមកពីភាវ ជាជនខ្ញុំបរទេសជាច្រើនសតវត្ស លុះគ្រាតែភ្លេចអស់នូវតម្លៃជាតិសាសន៍ខ្លួន ជាពិសេសលែងដឹងថាខ្លួនជាអ្វីទៅទៀត ហើយអ្វីដែលជាការខំប្រឹងប្រែងលើកតម្លៃជាតិ ជាពិសេស អ្នកចេះដឹងខ្មែរគឺគាត់យល់ថា ជាកិច្ចការមួយពិបាកក្រៃលែង មិនតែប៉ុណ្ណោះ នាំគ្នាទុកការចេះដឹងវិជ្ជាជាតិជាការខ្មាសអៀនថែមទៅទៀត។ ក្នុងសម័យនោះ រហូតមកដល់បច្ចុប្បន្នកាល បើខ្លួនតាំងខ្លួនឯងដោយខ្លួនឯង ជាបញ្ញវន្តរួចហើយ អ្នកទាំងនោះ គេឈប់ចង់សរសេរជាភាសាជាតិ ព្រោះខ្លាចគេថាខ្លួនមិនមែនជាបញ្ញវន(៣)ហើយមិនចេះសរសេរបារាំង។ ការដាក់កំហុសលើបច្ចេកទេស វាហួសសម័យទៅហើយ ព្រោះបច្ចុប្បន្ននេះ ការសរសេរជាភាសាខ្មែរក្នុងកំព្យូទ័រ វាលែងជាការពិបាកជាពិស្តារទៀតហើយ ការពិបាកដែលនៅមានសល់ គឺប្រហែលជានៅត្រង់ការដូរចិត្តគំនិតខ្មែរតែប៉ុណ្ណោះ។ ដូច្នេះ កុំនាំគ្នាជេរយួន ថាវាចេះនិយាយ និងសរសេរអក្សរខ្មែរ។ យើងនិយាយនេះមិនសំដៅដល់កូនខ្មែរ ដែលមិនបានចេះភាសាម៉ែឪខ្លួននោះឡើយហើយក៏មិនថា ត្រូវតែសរសរភាសាជាតិឲបរទេសអាននោះដែរ នៅពេលណា តម្រូវឲសរសេរភាសាបរទេស ជាការចាំបាច់ ក៏សរសេរវាទៅ តែគួរខំបកប្រែជានិច្ចជាភាសាជាតិ ឲខ្មែរដឹងផង បើការសរសេរនោះមានសារៈសំខាន់សំរាប់ជាតិខ្មែរ។ តែទោះបីយ៉ាងណា ខ្មែរនៅបរទេស ទាំងក្មេងចាស់ បើគិតពីជាតិពិត គួរនាំគ្នាឲតម្លៃអក្សរជាតិ ខំរៀនឲចេះ ខំសរសេរឲបានច្រើន ដើម្បីរក្សាអត្តសញ្ញាណខ្មែរ បើមិនដូច្នេះទេ គឺច្បាស់ជាយួនដែលបានមករស់នៅស្រុកខ្មែរ គេថាគេចេះខ្មែរច្រើនជាងកូនខ្មែរកើតនៅបរទេសទៅទៀត ហើយវានាំគ្នាសួរថា តើនរណាជាខ្មែរពិត?

បន្ទាប់ពីបានទទួលឯករាជ្យ មានការប្តូរបន្តិចក្នុងទស្សនៈខ្មែរស្តីអំពីលក្ខន្ទិកៈបញ្ញវន គឺការទុកអង្គគ្រូបង្រៀនថ្នាក់មធ្យម និងថ្នាក់បឋមជាបញ្ញវន តែទោះបីមានការទទួលស្គាល់លក្ខន្ទិកៈនេះយ៉ាងណាក៏ដោយ ក៏នៅតែមានការប្រមាថ ដោយយកពាក្យរញ្ជួតូចមកដាក់បន្ថែមថាជា"បញ្ញវនតូចតាច"។ សួរថាតូចតាច ប្រៀបធៀបទៅនឹងនរណា បើយើងដឹងថា៨០%នៃប្រជាជនខ្មែរជំនាន់នោះ សុទ្ធជាជនមិនចេះអក្សរផង។

ទីនេះ យើងមិនលើកមកនិយាយ ពីអ្នកសិល្បករ អ្នកចម្រៀងល្បីៗ វិចិត្រករ អ្នកនិពន្ធសៀវ

ភៅប្រលោមលោក អ្នកសរសេរកាសែត ដែលក្នុងប្រទេសបស្ចិមគេចាត់ទុកជាបញ្ញវ័ន ព្រោះសុទ្ធតែជាបិកា(អ្នកបង្កើតអ្វីមួយ)គំនិត បិកាមនោសញ្ចេតនា បិការូបភាពប្រកបទៅដោយសោភ័ណភាព និងអ្វីៗឯទៀត នៅក្នុងវិស័យសិល្បៈ តែនៅក្នុងស្រុកខ្មែរយើងវិញ អ្នកទាំងនោះខ្មែរយើងភាគច្រើន ទុកគ្នាជាជនគ្មានតម្លៃសំរាប់សង្គម ព្រោះមានមុខរបររកស៊ីត្រឹមតែជាអ្នកបំពេ មនោសញ្ចេតនាជាឪកាស(occasionnel)សំរាប់អ្នកដទៃតែប៉ុណ្ណោះ។

តែទោះបីមានសញ្ញាប័ត្រធំប៉ុណ្ណាក៏ដោយ នៅក្នុងរបបរាជានិយម ឬសីហនុនិយម បើអ្នកចេះទាំងនោះ មិនចូលខ្លួនមកបំរើ គ្មានលក្ខខ័ណ្ឌ មហាក្សត្រ ហើយគ្មានងារជាឧត្តមមន្ត្រី សេនាបតីទៃ អ្នកនោះ ត្រូវគេទុកជាជនចោលម្សៀត។ លុះចំណេរមក នៅក្នុងគតិអ្នកឆ្វេងនិយម គេចាត់ទុកជនណាជាបញ្ញវ័នពិត គឺអ្នកចេះហើយ ជាអ្នកស្អាតស្អំថែមទៀត និងអ្នកប្រឆាំងសីហនុតែម្តង។

**៤.ពិភពអ្នកស្រែ**

ពិភពនេះ មានចំនួនប្រមាណ៨០%នៃចំនួនប្រជាជន(population)ខ្មែរ ដែលអ្នកក្រុងតែងវិនិច្ឆ័យទុកជាមុន(préjuger)ថាជាអ្នកល្ងង់ខ្លៅ ឥតស្គាល់សុជីវធម៌។ តែយើងដឹងថា សម្មានការ(considération)ចំពោះអ្នកស្រែ វាផ្លាស់ប្តូរទៅតាមការរកប្រយោជន៍ពីពិភពនេះ។

**ទី១** គេយល់ថា អ្នកស្រែ គឺសុទ្ធជាអ្នករាជានិយមពិតប្រាកដ ចាត់ទុកព្រះមហាក្សត្រជាសារះជន (être essence) ឬជាអាទិទេពតែម្តង ដែលជាអ្នកថែរក្សា ការពារប្រជាពលរដ្ឋ ប្រឆាំងនឹងការរំលោភពីសំណាក់នាម៉ឺនស៊ីសំណូក។ ចិត្តគំនិតនេះ មិនសូវមានវិវឌ្ឍន៍ទេតាំងពីបុរាណកាលមក ហើយជំនឿនេះកាន់តែរិកខ្លាំងៗឡើងក្នុងរយៈ១៥ឆ្នាំដែលសម្តេចសីហនុ ទ្រង់កាន់អំណាច ត្បិតទ្រង់ ខំប្រឹងថែទាំបដិក្ខេប(réflexe)របស់រាស្ត្រនេះ ដើម្បីប្រយោជន៍អំណាចរបស់ព្រះអង្គ។

**ទី២** គេយល់ថា អ្នកស្រែនឹងក្លាយ ក្នុងរយៈពេលដ៏ឆាប់មួយ ទៅជាកម្លាំងបដិវត្តន៍ ព្រោះសង្គមខ្មែរនៅតែមានសភាពជាសង្គមសក្តិភូមិជានិច្ច ថ្វីបើអ្នកសុ រ៉េជាពុទ្ធបរិស័ទក៏ដោយ។ បដិវត្តន៍នេះ នឹងមិនអាចវៀរបាន ព្រោះអយុត្តិធម៌ក្នុងសង្គម វាមានកំរិតមួយដែលមិនអាចឲអ្នកស្រែទ្រាំបាន ដូចយ៉ាងការជិះជាន់រកប្រយោជន៍ពីសំណាក់នាម៉ឺនស៊ីសំណូក មន្ត្រី

ពុករលួយគ្រប់ថ្នាក់ និងនយោបាយប្រជាភិថុតិរបស់សម្តេចសីហនុតែម្តង។

**ទី៣** គេយល់ថា អ្នកស្រែ តាមធម្មជាតិគាត់ជាពុទ្ធបរិស័ទ ជាអ្នកប្រឆាំងនឹងកុម្មុយនិស្តដាច់ខាត ព្រោះលទ្ធិនេះ វាប្រឆាំងនឹងសសានា ដូច្នេះពុទ្ធសាសនាជាថ្នាំបន្សាបស័ក្តិសិទ្ធិនឹងអតិសុខុមប្រាណ លទ្ធិកុម្មុយនិស្ត មិនអាច ឲវារុលចូលមកក្នុងសង្គមខ្មែរបាន។

## ៥.ពិភពអ្នកជំនួញ

ស្ទើរតែ១០០% អ្នកជំនួញ គឺជនជាតិចិន ឬខ្មែរមានកំណើតជាចិន។ ក្នុងសម័យអាណាព្យាបាលបារាំង អ្នកជំនួញចិន មានអំណាចលើខ្មែរណាស់ ហើយពួកគេមិននៅក្រោមច្បាប់ខ្មែរនោះទៀត ព្រោះអាជ្ញាធរអាណាព្យាបាលបារាំង គេអនុញ្ញាតឲជនជាតិចិនមានលក្ខន្តិកៈពិសេសនៅក្នុងស្រុកខ្មែរ។ គួរកត់សំគាល់ថា ពួកអ្នកជំនួញចិននៅកម្ពុជាក្រោមនេះហើយ ដែលរួមជាមួយយួន ដើម្បីឲយួនមានលទ្ធភាពយកទឹកដីខ្មែរកម្ពុជាក្រោមបានដោយស្រួល(៤)។ សេដ្ឋកិច្ចខ្មែរថិតនៅក្នុងកណ្តាប់ដៃទាំងស្រុកពួកអ្នកជំនួញចិន គេអាចធ្វើព្យុះភ្លៀងបាន មានសិទ្ធិលើសខ្មែរម្ចាស់ស្រុកទៅទៀត ព្រោះពួកគេមានបារាំងជាអ្នកការពារ ដូចយ៉ាងថៅកែតាន់.ប៉ា គាត់មានអំណាចណាស់ រហូតដល់ព្លួងសីហនុចង់តែងតាំងគាត់ជានាយករដ្ឋមន្ត្រីទៅទៀត។ ការសំគាល់មួយ គឺគុណសម្បត្តិជនចិន ជាអ្នកធ្វើការស៊ូទ្រាំនឹងការលំបាកគ្រប់បែប ដូចយ៉ាងជនជាតិចិនដែលបានមករស់នៅក្នុងស្រុកខ្មែរ ប្រកបរបរ"អេតចាយ" ដើរត្រុកៗពីផ្ទះមួយទៅផ្ទះមួយរកទិញរបស់ដែរគេបោះចោលយកទៅសំអាតលក់វិញ រហូតមានលុយក្លាយជាថៅកែ គុណសម្បត្តិមួយទៀត គឺការឧបត្ថម្ភគ្នា បង្កើតជាសមាគមជួយការពារគ្នាយ៉ាងម៉ត់ចត់ណាស់។ នៅស្រុកស្រែចំការ ទោះបីអ្នកស្រែ នាំគ្នាស្អប់ចិន តែភាគច្រើន សុទ្ធជាកូនបំណុល"អាចឹកអាហៀ"។

## ៦.សហធម្មិក(clergé)ពុទ្ធសាសនា

អង្គការពុទ្ធសាសនានៅស្រុកខ្មែរ ថិតនៅក្រោមអំណាចមហាក្សត្រ ព្រះអង្គជាអ្នកតែងតាំងសម្តេចសង្ឃរាជនៃធម្មយុត្តិកនិកាយ និងមហានិកាយ។ បុព្វសិទ្ធិនេះ បង្ហាញឲឃើញនូវហិនភាពរបស់សាសនា នៅក្នុងប្រព័ន្ធនៃរាជអំណាច ទោះបីបាវចនារដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ទុក

សាសនាស្មើនឹងព្រះមហាក្សត្រក៏ដោយ។ បដិវាទកម្មនេះ គឺជាហេតុផល(conséquence)នៃការលាយគ្នារវាងព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ក្នុងវប្បធម៌នយោបាយខ្មែរ។ ទុកណា ពុទ្ធសាសនាមានប្រៀបខ្លាំងក្លាលើព្រហ្មញ្ញសាសនា ចាប់ពីសតវត្សទី១៣មក គ្រប់មហាក្សត្រខ្មែរទ្រង់នៅតែរក្សា របៀបដឹកនាំបែបព្រហ្មញ្ញសាសនាជានិច្ច គឺការទុកព្រះមហាក្សត្រជាប្រជាបតិ(ម្ចាស់នៃសត្វលោក) ប្រកបទៅដោយសច្ចធម៌។ គតិនេះ ជាការកែប្រែនៃអត្ថរស (fond) តែនៅរក្សាទម្រង់(forme)នៃអង្គការដឹកនាំជាតិៈគឺថា យកលទ្ធិពុទ្ធសាសនាមកធ្វើជាយោងនៃសីលធម៌សំរាប់អ្នកដឹងនាំ តែរាជបារមី នៅមានសារពើឋានឬមាននៅសព្វកន្លែង (omniprésence)ជានិច្ច;នុះ(ainsi)ព្រះមហាក្សត្រ ទ្រង់ឈប់ជាអវតា(incarnation)នៃអទិទេព តែទ្រង់ប្រែក្លាយដោយខ្លួនឯង ទៅជាអវតានៃពុទ្ធវចនៈ។ ពុទ្ធសាសនានៅស្រុកខ្មែរ គេទុកជាច្បាប់សីលធម៌ (système éthique) ជាជំនឿហេតុផល តែដោយមហាជន(masse)មានទន្លាប់ជឿលើជំនឿឥតហេតុផល យកការបន់ស្រន់អង្វរករ ព្រះ អ្នកតា អារក្ស ឲជួយស្រោចស្រង់ខ្លួនពីទុក្ខភ័យគ្រប់ប្រការ ឲបានត្រូវឆ្នោត ឬឲឈ្នះល្បែងប៉ោលែគ្រប់មុខ ហើយជាពិសេស មានព្រះសង្ឃខ្លះ ឆ្លៀតរកប្រយោជន៏ ក្នុងទម្លាប់អាក្រក់នេះ តាំងខ្លួនធ្វើជាគ្រូវពិធី ឬគ្រូទាយ ដើម្បីលុយកាក់ជាសគុណ នាំឲបេះពាល់ដល់កិត្តិយសពុទ្ធសាសនាក្រៃលែង។ តែជំនឿឥតហេតុនេះត្រូវបានព្រះសម្ពុទ្ធមានឪវាតថា ជា*ការប្រព្រឹត្តឥតប្រយោជន៏ ជាការបន្ទាបបន្ទោកខ្លួនប៉ុណ្ណោះ*។

រួមសេចក្តីមក ព្រះពុទ្ធសាសនានៅស្រុកខ្មែរ ជាលទ្ធិមួយល្អណាស់សំរាប់មនុស្សលោក តាមព្រះវិរិយបណ្ឌិតគោប៉ាង.ខាត់ គឺៈ*ធម៌ប្រាកដនិយម មានលក្ខណៈជាវិទ្យាសាស្ត្រ បើបុគ្គលណាបានសិក្សាធម៌ទាំងនេះហើយ នឹងបានយល់ច្បាស់ ឃើញច្បាស់ មើលអ្វី មើលឃើញពិតដោយពិតដោយយថាភូតទស្សនញ្ញាណ(objectivisme)ជាធម៌ដែលអ្នកប្រាជ្ញបច្ចុប្បន្នកាលនេះទទួលស្គាល់ថាត្រឹមត្រូវ ហើយគេកោតស្ងើចក្រៃលែង។* ជាធម៌យកគោលការណ៍"ខ្លួនទីពឹងខ្លួន"ជាមាគ៌ារកការចាកទុក្ខទាំងពួងនុះឯង។

ចំពោះយើង យើងក៏មានគំនិតដូចព្រះអង្គប៉ាង.ខាត់ដែរ តែបញ្ហាពុទ្ធសាសនានៅស្រុកខ្មែរ គឺមិនថិតនៅលើពុទ្ធធម៌នោះទេ គឺនៅលើអង្គការ ដែលវាមានរូបភាពជាអង្គការនៅក្រោមអំណាចអ្នកដឹកនាំ រហូតក្លាយជាសាសនាបំរើអំណាច និងនៅលើ ការអនុវត្តន៍មិនត្រឹមត្រូវ

នៃសាធុជនជាច្រើន ទុកធម៌ព្រះពុទ្ធជា ឧបករណ៍សំរាប់ស្វែងរក ផលជាសម្ភារៈច្រើនជាង ស្វែងរកបរមមគ្គសច្ច(vérité spirituel)គឺសច្ចធម៌នេះឯង;នុះពុទ្ធសាសនា ថិតនៅនិច្ចជា ប្រធានបទនៃការជជែកពិភិក្សាគ្នារវាងខ្មែរពុទ្ធសាសនិកជន(pratiquant)និងខ្មែរស្រឡាញ់ គោរពពុទ្ធធម៌(non pratiquant) ដែលគ្រាន់តែយកធម៌នេះមកធ្វើជាសីលធម៌សំរាប់ការរស់ នៅជាប្រក្រតីរបស់ខ្លួន។

## សម័យឯករាជ្យ
## រយៈពេលពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៥៥

ថ្ងៃទី៩វិច្ឆការឆ្នាំ១៩៥៣ សន្មតទុកជាថ្ងៃឯករាជ្យជាតិខ្មែរ។  ទើបតែបានឯករាជ្យភ្លាម ក្នុង ថ្ងៃទី១២មេសា ពួកយៀកមិុញ(យួនកុម្មុយនិស្ត)បានវាយប្រហារផ្លូវរថភ្លើងភ្នំពេញ.បាត់ដំបង នាំឲខ្មែរយើងមានប្រតិកម្មរហ័សភ្លាម គឺបើកប្រតិបត្តការសឹកនៃកងខេមរៈភូមិន្ទប្រយុទ្ធ នឹងពួកយៀកមិុញក្នុងរយៈពេលពីខែ(ឧសភាដល់កក្កដា)ដើម្បីដេញពួកវាឲចេញពីស្រុកខ្មែរ។ ប្រតិបត្តការសឹកនេះ ត្រូវបានបញ្ចាប់សព្វគ្រប់ នៅថ្ងៃទី២០កក្កដាឆ្នាំ១៩៥៤ ដែលជាថ្ងៃចុះ ហត្ថលេខានៅទីក្រុងស៊ីណែវ (Genève)ស្តីអំពីកិច្ចព្រមព្រៀង បញ្ចប់វិវាទសឹក នៅឥណ្ឌូចិន រវាងយួនកុម្មុយនិស្ត និងបារាំង។  កិច្ចព្រមព្រៀងនេះ តម្រូវឲពួកយៀកមិុញ និងបារាំង ដក ទ័ពរៀងខ្លួន ចេញពីស្រុកខ្មែរ ក្រោមការត្រួតពិនិត្យជាក់លាក់ជាអចិន្ត្រៃយ នៅក្នុងផ្ទៃដីស្រុក ខ្មែរ នៃអង្គការសហប្រជាជាតិ។

ជោគជ័យថ្មីរបស់ប្រជាជាតិខ្មែរនេះ ក៏ជាឪកាសថ្មីល្អមួយទៀត សំរាប់ហ្លួងសីហនុ យកវាមក ពង្រឹងពង្រីក អំណាចផ្ទាល់ខ្លួនរបស់ទ្រង់ ក្នុងឋានៈអធិអធមជាព្រះបិតាឯករាជ្យជាតិខ្មែរ និងជាព្រះបិតាជាសរណៈរបស់កូនចៅខ្មែរ(រាស្ត្រ)។  គួររំលឹមកពិនិត្យឡើងវិញក្នុងរយៈពេល បេសកកម្ម"ព្រះរាជបូជនីយ៍កិច្ចសម្រាប់ឯករាជ្យកម្ពុជា"របស់ហ្លួងសីហនុ ពេលដែលទ្រង់ យាងចេញទៅបំពេញបេសកកម្មនៅបរទេស នៅថ្ងៃទី៩កុម្ភៈឆ្នាំ១៩៥៣ ព្រះអង្គបានប្រគល់ តំណែងរបស់ទ្រង់ជានាយករដ្ឋមន្ត្រីឲទៅលោកប៉ែ.នុត និងតាំងព្រះបិតាទ្រង់ នរោត្តម. សុរាម្រិត ជារាជានុសិទ្ធិ តែនៅអមព្រះអង្គនៅក្រៅប្រទេស ទ្រង់បង្កើតរាជរដ្ឋាភិបាលមួយ ទៀត ដឹកនាំដោយលោកចាន់.ណាក់ ដូច្នេះ នៅក្នុងរយៈនោះ ស្រុកខ្មែរមានរដ្ឋាភិបាលពីរ

មួយជាផ្លូវការនៅក្នុងប្រទេស មួយទៀតក្រៅផ្លូវការ នៅក្រៅប្រទេស;ការនេះជាទម្លាប់អាក្រក់របស់ហ្លួងសីហនុ គឺប្រើយុទ្ធសាស្ត្រ"បំបែកដើម្បីងាយស្រួលត្រួតត្រា"។ គួរកត់សំគាល់ថាបេសកកម្ម ព្រះរាជបូជនីយ៍កិច្ចសម្រាប់ឯករាជ្យកម្ពុជានេះ ហ្លួងសីហនុមិនបានទទួលដំណាងអំណាចពីរដ្ឋសភានោះទេ វាជាបេសកកម្មដោយទំនើងចិត្តព្រះអង្គ ហើយរាជរដ្ឋភិបាល ប៉ែន នុតក្តី ចាន់ ណាក់ក្តី ក៏ជារដ្ឋាភិបាលឥតស្របរដ្ឋធម្មញ្ញនោះដែរ។

ដូច្នេះ ក្រោយពីបារាំងបានប្រគល់ឯករាជ្យឲស្រុកខ្មែរ បញ្ហានយោបាយផ្ទៃក្នុង នៅក្តៅគគុកនោះបីមានបង្កើតរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ នៅថ្ងៃទី២២វិច្ឆិកាឆ្នាំ១៩៥៣ ដឹកនាំដោយលោកចាន់.ណាក់ ដែលមានអាយុចាស់ជរាណាស់ហើយ ហើយជាមនុស្សរាជវាំង មានការស្មោះគ្មានខ្ចោះនឹងព្រះមហាក្សត្យ ដែលនាំឲអ្នកជាតិនិយមគ្មានសេចក្តីទុកចិត្តបន្តិចនោះឡើយលើគំនិតរួបរួមជាតិនេះ។

ក្នុងរដ្ឋាបាលនេះ មានការចូលរួមពីសមាជិគណបក្សប្រជាធិបតេយ្យម្នាក់ គឺលោកហាក់.ម៉ុងហេង ដែលគេទុកលោកជាអ្នកឆ្វេងនិយម ក្នុងរដ្ឋាភិបាលនោះដែរ មានលោកយ៉ែម.សំបូរដែលគេទុកលោកជាអ្នកស្តាំនិយម;សហត្តិភាពរវាងអច្ចន្តិកជន(extrémiste)ទាំងពីរនេះចោទជាបញ្ហាច្រើនដល់ដំណើរការនៃរដ្ឋាភិបាល។ គួរកត់សំកាល់ដែរ អំពីការមិនសុខចិត្តចូលរួមក្នុងរដ្ឋាភិបាលនេះ ពីសំណាក់លោកសឺន.សាន វរជនម្នាក់នៃគណបក្សប្រជាធិបតេយ្យនោះបីមានការស្នើ ឲលោកទទួលតំណែងជា ឧបនាយករដ្ឋមន្ត្រីក៏ដោយ ការមិនព្រមទទួលតំណែងនេះ ឋិតនៅជាភាពអាថ៌កំបាំងជានិច្ច សូម្បីនៅក្នុងកំណត់ការចងចាំរបស់លោកសឺន.សាន ក៏លោកមិនបានប្រាប់ហេតុផលនេះដែរ។

ដើម្បីបំបាត់កម្លាំងនយោបាយគណបក្សប្រជាធិបតេយ្យ ដែលចុះខ្សោយខ្លាំងណាស់ទៅហើយឲអស់តែម្តង ក្នុងឆាកនយោបាយខ្មែរ ហ្លួងសីហនុបានយកប្រជាមតិ(ថ្ងៃទី៧កុម្ភៈឆ្នាំ១៩៥៥)មកធ្វើជាអាវុធនយោបាយ សូមឲប្រជារាស្ត្រ(sujets)ឆ្លើយនឹងសំណួរទ្រង់ថាតើ"ព្រះរាជបូជនីយ៍កិច្ចសម្រាប់ឯករាជ្យកម្ពុជា"បានទទួលជោគជ័យសព្វគ្រប់រួចស្រេចអស់ហើយឬនៅ? ហើយប្រជារាស្ត្រពេញចិត្តឬទេនឹងរាជបេសកកម្មនេះ?

លទ្ធផលនៃប្រជាមតិនេះ វាគ្មានអ្វីឲមោនការភ្ញាក់ផ្អើលនោះទេ អត្រា៩៩ ៨០%នៃចំនួនអ្នកបោះឆ្នោត(៩២៥.៨១២នាក់)យល់ឃើញថា រាជបេសកកម្មរបស់ព្រះមហាក្សត្យជាការល្អប្រសើរ

ណាស់ ហើយបានទទួលជោគជ័យទាំងអស់។ ដូចបានជំរាបរួចហើយថា ទង្វើនេះធ្វើឡើងក្នុងគតិនៃឧបាយបញ្ឆោតរបស់ហ្លួងសីហនុដើម្បីរៀបជើងព្រួលសំរាប់រំលាយលទ្ធិប្រជាធិបតេយ្យ ដែលកំពុងដុះឡើងនៅក្នុងស្រុកខ្មែរ។ ដូចនេះ យើងអាចសួរជាសំណួរថា តើលទ្ធផលនៃប្រជាមតិនេះជាលទ្ធផលវិស្សុសៈ(sincère)ដែរឬទេ?

វិស្សុសភាពគឺប្រកដជាគ្មានពិតក្នុងឧបាយបញ្ឆោត តែសម្លេងឆ្នោតនេះ វាអាចជាលទ្ធផលយថាភូត(authentique)ព្រោះមហាជនខ្មែរយើងនៅពេលនោះ ឆាប់ជឿណាស់លើអ្វីៗដែលអ្នកដឹកនាំ គេយកមកបង្ហាញថា ជាអំពើល្អ ឬគោលដៅត្រឹមត្រូវសំរាប់ជាតិ ឬជឿងប់ងល់លើទិដ្ឋិ (dogme)។ បាតុភូតបែបនេះ ដែលនាំលើកទឹកចិត្តអ្នកដឹកនាំ ឲអនុវត្តឧបាយបញ្ឆោតសំរាប់បក់បោយយកអត្តប្រយោជន៍ លើសពីនេះទៅទៀត អ្នកដឹកនាំមានស្នេហ៍ នៅក្នុងសង្គមហួសសម័យ ច្រើនតែមាននិន្នាការ យកជ័យជំនះតាមការបោះឆ្នោត មកសំអាង ហើយគ្មេរគ្មាន់(កាត់តម្រូវ) ថាខ្លួន មានប្រជាប្រិយភាពជានិច្ចនិរន្ត។ គតិបែបនេះឯង ដែលនាំឲអ្នកដឹកនាំមានស្នេហ៍បែបនេះ ក្លាយខ្លួនទៅជាជនផ្តាច់ការ។

ក្នុងខែកុម្ភៈឆ្នាំ១៩៥៥ គណបក្សប្រជាធិបតេយ្យដូរពណ៌នយោបាយ ព្រោះគណៈកម្មាធិការថ្មីក្នុងចំណោមចំនួនទាំងអស់១២នាក់ ១០នាក់សុទ្ធជាអ្នកឆ្វេងនិយម ហើយក្នុចំណោមចំនួន ១០នាក់នោះទៀត ៧នាក់សុទ្ធជាអតីតនិស្សិតបានទៅរៀននៅប្រទេសបារាំង ដូចយ៉ាងលោកកេង.វ៉ាន់សាក់ ទើបតែវិលត្រឡប់ចូលមកក្នុងប្រទេសវិញ។ សមាសភាពគណកម្មាធិការថ្មីនេះត្រូវបានប្រតិភូរបស់គណៈបក្សចំនួន២០០០នាក់ ភាគច្រើនបំផុត បោះឆ្នោតប្រគល់សេចក្តីទុកចិត្ត ឲដឹកនាំគណបក្សផង និងរៀបចំធ្វើការបោះឆ្នោតរើសសមាជិកសភាជាតិ នៅថ្ងៃទី ១៧មេសាផង។ លទ្ធផលនេះ កើតចេញមកពីការបោះឆ្នោតដាក់ទណ្ឌកម្មពីសំណាក់ប្រតិភូដល់គណកម្មាធិការចាស់ ដែលអនុវត្តនយោបាយ យកចិត្តហ្លួងសីហនុ ដោយអនុញ្ញាតឲវរជនគណបក្សចូលធ្វើសហការក្នុងរដ្ឋាភិបាលដឹកនាំដោយព្រះអង្គ ជាមហាក្សត្រ ដែលជាអំពើផ្ទុយនឹងរដ្ឋធម្មនុញ្ញ នុះហ្លួងសីហនុ ទ្រង់នឹងមានសត្រូវនយោបាយដ៏ខ្លាំងទាំងខាងស្តាំ ក៏ដូចខាងឆ្វេង ទៅថ្ងៃមុខជាពុំខាន។ ខាងអ្នកស្តាំនិយម គណបក្សនយោបាយប្រាំ មានគ្រោងការ រួមបញ្ចូលបង្កើតគណបក្សតែមួយ ដើម្បីចូលរួមបោះឆ្នោត ក្នុងពេលជាមួយគ្នានោះ អ្នកស្រឡាញ់ឧត្តមគតិនយោបាយលោកស៊ឹង.ង៉ុកថាញ់ ដែលជាអ្នករាជានិយមដែរ មានចិត្ត

ប្រឆាំងដាច់ខាតនឹងលទ្ធិកុម្មុយនិស្ត នាំគ្នាប្រមូលគ្នាឡើងវិញ ក្រងជាកម្លាំងនយោបាយ ដើម្បីទាមទារឲ្យព្រះបាទសីហនុគោរពរដ្ឋធម្មនុញ្ញពិតប្រាកដ  ជាមួយគ្នានោះដែរ ក៏គេឃើញមានសកម្មភាព របស់អច្ឆន្ទិកក្រុម ដែលជាក្រុមខ្មែរកុម្មុយនិស្ត ធ្វើសកម្មភាពបំរើនយោបាយយួនកុម្មុយនិស្ត ដើម្បីរំលំរបបរាជានិយម។  ពួកខ្មែរកុម្មុយនិស្តទាំងនោះ គ្មានបានគិតថា លេងល្បែងជាមួយយួន បើមានការភាន់ច្រឡំ គឺវាក្លាយភ្លាមជាការចំណេញដល់ជាតិសាសន៍យួនឥតត្រឡប់ក្រោយបានវិញនោះទេ។

នៅចំពោះមុខកម្លាំងនយោបាយទាំងបួននេះព្រះបាទសីហនុ ទ្រង់បើកយុទ្ធសាស្ត្រតបវិញភ្លាមតាមការសំរេចចិត្ត ដាក់រាជសម្បត្តិ ដើម្បីបង្កើតចលនានយោបាយមួយ ឈ្មោះថា ”សង្គមរាស្ត្រនិយម”។  នុះ  ការប្រយុទ្ធនយោបាយក៏កើតមានឡើងបែបថ្មី  លើកនេះ គឺពុំមែនជាការប្រយុទ្ធរវាងគណបក្សប្រជាធិបតេយ្យជាមួយមហាក្សត្រដូចពីមុននោះទេ តែជាការប្រយុទ្ធរវាងអំណាចផ្តាច់ការ និងពេលវេលាសំណឹងដោយខ្លួនឯងរបស់វាតែម្តង ដែលយើងនឹងលើកវា យកមកពិនិត្យបន្តនៅថ្ងៃមុខទៀត។

### សៀវភៅ និងឯកសារយោង៖


ព្រះពុទ្ធសាសនាដូចម្តេច?.និពន្ធដោយព្រះវិរិយបណ្ឌិតគោប៉ាង.ខាត់(ឆ្នាំ១៩៧០)។

Essai sur la démocratie au Cambodge  par Philippe Preschez (Octobre 1961).។

កំណត់ការចងចាំរបស់អ្នកបំរើមាតុភូមិខ្មែរមួយរូប និពន្ធដោយលោកសឺន.សាន(ឆ្នាំ២០០០)។

Le journal d’Extrême-Orient  1954។


១ កំណត់ការចងចាំរបស់អ្នកបំរើមាតុភូមិខ្មែរមួយរូប និពន្ធដោយលោកសឺន.សាន។

២ ដកស្រង់ចេញពីថលិខិតនៃសមាគមខេមរៈនិស្សិតនៅស្រុកបារាំង ថ្វាយព្រះបាទសីហនុ ចុះថ្ងៃទី៦កក្កដាឆ្នាំ១៩៥២។

៣សុំអ្នកអានសៀវភៅលោកប៉ុនចន្ទម៉ុល(គុកនយោបាយ)និងរកអានសៀវផ្សាយចេញពីគណៈកម្មាធិកអចិន្ត្រៃនៃសមាគមចំ រុះបោះពុម្ពក្នុងឆ្នាំ១៩៦៧ មានចំណងជើងថា ជយោភាសាខ្មែរ។

៤Histoire sommaire du Royaume de Cambodge  des origines à nos jours ; par Henri Russier (1914)។

# ៤

# សម័យឯករាជ្យ
# សម័យសង្គមរាស្ត្រនិយម

## ១.រយៈពេលពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦០

### ១.១.ការកកើតចលនាសង្គមរាស្ត្រនិយម

អ្នកសីហនុនិយម តែងតែលើកយកស្ថិរភាពនយោបាយមកធ្វើជាហេតុផលនៃការកកើតចលនាសង្គមរាស្ត្រនិយម។ អ្នកទាំងនោះ ទុកកំណើតនេះជាស្នាប្រហស្តប្រកបទៅដោយទេពកោសល្យរបស់ព្រះឧបយុវរាជសីហនុ ដើម្បីការពារប្រជារាស្ត្រពីការគំរាមពីចលនាកុម្មុយនិស្ត និងពីអនាធិបតេយ្យនយោបាយនៅក្នុងប្រទេស ដូច្នេះអង្គការនេះ ជាចលនានយោបាយផង និងជាការប្រមូលខ្មែរគ្រប់ស្រទាប់ក្តី គ្រប់គណបក្សនយោបាយក្តី ដែលមានចិត្តស្រឡាញ់ និងការពារប្រយោជន៍ជាតិជាចាំបាច់។

ចលនានេះ បង្កើតបាន ព្រោះមានជំនួយដ៏ថ្លៃថ្លាពីរវជនបីរូប លោកស៊ិម.វ៉ារ សម.សារី និង យ៉ែម.សំបូរ ដែលជាអ្នកស្តាំនិយម។ លោកស៊ិម.វ៉ារ ជាអតីតរដ្ឋមន្ត្រី អតីតវរជននៃគណបក្សប្រជាធិបតេយ្យ ដែលជាមេខ្យល់សំខាន់មួយក្នុងគណបក្ស;លោកយ៉ែម.សំបូរ អតីតនាយករដ្ឋមន្ត្រី និងអតីតប្រធានគណបក្សតំកើងប្រជាជាតិ;លោកសម សារី បវរជន[2]១នៃអ្នកសីហនុនិយម។ សីហនុបានកោះប្រជុំ នៅថ្ងៃទី១៩កុម្ភៈឆ្នាំ១៩៥៥ អង្គទូត និងគណកម្មការត្រួតពិនិត្យនៃការដកទ័ពបរទេសចេញពីស្រុកខ្មែរ ដើម្បីថ្វាយជូនជាព័ត៌មាន នៃគោលបំណងបង្កើតចលនានេះ ក្រោយ១៧ថ្ងៃនៃការបោះឆ្នោតជ្រើសរើសគណកម្មធិការនាយកនៃគណបក្សប្រជាធិបតេយ្យ ក្នុងនោះ មានអ្នកឆ្វេងនិយម១០នាក់ក្នុងចំណោមចំនួនទាំងអស់១២នាក់។

តាមលោកកេង.វ៉ាន់សាក់ ការបង្កើតចលនាសង្គមនិយមនេះ គឺជាកលល្បិចនយោបាយរបស់សីហនុ សំរាប់ប្រឆាំងនឹងគណបក្សប្រជាធិបតេយ្យនៃអ្នកឆ្វេងនិយម[3]២ ដែលជាគណបក្សតែងតែមានជ័យជំនះជានិច្ចតាំងពីឆ្នាំ១៩៤៦មកម្លេះ។ ស្តេចសីហនុ បញ្ឆោតរាស្ត្រខ្មែរក្នុងគំនិតបោកប្រាស បង្ហាញគម្រោងការ កែប្រែរដ្ឋធម្មនុញ្ញ ដូរ របបគណបក្សនយោបាយ ឲទៅជារបប«លទ្ធិប្រជាធិបតេយ្យដែលអាចឲប្រជាពលរដ្ឋយល់ដឹងបាន[4]៣» មានន័យថា ចង់ឲប្រជាពលរដ្ឋក្លាយជាម្ចាស់អំណាច លែងនៅក្រោមការដឹងនាំនៃបុព្វសិទ្ធិជនមួយក្បាប់តូច។

---

[2] បវរជន=Eminence grise។
[3] អ្នកប្រជាធិបតេយ្យឆ្វេងនិយម=Démocrate des progressistes។
[4] លទ្ធិប្រជាធិបតេយ្យដែលអាចប្រជាពលរដ្ឋយល់ដឹងបាន=Démocratie compréhensible pour le peuple។

តាមពិត គម្រោងការនេះ គ្មានអ្វីក្រៅ ពីការបន្តនយោបាយពង្រឹងអំណាចផ្តាច់ការរបស់ស្តេចសីហនុ ក្រោយពីព្រះអង្គ បានធ្វើរដ្ឋប្រហាររដ្ឋធម្មនុញ្ញ កាលពីថ្ងៃទី១៥មិថុនាឆ្នាំ ១៩៥២ និងបំបាត់ចោលឲអស់គណបក្សនយោបាយប្រឆាំងនឹងព្រះអង្គ ដើម្បីឆក់យកអំណាចគ្រប់មុខមកប្រើតាមទំនើងចិត្តព្រះអង្គ។

**រដ្ឋប្រហារថ្ងៃទី១៥មិថុនាឆ្នាំ១៩៥២៖**

រដ្ឋប្រហារនេះ ជាដុំគំរូទី១របស់ហ្លួងសីហនុ យកវាមកផ្គុំគ្នា ដើម្បីសាងវិមាននៃអំណាចផ្តាច់ការរបស់ព្រះអង្គ។ សួរជាសំណួរថា តើហ្លួងសីហនុបានធ្វើអ្វីខ្លះ បានជាយើងអាចចាត់ទុកអំពើនេះ ដោយយកច្បាប់ជាយោង ជារដ្ឋប្រហាររដ្ឋធម្មនុញ្ញ?

ហ្លួងសីហនុ បានប្រើបុព្វសិទ្ធិរបស់ព្រះអង្គជាមហាក្សត្រ លុបរដ្ឋាភិបាលលោកហ៊ុយ-កន្ធុល ដែលសភាជាតិ បានបោះឆ្នោតប្រគល់សេចក្តីទុកចិត្ត ឲដឹកនាំកិច្ចការជាតិ ដូច្នេះ រដ្ឋាភិបាលនេះជារដ្ឋាភិបាលដំណាងរដ្ឋសភា ដែលជាដំណាងប្រជារាស្ត្រខ្មែរ។ ហ្លួងសីហនុលើកយកហេតុផលពីរមកសំអាង ទី១ ចោទរដ្ឋាភិបាលនេះថា ខ្វះសមត្ថភាព បង្ក្រាបពួកអ្នកខ្វែងមតិនយោបាយ(dissident)ភាពធូរនេះ បណ្តោយ ឲលោកស៊ឺង.ង៉ុកថាញ់ អាចភាសខ្លួនចេញពីភ្នំពេញបាន;ទី២ ប៉ូលិស រកឃើញកាំភ្លើង និងខិតប័ណ្ណកំហែងដល់សន្តិសុខជាតិ នៅក្នុងគេហដ្ឋានលោកយ៉ែម.សំបូរ របស់មេឧទ្ទាមម្នាក់ នៅពេលដែលប៉ូលិសធ្វើការឆែកឆេរតាមបង្គាប់តុលាការ ក្រោយពីរដ្ឋាភិបាលលោកហ៊ុយ.កន្ធុល បញ្ជាឲប៉ូលិស ចាប់ឃុំលោក ដោយចោទប្រកាន់លោកថាមានទំនាក់ទំនងនឹងពួកឧទ្ទាម។

សំណួរសួរថា ការលុបរដ្ឋាភិបាលលោកហ៊ុយ.កន្ធុលដោយហ្លួងសីហនុ ហើយទ្រង់យកដំណែងនាយករដ្ឋមន្ត្រី មកកាន់ខ្លួនឯងផ្ទាល់ តើវាជាទង្វើស្របច្បាប់ដែរឬទេ?

ចម្លើយមាននៅក្នុងនិក្ខេបបទសំរាប់ថ្នាក់បណ្ឌិតរបស់លោកផឿង.គុន[5]៤ ដែលយើងយល់ស្របតាម ព្រោះការធ្វើវិភាគជាគតិយុត្តនេះ វាមានមូលដ្ឋានច្បាប់រដ្ឋធម្មនុញ្ញជាយោង។ យើងយកវា មករៀបរាប់តាមសម្រួល ជូនជ្រាបដូចខាងក្រោមនេះ៖

*«ក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មិនមានចែងទុក ថាព្រះមហាក្សត្រមានសិទ្ធិអាចផ្តួលរាជរដ្ឋាភិបាលបាននោះឡើយ សិទ្ធិនេះ មានតែរដ្ឋសភាប៉ុណ្ណោះអាចធ្វើបាន តាមការបោះឆ្នោតដកសេចក្តីទុកចិត្តពីរាជរដ្ឋាភិបាល(មាត្រា៨៥)។ ម្យ៉ាងមួយទៀត រាជរដ្ឋាភិបាល មិនទទួលខុសត្រូវនៅចំពោះមុខព្រះរាជាទេ តែខ្លួនចាំបាច់ទទួលខុសត្រូវនៅចំពោះមុខសភាជាតិ (មាត្រា៨១)ព្រោះសភាជាតិនេះហើយ ដែលរាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជាចាំបាច់ អំពីសកម្មភាពនៃកិច្ចការរដ្ឋ របស់ខ្លួន តើវាជាសកម្មភាពសម្របនឹងប្រយោជន៍ជាតិដែរឬទេ?*

*ដូច្នេះមានតែសភាជាតិទេ ដែលអាចមានសិទ្ធិ វាយតម្លៃនូវសកម្មភាពនយោបាយរបស់រដ្ឋាភិ*

---

[5]៤ La crise cambodgienne ; Thèse pour le doctorat par Phung Thon ; Faculté de droit de Paris(1954)។

*បាល ហើយអាច ស្តីបន្ទោសឬសសើរ តាមការវិនិច្ឆ័យដែលខ្លួនយល់ឃើញ ព្រោះខ្លួនជាដំណាងប្រជាពលរដ្ឋ ហើយជាអ្នកទទួលខុសត្រូវនៅចំពោះមុខប្រជាពលរដ្ឋ។ ឯចំណែកមហាក្សត្រវិញ នៅក្នុងក្នុងរបបគ្រប់គ្រងអាស្រ័យរដ្ឋសភា ព្រះអង្គគ្មានការទទួលខុសត្រូវអ្វីនៅចំពោះប្រជាពលរដ្ឋ ដូច្នេះ ព្រះអង្គពុំអាចមានសិទ្ធិ ផ្តួលរដ្ឋាភិបាល ដែលជាស្ថាប័ន គ្មានការទទួលខុសត្រូវចំពោះមុខព្រះអង្គនោះឡើយ។ ដូច្នេះ នៅពេលណាដែលរដ្ឋាភិបាល គ្មានការដកសេចក្តីទុកចិត្តពីរដ្ឋសភា រដ្ឋាភិបាលនេះ នៅតែជារដ្ឋាភិបាលស្របច្បាប់ជានិច្ច»។*

ឯចំណែក រាជរដ្ឋាភិបាលដែលហ្លួងសីហនុបង្កើតឡើង ហើយដឹលនាំដោយព្រះអង្គផ្ទាល់ ជារដ្ឋាភិបាលក្រៅច្បាប់ ឬជា រដ្ឋាភិបាលដណ្តើមអំណាច កើតចេញមកពីរដ្ឋប្រហារនោះឯង។ នុះឯងហើយ(ainsi)ដែលអ្នកឯកទេសខាងច្បាប់រដ្ឋម្មនុញ្ញ គេទុកទង្វើហ្លួងសីហនុ នៅថ្ងៃទី១៥មិថុនាឆ្នាំ១៩៥២ ជារដ្ឋប្រហាររដ្ឋធម្មនុញ្ញ។

## រំលាយរដ្ឋាភាដោយហ្លួងសីហនុនៅថ្ងៃទី១៣មករាឆ្នាំ១៩៥៣

ទង្វើនេះ ជាការបន្តជាធម្មតានៃការពង្រឹងអំណាចផ្តាច់ការរបស់ហ្លួងសីហនុ ព្រោះព្រះអង្គក្នុងឋានៈជានាយករដ្ឋមន្ត្រីឥតស្របច្បាប់ ទ្រង់មានការពិបាកចាត់ចែងកិច្ចការរដ្ឋ ព្រោះទ្រង់គ្មានការគាំទ្រពិតប្រាកដពីសំណាក់រដ្ឋសភា ដែលមានគណបក្សប្រជាធិបតេយ្យ ជាគណបក្សភាគច្រើន ដូច្នេះឆ្លៀតឳកាសនៅពេលដែលរដ្ឋសភា បោះឆ្នោតប្រឆាំងនឹងគម្រោងការថវិការជាតិ របស់រាជារដ្ឋាភិបាល ដឹកនាំដោយទ្រង់ផ្ទាល់ ទ្រង់ប្រកាសរំលាយរដ្ឋសភាតែម្តង។ សួរជាសំណួរថា ហេតុអ្វី បានសភាជាតិ បោះឆ្នោតប្រឆាំងនឹងគម្រោងការថវិការជាតិរបស់រាជរដ្ឋាភិបាល?

ទំនាស់នោះ មាននៅក្នុងការវាយតម្លៃលើស្ថានភាពជាតិ រវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលយល់ឃើញថា អទិផាត(priorité)លើនយោបាយការពារជាតិ និងសន្តិសុខប្រជាជាតិចំណែករដ្ឋសភាវិញ ឲអទិផាតទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ព្រោះការលើកយកស្ថានភាពអស្ថិរវន្ត(instable)នៃប្រជាជាតិ របស់រាជរដ្ឋាភិបាល ដើម្បីតម្លើងថវិការជាតិក្នុងវិស័យការពារជាតិ និងសន្តិសុខប្រជាជាតិ ជាហេតុផលឥតសមហេតុ ព្រោះសន្ថាភាពនេះ វាកើតមានមកពីរដ្ឋប្រហាររដ្ឋធម្មនុញ្ញនៅថ្ងៃទី១៥មិថុនាឆ្នាំ១៩៥២នោះឯង ដែលនាំប្រជាពលរដ្ឋគ្រប់ស្រទាប់ ក្រមការគ្រប់ក្រសួង និងយុវជន មិនសប្បាយចិត្ត នាំគ្នា ធ្វើកូដកម្មប្រឆាំងនឹងរាជរដ្ឋាភិបាល ដូចយ៉ាង៖

-កូដកម្មសិស្សអនុវិទ្យាល័យបច្ចេកទេស និស្សិតសាលាគរុកោសល្យ សិស្សវិទ្យាល័យស៊ីសុវត្ថិ អនុវិទ្យាល័យយុវតី និងវិទ្យាល័យ និងអនុវិទ្យាល័យសំខាន់ៗឯទៀតនៅតាមបណ្តាខេត្តនានា;

-ការតវ៉ាពីសំណាក់និស្សិតខ្មែរនៅប្រទេសបារាំង ប្រឆាំងនឹងរដ្ឋប្រហារថ្ងៃទី១៥មិថុនាឆ្នាំ១៩៥២ នាំឲហ្លួងសីហនុមានប្រតិកម្មកម្រោល ផ្តាច់អាហារូបករណ៍និស្សិតខ្មែរចំនួន២០នាក់ ហើយស្នើសូមឲអាជ្ញាធរបារាំងរំលាយសមាគមនិស្សិតខ្មែរនៅប្រទេសបារាំង ជាពិសេស សមា

គមខេមរៈនិស្សិត មាននិន្នាការនយោបាយឆ្វេងនិយម ដែលបានសរសេរលិខិតថ្វាយព្រះអង្គផ្ទាល់ នៅថ្ងៃទី៦កក្កដាឆ្នាំ១៩៥២ រិះគន់ នយោបាយទ្រង់ ចោទថា ជានយោបាយបំផ្លាញសេរីភាពរបស់រាស្ត្រខ្មែរ ចោទរបបរាជាធិបតេយ្យ ថាជារបបមនុស្សជិះជាន់មនុស្សៈ កូដកម្មអ្នករាជការ នាយទាហាន ព្រះសង្ឃនៃសាលាជាន់ខ្ពស់ភាសាបាលី(ថ្ងៃ១២មករាឆ្នាំ១៩៥៣)។

នៅថ្ងៃរំលាយរដ្ឋសភានោះ ហ្លួងសីហនុប្រកាសជាសាធារណៈថាទ្រង់«*នឹងប្រឆាំងដាច់ខាតដល់គ្រប់ជនណា ឬគណបក្សនយោបាយណា ប្រឆាំងនឹងកម្មវិធីនយោបាយរបស់ទ្រង់ ហើយទ្រង់ទុកអ្នកប្រឆាំងជាជនក្បត់ជាតិ*»។ ប្រកាសបែបនេះ គឺមានបំណងយកការទាមទារឯករាជ្យជាសកម្មភាពផ្តាច់មុខរបស់ទ្រង់ ដោយបំបែកស្រុកខ្មែរជាពីរពួក គឺពួកព្រះអង្គ ធ្វើតាមព្រះអង្គឥតអាចប្រកែកបាន និងពួកដែលគេមានគំនិតទាមទារឯករាជ្យជូនជាតិដែរ តែមិនធ្វើតាមរបៀបព្រះអង្គ ឬមិនរួមនឹងព្រះអង្គ។ នយោបាយបែបនេះ មានតែអ្នកដឹកនាំផ្តាច់ការទេ ដែលយកមកអនុវត្តន៍។

សួរថា ការរំលាយរដ្ឋសភានេះ ជាទង្វើស្របច្បាប់ដែរឬទេ?

ម្តងទៀត ចម្លើយមាននៅក្នុងនិក្ខេបបទសំរាប់ថ្នាក់បណ្ឌិតរបស់លោកផឿង.តុនៈ

«*មាត្រា៣៨នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ អនុញ្ញាតិឲសិទ្ធិមហាក្សត្រ អាចរំលាយសភាជាតិបានមួយដង តែត្រូវចាំបាច់មានការស្នើពីនាយករដ្ឋមន្ត្រី,ដូច្នេះមហាក្សត្រ មិនមានសិទ្ធិខ្លួនឯង ប្រើអំណាចពិត(pouvoir réel)ជាក់លាក់ ដែលព្រះអង្គគ្មាន យកមករំលាយរដ្ឋសភាបាននោះឡើយព្រោះក្នុងរបបគ្រប់គ្រងអាស្រ័យរដ្ឋសភា មានតែនាយករដ្ឋមន្ត្រីទេ អាចស្នើសុំទៅព្រះរាជា សុំឲព្រះអង្គរំលាយរដ្ឋសភា សិទ្ធិនេះអ្នកតែងច្បាប់គេបង្កើតឡើង ក្នុងគតិ(esprit)រកសមតានៃអំណាចនីតិប្រត្តិបត្តិ និងនីតិបញ្ញាតិនេះឯង* »។

«*ក្នុងមតិផ្ទាល់របស់ខ្ញុំ(ផឿង.តុន)គេអាចធ្វើការសង្កេតមួយថា នៅពេលនោះមហាក្សត្រជានាយករដ្ឋមន្ត្រី ដូច្នេះ ព្រះអង្គអាចស្នើទៅខ្លួនព្រះអង្គ ជាព្រះរាជា ឲរំលាយរដ្ឋសភា។ ការសង្កេតបែបនេះ វាគ្មានភាពសមហេតុផលទេ ព្រោះនៅពេលណា មានអំណាចណាមួយនៃស្ថាប័នទាំងបី(មហាក្សត្រ នីតិប្រត្តិបត្តិ និងនីតិបញ្ញាតិ)ឈប់មានអានុភាព ពេលនោះ គេមិនអាចយកមាត្រា៣៨មកអនុវត្តន៍បាននោះឡើយ ព្រោះច្បាប់រដ្ឋធម្មនុញ្ញ មានបែងចែកដាច់គ្នាច្បាស់នៃសមត្ថភាព របស់ស្ថាប័ននិមួយៗ ហើយសមត្ថភាពនេះ វាពុំអាចរលាយចូលគ្នាបាននោះឡើយ ព្រោះថា គេពុំអាចធ្វើជាអាជ្ញាកណ្តាលផង និងជាអ្នកប្រកួតកីឡាផង ដូច្នេះ អំពើដែលហ្លួងសីហនុបានធ្វើនេះ វាមាននៅតែក្នុងរបបផ្តាច់ការតែប៉ុណ្ណោះ*»។

គួរដឹងដែរថា នៅពេលដែលហ្លួងសីហនុ រំលំរដ្ឋាភិបាលលោកហ៊ុយ.កន្ថុល ទ្រង់បានកំញើញសភាជាតិ ឲធ្វើច្បាប់មួយឡែក ហាមមិនឲបុគ្គលណា ឬគណបក្សណា ធ្វើអំពើល្មើសព្រះករុណា។

## រាជានិយមផ្តាច់ការ

នៅពេលហ្លួងសីហនុ ចាប់ផ្តើមធ្វើ«ព្រះរាជបូជនីយ៍កិច្ចសម្រាប់ឯករាជ្យកម្ពុជា»នៅថ្ងៃទី១៥ មិថុនាឆ្នាំ១៩៥២ ព្រះអង្គបានសុំស្នើតាមតែសំដីទ្រង់ទៅប្រជាពលរដ្ឋ ដែលជាកិច្ចសន្យា គ្មាននិយតកម្ម(ឥតត្រឹមត្រូវតាមច្បាប់)ថាព្រះអង្គសុំរយៈពេលបីឆ្នាំ សំរាប់ធ្វើសម្ភភាពទាមទារឯករាជ្យពីបារាំងយកមកជូនជាតិ ហើយស្បថចំពោះទេវតាថានឹងខំប្រឹងធ្វើឲសំរេចទាល់តែបាននូវគោលបំណងនេះ។  សំណើឥតមូលដ្ឋានច្បាប់នេះ គឺសំរាប់តែបង្វែងនូវការចាប់អារម្មណ៍ប្រជាពលរដ្ឋទៅលើរដ្ឋប្រហារ ដែលព្រះអង្គកំពុងធ្វើដោយរំលោភច្បាប់រដ្ឋ នៅថ្ងៃនោះដែរ គឺរំលំរដ្ឋាភិបាលលោកហ៊ុយ.កន្ធុល ដែលជារដ្ឋាភិបាលដំណាងសភាជាតិ ដែលជារដ្ឋសភាពដំណាងរាស្ត្រ ហើយរឿងទាក់ទងនឹងសំបថនោះទៀត គឺគ្មានអ្វីក្រៅពីការចំអករបស់ហ្លួងសីហនុ យកជំនឿឥតហេតុផល មកបោកប្រាស់ប្រជាពលរដ្ឋឆាប់ជឿនោះឯង។

ម្យ៉ាងមួយទៀត នៅថ្ងៃទី១៥មករាឆ្នាំ១៩៥៣ ព្រះអង្គប្រកាសក្រម ថាប្រទេសជាតិមានអាសន្នការប្រកាសនេះ គឺសំរាប់តែបង្វែង ម្តងទៀត នូវការចាប់អារម្មណ៏ប្រជាពលរដ្ឋ ទៅលើការរំលាយរដ្ឋសភា ដោយទ្រង់ នៅថ្ងៃទី១៣មករាឆ្នាំ១៩៥៣នោះដែរ។  ក្នុងចំណុចនេះ ហ្លួងសីហនុបានបំពានដាក់ស្តែងលើច្បាប់រដ្ឋធម្មនុញ្ញ ព្រោះរបបគ្រប់គ្រងអាស្រ័យរដ្ឋសភា ស្ថាប័នអាចវាយតម្លៃនូវ ភារពលនៃការីករដែលមានកើតឡើងនៅក្នុងប្រទេស មានតែរដ្ឋសភានោះឯង ដោយហេតុនេះ រដ្ឋសភា ជាអ្នកប្រកាសនូវភាពអាសន្ននៃប្រជាជាតិ មិនមែនមហាក្សត្រអាចយកអំណាចខ្លួន ដែលជាអំណាចជានិមិត្តរូប(pouvoir symbolique)មកប្រកាសប្រជាជាតិមានអាសន្នបាននោះឡើយ។

តាំងពីប្រទេសខ្មែរយករបបគ្រប់គ្រងអាស្រ័យរដ្ឋសភាមកអនុវត្តន៏ ហ្លួងសីហនុបានរំលោភពីរដងនូវដំណើរប្រក្រតីនៃលទ្ធិប្រជាធិបតេយ្យ គឺយកអំណាចកម្រោលមករំលាយរដ្ឋសភាដែលជាសភាដំណាងរាស្ត្រខ្មែរ ហើយនាំឲមានវិបត្តិរដ្ឋធម្មនុញ្ញនៅកម្ពុជា លើកទី១នៅក្នុងឆ្នាំ១៩៤៩ លើកទី២ នៅក្នុងឆ្នាំ១៩៥៣ ហើយលើកទី២នេះឯង ដែលអំពើដាក់ស្តែងក្នុងបំណងបំបាត់ចោលលទ្ធិប្រជាធិបតេយ្យសេរីនៅស្រុកខ្មែរ ដើម្បីប្រត្យាស្ថាបនា របបរាជានិយមផ្តាច់ការ ក្នុងរបបនេះ ទ្រង់មានអំណាច អាចនឹងធ្វើអ្វីបានគ្រប់បែបយ៉ាង តាមតែទំនើងចិត្តខ្មៅរបស់ទ្រង់ ដូចយ៉ាង៖

-ដណ្តើមយកអំណាចទាំងមូល មិនត្រឹមតែអំណាចនីតិប្រត្តិបត្តិ និងនីតិបញ្ញាតិ ថែមទាំងយកអំណាចតុលាការ មកធ្វើជាអាវុធនយោបាយ ដូចយ៉ាងតែងតាំងចៅក្រមធំៗ សុទ្ធតែជាជនស្មោះនឹងព្រះអង្គ;

-ចាប់ដាក់គុកសមាជិករដ្ឋសភាជាច្រើននាក់ ដោយឥតរវល់ឈឺក្បាលនឹងអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រនោះឡើយ;

-លប់ចោលសេរីភាពបុគ្គល សេរីភាពមតិ សេរីភាពរួមប្រជុំគ្នា ហើយបង្កើតប្រព័ន្ធត្រួតពិនិត្យ

(censure)គ្រប់វិស័យ ដែលគេឃើញមាន នៅតែក្នុងប្រទេស ដឹកនាំដោយរបបផ្តាច់ការ។ ដូច្នេះ អ្វីដែលហ្លួងសីហនុបានធ្វើ ដូចបានរៀបរាប់ខាងលើនេះ វាមានចរិកលក្ខណៈជារបបផ្តាច់ការ ដែលវិទូនយោបាយ(politologue) គេសំគាល់ឃើញជាទូទៅ.នូវធាតុបីយ៉ាងរបស់វា គឺ
១.អំណាចផ្តាច់ការ ច្រើនតែប្រកាសប្រើដោយខ្លួនឯង ដោយគ្មានកំរិតអាណត្តិ ឬអាណត្តិមួយមានរយៈពេលយូរ;
២.អំណាចផ្តាច់ការ តែងតែជ្រើសរើស លុះកាលវេលាមកដល់ជា**សុទិន**(temps favorable)ធ្វើប្រជាមតិក្តី ឬរៀបចំការបោះឆ្នោតក្តី ព្រោះដឹងច្បាស់ថាពិតជាឈ្នះជាពុំខាន;
៣.អំណាចផ្តាច់ការ នៅពេលធ្វើប្រជាមតិ ជ្រើសរើសដោយខ្លួនឯង នូវសំណួរណាដែលខ្លួនដឹងច្បាស់ជាមុននូវចម្លើយជាវិជ្ជមានសំរាប់ខ្លួន។
គម្រោងការកែរដ្ឋធម្មនុញ្ញ ដែលសីហនុយកមកលាតត្រដាង នៅថ្ងៃទី១៥កុម្ភៈឆ្នាំ១៩៥៥ នៅចំពោះមុខអង្គទូត និងគណកម្មាធិការអន្តរជាតិត្រួតពិនិត្យ(c.i.c.)ការដកទ័ពបរទេសចេញពីស្រុកខ្មែរ ជាដំណាក់ការទីបំផុត សំរាប់បង្កើតឡើងវិញនូវរបបរាជាផ្តាច់ការតែប៉ុណ្ណោះ។ គួរដឹងដែរថា គម្រោងការនេះ មានប្រតិកម្មជាអវិជ្ជមាន ជាផ្លូវការ ពីសំណាក់**គ.អ.ត.**(C.I.C.) ព្រោះគេមើលឃើញរួចស្រេច ថាជាឧបាយកលសំរាប់ដាំរបបផ្តាច់ការ ដែលវាខុសពីគតិនៃសន្និសិទនៅទីក្រុងស៊ឺណែវ ស្តីពីសន្តិភាពនៅឥណ្ឌូចិន។
យោងទៅលើឧបជិ(ការបោកប្រាស)របស់ហ្លួងសីហនុ ដែលយើបានរៀបរាប់ខាងលើនេះ ការបង្កើតចលនាសង្គមរាស្ត្រនិយម គឺជាការបង្កើតចលនាមួយសំរាប់ធ្វើជារាំងនន បិតបាំងការវិលត្រឡប់មកវិញនៃរបបរាជានិយមផ្តាច់ការ ឬរបបសីហនុនិយមតែប៉ុណ្ណោះ។ ហ្លួងសីហនុដាក់រាជ្យនៅថ្ងៃទី២មិនាឆ្នាំ១៩៥៥ ព្រោះរាជសម្បត្តិ វាគ្មានតម្លៃអ្វីទៀតទេ សំរាប់ទ្រង់ ព្រោះព្រះអង្គដណ្តើមអំណាចបានអស់ទៅហើយ មួយវិញទៀត ទ្រង់ប្រើអំណាច ចែកអំណោយថ្វាយដល់បិតាទ្រង់ថែមទៅទៀត គឺផ្ទេររាជសមបត្តិ ថ្វាយអ្នកមានគុណព្រះអង្គ។ ការថ្វាយអំណោយរាជសម្បត្តិ ដល់បិតានេះទៀត ជាល្បិចវៀរ(éviter)មិនឲមានអ្នកណាមួយនៅពីលើទ្រង់បានតែប៉ុណ្ណោះ។ អំណាចពិត ព្រះអង្គក្តោបបានអស់ហើយ ដូច្នេះ ត្រូវធ្វើយ៉ាងដូចម្តេច ឲអំណាចជានិមិត្តរូប ជាអំណាចមហាក្សត្រ ឋិតនៅលើដៃទ្រង់ដដែល គឺគ្មានល្បិតអ្វីល្អជាងប្រគល់ថ្វាយបិតា ឲគ្រប់គ្រង ដោយដឹងច្បាស់ ថាអ្នកមានគុណព្រះអង្គ មិនយកវា មករំខានអំណាចពិតរបស់ទ្រង់នោះទេ ដូចព្រះអង្គ តែងតែយកវាមកប្រើ ដើម្បីរំខានរដ្ឋសភាតាមទំនើងចិត្តទ្រង់។
យើងអាចឧបមាថា សីហនុនិយមជាដំណាងអំណាចផ្តាច់ការ រាជានិយមជាដំណាងសីហនុ សីហនុជាដំណាងសីហនុ។ តើប្រជាជាតិខ្មែរជាអ្វី?ចំពោះខ្ញុំ នៅពេលណា ខ្មែរម្នាក់ៗ នៅតែរំលឹកគុណដល់ខ្មោចព្រះករុណាសីហនុ គឺច្បាស់ជាស្រុកខ្មែរនៅមានទុក្ខវេទនាជានិច្ច ព្រោះសីហនុនេះឯង ជាទុក្ខវេទនារបស់ជាតិខ្មែរ តាំងពីនៅមានជីវិត រហូតចាកលោកនេះទៅបរលោក។

### ១.២.គតិនៃចលនាសង្គមរាស្ត្រនិយម

បើលើកយកទ្រឹស្តី”សង្គមរាស្ត្រនិយម”មកពិនិត្យ តាមការឃោសនានៃអ្នកសីហនុនិយម គឺពិតជាឃើញមានភាពផ្ទុយពីកំណើតមក ដូចយ៉ាង៖

១.ជាសហគមន៍ដើម្បីកិត្តិយសសីលធម៌ សំរាប់ដំកើងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយមានការធានានៃការចំរើនសង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ ពីចលនានេះ;

២.ជាសហគមន៍ ជាដំណាងនូវសេចក្តីប្រាថ្នានៃប្រជាពលរដ្ឋពិត មាតុភូមិ ជាសហគមន៍រួបរួមជាតិដើម្បីប្រឆាំងនឹងអំពើអយុត្តិធម៌ អំពើពុករលួយ ការរឹបជាន់ និងការក្បត់ចំពោះប្រជាពលរដ្ឋ និងប្រជាជាតិ;

៣.ជាសហគមន៍ការពារឯកភាពជាតិ ការពារប្រពៃណីដ៏ល្អថ្លៃថ្នូរបស់ជាតិខ្មែរ ដែលវាធ្លាប់ធ្វើឲប្រជាជាតិស្គាល់នូវសេចក្តីរុងរឿងក្នុងអតីតកាល។ ប្រពៃណីនេះ កើតពីការរួបរួមនៃរាស្ត្រ ជាមួយឧបត្ថម្ភកៈ(protecteur)ជាធម្មជាតិពីរយ៉ាង គឺពុទ្ធសាសនា និងរាជបល័ង្គ។

តាមពិត ទ្រឹស្តីសង្គមរាស្ត្រនិយម ជាទ្រឹស្តីកើតចេញពីគ្រឿងផ្សំ បង្កើតដោយបុគ្គលសីហនុ ពីមួយថ្ងៃទៅមួយថ្ងៃ ទាញយកប្រសិទ្ធិភាព ពីក្នុងអារម្មណ៍(réalisme)របស់ព្រះអង្គផ្ទាល់ យកវាមកនិយាយឃោសនា បញ្ឆើចរាស្ត្រឆាប់ជឿ ដូចយ៉ាង កាន់ចបកាប់ដីលើកត្រនប់ទឹក ដោះស្រាយបញ្ហាយុត្តិធម៌ជូនរាស្ត្រក្នុងសួនផ្កាកណ្តាលថ្ងៃ លេងកីឡាទាត់ប៉ាល់ ទះបាល់ រាល់ល្ងាចជាមួយ កុង្សីសេនាបតី ដំណាងរាស្ត្រ ឬឯកអគ្គរដ្ឋទូត នៅក្នុងដំណាក់ចំការមន ដើម្បីថតជាខ្សែភាយន្ត សំរាប់បញ្ចាំងជូនប្រជារាស្ត្រមើលក្នុងរោងកុន និងទីលានសាធារណៈ។ ទង្វើនេះ គឺសំរាប់ឲរាស្ត្រគោរព និងស្រឡាញ់រូបសីហនុឲដូចជាទេពតា ចុះពីឋានសួគ៌មកចាប់កំណើតជាមនុស្ស ក្នុងឋានលោកីយនោះឯង។

### ស្នេហ៍ស្តេចសំរាប់បំពេចិត្តរាស្ត្រ និងអ្នកនយោបាយខ្មែរ

សួរជាសំណួរថា រាស្ត្រទៅចុះ មានចិត្តស្រាល ឆាប់ជឿគេ ព្រោះស្រឡាញ់ដោយខ្លាចស្តេច តាមទម្លាប់ ជាប់ស្នេហ៍ស្តេចតាំងពីបុរាណកាលមក ចុះហេតុអ្វីបានជា មានអ្នកនយោបាយសម័យអ្នកចេះដឹងចំណេះទំនើប នាំគ្នាត្រូវត្រូវស្នេហ៍ស្តេចហ្នុះដែរ?

នៅពេលដែលរបបគ្រប់គ្រងអាស្រ័យរដ្ឋសភា បានក្លាយទៅជារបបរាជានិយមផ្តាច់ការ ចរិកអាក្រក់តពូជខ្មែរ ក៏បានអង្រួនឡើងវិញនៅក្នុងគំនិតខ្មែរ ទាំងរាស្ត្រ ទាំងមន្ត្រី ទាំងអ្នកនយោបាយ ភាគច្រើន ខ្លាច ឃ្លានអំណាច នាំគ្នាមើលឃើញហ្លួងសីហនុជាព្រះបាទធម្មិក ជាព្រះថ្មី មានចិត្តក្តីស្រដង់ប្រជាជាតិខ្មែរពីគ្រោះអាសន្ន តែឥតបាននាំគ្នាគិតពិចារណា ឲបានច្បាស់លាស់ថា គ្រោះអាសន្ននោះ គឺព្រះថ្មីនេះឯងជាសាបព្រោះការវឹកវរនៅក្នុងនគរនោះឯង ហើយនាំគ្នាចុះចូលក្នុងចលនាសង្គមរាស្ត្រនិយម ឥតមានល័ក្ខខណ្ឌ។ ពេលនោះនៅសល់រវជនភាគតិចបំផុត ក្នុងចំណោមអ្នកនយោបាយខ្មែរ នៅមានឧត្តមគតិមិនព្រមចាញ់ស្នេហ៍ស្តេច

តែជាអកុសល ពួកអ្នកគស្ញុំគំនិតទាំងនោះ ច្រើនតែមាននិន្នាការនយោបាយជាអ្នកឆ្វេងនិយម ឬកុម្មុយនិស្តនិយម ដោយហេតុនេះ ក្នុងរបបសីហនុនិយម គឺឃើញមានតែនិន្នាការនយោបាយអច្ចន្តភាព(extrême)ពីរតែប៉ុណ្ណោះ ប្រឈរមុខទល់គ្នា លើងឆាកនយោបាយនៅក្នុងស្រុកខ្មែរ គឺអ្នកសីហនុនិយម និងអ្នកឆ្វេងនិយម។ ការបោះបង់ចោលការគស្ញុំមតិ នៃអ្នកស្តាំនិយម អ្នកជាតិនិយម ដែលជាអ្នកប្រជាធិបតេយ្យសេរីពិត ហើយនាំគ្នាទៅចុះចូលហ្លួងសីហនុ ឧបមានាំគ្នា យកអាហារទៅចិញ្ចឹមចិញ្ចឹមខ្លា ឲបានធាន់ធំ សំរាប់ស៊ីខ្លួនឯងទៅថ្ងៃក្រោយនោះឯង។ ដូចខ្ញុំបានជំរាបពីខាងលើរួចមកហើយ អ្នកនយោបាយខ្មែរជំនាន់នោះគាត់មិនសូវស្គាល់ថាអ្វីទៅជាមនោគមវិជ្ជាដែលគាត់ត្រូវប្រកាន់យកជាដាច់ខាត ដើម្បីរក្សាសេចក្តីថ្លៃថ្នូររបស់គាត់ជាមនុស្សផង និងជាកម្លាំងនយោបាយរបស់គាត់ផង។ ខ្វះមនសិកាជាតិនេះឯង ដែលជាកត្តា នាំគ្នារត់ទាំងហ្វូង ទៅចូលសីហនុ ព្រោះគាត់យល់ច្រឡំថា នយោបាយ គឺជាយស័ក្តិ ដែលជាក្អែលក្រាសឃ្នីកនៃទំនៀមខ្មែរ។ តើគតិខ្មែរបែបនេះ វាមានអ្វីខុសគ្នាទៅ នឹងគតិក្នុងសម័យនេះ? អ្នកនយោបាយបែបជាអ្នករកអត្ថប្រយោជន៏ គឺជារវជនអំណាចតែប៉ុណ្ណោះ។

ចំណែករាស្ត្រខ្មែរ នៅពេលគាត់ឃើញការវិលត្រឡប់របបរាជានិយមផ្តាច់ការមកវិញ ពេលនោះគំនិតបាក់ស្បាត ខ្លាចអំណាចហ្លួង ក៍វាវិលត្រឡប់មកវិញខ្លួនឯក ក្នុងគតិរបស់គាត់ដែរ ព្រោះការខ្លាចអំណាច វាក្លាយជាធម្មជាតិនៃជនខ្មែរម្នាក់ៗអស់ច្រើនសតវត្សរួចមកហើយ។ មួយវិញទៀត អ្វីដែលរាស្ត្រខ្មែរ គាត់លែងយល់ទៅទៀត គឺគាត់ឮពាក្យបញ្ចោរជានិច្ច ពីសំណាក់អ្នកនយោបាយផង អ្នកចេះដឹកផង ថាប្រជារាស្ត្រខ្មែរជាពូជពង្សខ្មែរអង្គរ តែពេលដែរគាត់ឮពាក្យផ្អែមបែបនេះ គាត់នាំគ្នាស្រណោះ គិតក្នុងចិត្តថា ឱព្រះអើយ!បើអញសព្វថ្ងៃនេះ អញវេទនាបែបនេះ ចុះនៅក្នុងសម័យមហាចក្រស្តេច មហាក្សត្រ មានអំណាចស្មើនឹងយោមរាជតើខ្មែរអង្គរ ដែលជាញាតិសន្តានរបស់អញ តើគាត់វេទនាចិត្តកាយបែបណាទៅក្នុងរបបមនុស្សជិះជាន់មនុស្ស?

សួរថាតើកត្តាមនុស្សនេះឯងឬ ដែលនាំឲរបបរាជានិយមផ្តាច់ការ អាចនៅថែរក្សាបាននូវឯកសិទ្ធិមហាក្សត្រឲគង់វង់ជានិច្ច ដែលនាំឲដៅលែងដុះនូវលទ្ធិប្រជាធិបតេយ្យសេរីនៅស្រុកខ្មែរ?

យើងឃើញច្បាស់ហើយថា ចលនាសង្គមរាស្ត្រនិយម កើតចេញពីរបបផ្តាច់ការ ហើយអ្នកបង្កើតសោតទៀត គឺពួកជនមួយក្តាប់តូច មានហ្លួងសីហនុជាសេនាប្រមុខ។ ដូច្នេះ វាគ្មានការអ្វីគួរឲងឿងឆ្ងល់ទេ អំពីជ័យជំនះដាច់មុខនៅក្នុការបោះឆ្នោត នៅថ្ងៃទី១១កញ្ញាឆ្នាំ១៩៥៥ របស់សង្គមរាស្ត្រនិយម ព្រោះជាការបោះឆ្នោតគ្មានសេរី យុត្តិធម៌ ផ្គងរៀបចំឡើង ពីក្រុមអ្នកសីហនុនិយម ដើម្បីជ័យជំនះរបស់ព្រះករុណារបស់ខ្លួន។ ដូច្នេះ យើងអាចសន្និដ្ឋានបាន”សង្គមរាស្ត្រនិយម”បង្កើតឡើងសំរាប់តែបុគ្គលសីហនុតែប៉ុណ្ណោះ។

## ១.៣.សកម្មភាពនយោបាយ របស់សង្គមរាស្ត្រនិយម ពីឆ្នាំ១៩៥៥ដល់១៩៦០

### សកម្មភាពនយោបាយក្នុងប្រទេស

គឺគ្មានអ្វីក្រៅពីការខំពង្រឹងអំណាចផ្តាច់ការសម្តេចសីហនុឡើយ ដូចយ៉ាង៖
នៅថ្ងៃទី១៤មករាឆ្នាំ១៩៥៦ ការប្រកាសប្រើរដ្ឋធម្មនុញ្ញថ្មី ដែលជារដ្ឋធម្មនុញ្ញតម្រូវអំពើល្មើសសម្តេចសីហនុតែប៉ុណ្ណោះ។
នៅក្នុងខែវិច្ឆិកាឆ្នាំ១៩៥៧ បង្កើតចលនាយុវជនសង្គមរាជានិយមខ្មែរ ដើម្បីឲឈរចាំទះដៃនិងស្រែកថា"ជ័យយោសម្តេចឪ បិតាឯករាជ្យជាតិ!"។
នៅថ្ងៃទី៨មករាឆ្នាំ១៩៥៨ សម្តេចសីហនុ រំលំរាជរដ្ឋាភិបាលដឹកនាំដោយលោកស៊ីម.វ៉ា ដោយសារលោក ជំទាស់នឹងទ្រង់ អំពីចំណង់របស់ទ្រង់ ចង់យកសមាជជាតិមកធ្វើជាស្ថាប័នជាតិមួយនៅក្នុងរដ្ឋធម្មនុញ្ញ។
នៅថ្ងៃទី៨មករាឆ្នាំ១៩៥៨ សម្តេចសីហនុប្រកាសរំលាយរដ្ឋសភា ក្នុងចិត្តខ្មៅរបស់ទ្រង់ គឺសភាជាតិនេះ មិនសូវជួយជិតដល់នូវចំណង់ហួសហេតុរបស់ទ្រង់ គឺពង្រឹងអំណាចផ្តាច់ការ។
-នៅថ្ងៃទី២៦មករាឆ្នាំ១៩៥៨ សម្តេចសីហនុធ្វើប្រជាមតិអំពីច្បាប់បោះឆ្នោត ដើម្បីប្រយោជន៍ទ្រង់ តែទ្រង់ប្រើឧបាយកល ដូចដែរទ្រង់ធ្លាប់ធ្វើដើម្បីបំភាន់មតិរាស្ត្រ ល្បិចនោះគឺ ឲសិទ្ធិស្ត្រីអាចបោះឆ្នោតបាន។
-នៅថ្ងៃទី២៩មករាឆ្នាំ១៩៥៨ បោះឆ្នោតរើសមាជិកសភាជាតិ។ ជោគជ័យជាអតិបរិមាណរបស់ចលនាសង្គមរាស្ត្រនិយម។
-ក្នុងខែមករាឆ្នាំ១៩៥៩ លោកសម.រង្សី ដែលជាសិប្បករដ៏សំខាន់មួយនៃការបង្កើតចលនាសង្គមរាស្ត្រនិយម រត់ចូលព្រៃ ព្រោះមានទំនាស់មតិនយោបាយជាមួយសម្តេចសីហនុ។ ទំនាស់នោះគឺនៅត្រង់ លោក ប្រកាសតាមលិខិត ហើយចុះផ្សាយក្នុងកាសែត"រដ្ឋាធិបតេយ្យ"នៅថ្ងៃទី១មករា បង្កើតចលនាប្រឆាំងនឹងសង្គមរាស្ត្រនិយម។ ចលនាលោក មានឈ្មោះថា"ចលនារួបរួមអ្នកប្រជាធិបតេយ្យ" ស្ថាបទជនសំខាន់មានលោកសម.សារី និងលោកចៅ.បូរី។
សម្តេចសីហនុ មានប្រតិកម្មប្រឆាំង ទាំងកម្រោលនឹងសារលិខិតនេះ ហើយចោទប្រកាន់ថាជាអំពើក្បត់ជាតិ។ គេដឹងច្បាស់ថា លោកសម.សារី លោកមិនមែនជាសន្តជនទេ តែសិទ្ធិបង្កើតគណបក្សនយោបាយ ជាសេរីភាពរបស់មនុស្សម្នាក់ៗដែលមានចែងក្នុងសេចក្តីថ្លែងប្រកាសជាសាកលនៃសិទ្ធិមនុស្ស។ ចោទលោកថាជាជនក្បត់ជាតិ អ្នកដែលចោទនោះទេ ជាជនក្បត់រាស្ត្រដែលជាម្ចាស់របស់ប្រជាជាតិ។
គួរដឹងដែរថា ថ្ងៃក្រោយមក សម្តេចសីហនុ ចាប់លោកចៅ.បូរី យកទៅបាញ់ប្រហារជីវិត ជាសាធារណ:នៅត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ ដោយគ្មានជំនុំជំរះទោស។ ដើម្បីទុកជាមេរៀនសីហនុឲថតកុននូវការបាញ់ប្រហារជីវិតលោកចៅ.បូរី ហើយឲយកកុននេះ ទៅបញ្ចាំង

តាមសាលារៀនគ្រប់ថ្នាក់ ជាពិសេសបង្ខំឲកុមារា កុមារីទៅទស្សនាភាពយន្តនេះ។ នេះហើយជាអំពើព្រៃផ្សៃរបស់សីហនុ។
-ក្នុងខែកុម្ភៈឆ្នាំ១៩៥៩ ស្តេចសីហនុអនុញ្ញាតឲកេងខេមរៈភូមិន្ទ សម្លាប់លោកដាប.ឈួន អតីតខ្មែរឥស្សរៈ មេគណបក្ស និងរដ្ឋមន្ត្រី ដោយចោទប្រកាន់លោក ថាមានបំណងជាក់ច្បាស់ចង់ធ្វើរដ្ឋប្រហារ ដោយមានយួនខាងត្បូងនៅពីក្រោយ។
-ថ្ងៃទី២៦វិច្ឆកាឆ្នាំ១៩៥៩ សម្តេចសីហនុបញ្ញាឲព្យួរសកម្មភាពសភាជាតិ។
-ក្នុងខែមិថុនាឆ្នាំ១៩៦០ សម្តេចសីហនុធ្វើប្រជាមតិ សុំឲប្រជាពលរដ្ឋជ្រើសរើសរវាងនយោបាយព្រះអង្គ នឹងនយោបាយលោកស៊ីង.ង៉ុកថាន់ និងអ្នកកុម្មុយនិស្តនិយម។
-ថ្ងៃទី១៧ធ្នូឆ្នាំ១៩៦០ សភាទាំងពីរ(រដ្ឋសភាព និងក្រុមព្រឹក្សាព្រះរាជាណាចក្រ)បោះឆ្នោតតែងតាំងសម្តេចសីហនុជាប្រមុខរដ្ឋអស់មួយជាជិវិត។
-ថ្ងៃទី៣មេសាឆ្នាំង១៩៦០ មហាក្សត្រនរោត្តម សុរាម្រិត ទ្រង់ប្រឈួនរោគសគតទៅនៅក្នុងព្រះជន្មាយុ៦៤វស្សា។

## សកម្មភាពនយោបាយក្រៅប្រទេស

-ក្នុងខែមេសាឆ្នាំ១៩៥៥ សម្តេចសីហនុបានចូលរួមប្រជុំក្នុងសន្និសិទនៅទីក្រុងប៉ង់ឌុងនៅប្រទេសឥណ្ឌូណេស៊ី។ សន្និសិតនេះមានគោលបំណងបង្កើតជាអង្គការនៃប្រទេសមិនចូលរួមក្នុងប្រតិព័ន្ធណាមួយ។ សន្និសិតនេះទៀត បង្កើតឲមានអត្តសញ្ញាណនៃតតិយកប្រទេស (Tiers monde)ក្នុងឆាកអន្តរជាតិ ដែលកើតឡើងពីការរួបរួមនៃប្រទេសទើបនឹងទទួលបានឯករាជ្យ។
-នៅថ្ងៃទី១៦ឧសភាឆ្នាំ១៩៥៥ អាមេរិកាំង និងខ្មែរ ចុះហត្ថលេខាទាក់ទងនឹងជំនួយយោធាសហរដ្ឋអាមេរិក ផ្តល់ឲកម្ពុជា។
-ថ្ងៃទី១៤ធ្នូឆ្នាំ១៩៥៥ ប្រទេសខ្មែរ បានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ។
-ថ្ងៃទី១៣កុម្ភៈឆ្នាំ១៩៥៦ សម្តេចសីហនុយាងទៅធ្វើព្រះរាជទស្សនាកិច្ចជាផ្លូវការ ជាលើកដំបូងនៅប្រទេសចិនកុម្មុយនិស្ត។ រាជទស្សនាកិច្ចនេះ ជាអន្ទាក់កុម្មុយនិស្តទាក់បានសីហនុឲជាប់នៅក្នុងទ្រុងចិន តែក៏ជាលាភរបស់សីហនុដែរ ព្រោះទ្រង់អាចបន្តពង្រឹងនយោបាយផ្តាច់ការនៅក្នុងស្រុកខ្មែរ ដោយសំអាងថាមានចិនកុម្មុយនិស្ត ជាអ្នកគាំទ្រព្រះអង្គលើឆាកអន្តរជាតិ។
-ថ្ងៃទី២មិថុនាឆ្នាំ១៩៥៦ រាជាណាចក្រខ្មែរ និងសាធារណរដ្ឋយៀកណាមខាងត្បូង យល់ស្របគ្នាឲមានការទំនាក់ទំនងតាមផ្លូវទូត។
-ថ្ងៃទី៤វិច្ឆកាឆ្នាំ១៩៥៧ សម្តេចសីហនុ ប្រកាសក្រម ដាក់ប្រទេសខ្មែរជាប្រទេសអព្យាក្រិតក្រមនេះត្រូវបានសមាជជាតិលើកទី៤ យល់ព្រមនៅក្នុងខែមករាឆ្នាំ១៩៥៧។
នៅថ្ងៃទី១៨មិថុនាឆ្នាំ១៩៥៨ មានឧប្បត្តិហេតុយោធា រវាងខ្មែរនិងយួនខាងត្បូងនៅតាមព្រំ

ដែននៃប្រទេសទាំងពីរ។
-ថ្ងៃទី១៨កក្កដាឆ្នាំ១៩៥៨ មានការថ្លែងរួមចិនខ្មែរ ប្រកាសតាំងស្ថានទូតទៅវិញទៅមក រវាងប្រទេសទាំងពីរ ដោយហេតុនេះ ខ្មែរផ្តាច់ទំនាក់ទំនងជាផ្លូវការជាមួយចិនជាតិនិយម(ចិនតៃវ៉ាន់)។
-នៅថ្ងៃទី១៨វិច្ឆកាឆ្នាំ១៩៥៨ ខ្មែរប្រកាសផ្តាច់ទំនាក់ទំនងតាមផ្លូវទូតជាមួយរាជាណាចក្រថៃ។
-នៅក្នុងឆ្នាំ១៩៥៩ សង្គ្រាមនៅប្រទេសយៀកណាម បានផ្ទុះឡើងជាលើកទី២។
-នៅថ្ងៃទី១៨ធ្នូ ឆ្នាំ១៩៦០ ខ្មែរចិន ចុះហត្ថលេខារួមទាក់ទងនឹង"មិត្តភាពចិនខ្មែរ និងមិនឈ្លានពានគ្នាទៅវិញទៅមក។
នៅក្នុងការសាកល្បងសិក្សារបស់យើង នៅពេលក្រោយ យើងនឹងលើកមកពិនិត្យបន្តទៀតនូវសម័យសង្គមរាស្ត្រនិយម ហើយនឹងវិភាគ អំពីការយល់ឃើញរបស់អ្នកឯកទេសបារាំងមួយចំនួន ដែលជាអ្នកគាំទ្រនយោបាយសីហនុ ដោយបានសរសេរការពារ ចលនា"សង្គមរាស្ត្រនិយម"ថាជា"ផ្លូវកណ្តាល"រវាងលទ្ធិប្រជាធិបតេយ្យសេរីនៅបស្ចឹមប្រទេស និងរបបសង្គមនិយម ម៉ាស៊ីសនិយម ដែលគ្រប់ប្រទេសលោកខាងកើតយកវាមកអនុវត្តន៍។

**កំណត់នៃការប្រើពាក្យ:**ប្រជាពលរដ្ឋ(Peuple) ប្រជាជន(Population) ប្រជារាស្ត្រ(Sujets) គតិ(Esprit) ការត្រិះរិះ(Pensée) គំនិត(Idée)។

**ឯកសារនិងសៀវភៅយោង៖**


វិបត្តិកម្ពុជា និពន្ធដោយលោកសៅ.ឆាត;

គុកនយោបាយ និពន្ធដោយប៊ុនចន្ទ ម៉ុល(១៩៧១)។

# ៥

## សម័យឯករាជ្យ

## សម័យសង្គមរាស្ត្រនិយម

## ២.រយៈពេលពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៦

### ២.១.សង្គមរាស្ត្រនិយម អាចចាត់ទុកជាផ្លូវកណ្ដាលបានដែរឬទេ?

ជនជាតិបារាំងមួយក្រុម១ នាំគ្នាសរសេរសរសើរ ដោយយកលក្ខន្តិកៈខ្លួនជាសាស្ត្រាចារ្យ ជាអ្នកជំនាញ ដើម្បីអន្ទងអ្នកចេះដឹកខ្មែរឲជឿលើជាតុចលនាសង្គមរាស្ត្រនិយមថា ជាប្រពន្ធលទ្ធិប្រជាធិបតេយ្យដែលមិនធ្លាប់មានមួយក្នុងប្រពន្ធរបបនយោបាយ។ ជាប្រពន្ធនយោបាយបែបរបបគ្រប់គ្រងអាស្រ័យរដ្ឋសភាជា**តន្តី**(classique) តែនៅក្នុងរបបនេះ មានលាយ រូបមន្តថ្មីមួយ គឺ**លទ្ធិប្រជាធិបតេយ្យអឌ្ឍដោយចំពោះ**២ គឺថា:"ខ្មែរម្នាក់ៗ អាចមានសិទ្ធិ សរសេរ**បដ្ឋនាលិខិត**(pétition)ផ្ញើចំពោះអាជ្ញធរ ដើម្បីប្ដឹងសុំ ឬថ្លែងមតិ ឲយកបញ្ហាអត្ថប្រយោជន៍របស់ខ្លួន ឬក្រុម មកពិនិត្យ រកការពិត(មាត្រា១៤នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦)ជូនខ្លួន។ ម្យ៉ាងមួយទៀត ប្រជាពលរដ្ឋអាចមានសិទ្ធិ អាចហូតងារតំណាងរាស្ត្រនៃ សភាជាតិ ឬសភាខេត្ត ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ ក្នុងនោះ មានបង្កើតស្ថាប័តថ្មីមួយ គឺសភាប្រជាជន៣ឬសភាខេត្ត នៅតាមខេត្តនិមួយៗ។

សភាប្រជាជននេះ ជាអង្គការ បោះឆ្នោតអនុម័តថវិការខេត្តនិងឃុំ។ គោលបំណងរបស់ស្ដេចសីហនុ គឺបង្កើតដើម្បីបញ្ឆោះ(inciter)ប្រជាពលរដ្ឋឲចូលរួមគិតពីបញ្ហាសំខាន់ៗរបស់ជាតិ ដូចយ៉ាងឲយោបលទាក់ទង គ្រប់ការចុះសិទ្ធិសញ្ញាជាមួយបរទេស ថវិការជាតិប្រចាំឆ្នាំ គម្រោងការខ្ចីលុយរបស់រាជរដ្ឋាភិបាល អនុម័តគណនីរដ្ឋបាល និងជូនជាវិស័យមតិចំពោះរដ្ឋសភា និងរដ្ឋាភិបាលទាក់ទងនឹងកិច្ចការសាធារណៈ។

ធាតុពិសេសមួយទៀតរបស់សភាប្រជាជន គឺមន្ត្រីរាជការខេត្ត ជាអ្នកទទួលខុសត្រូវចំពោះមុខខ្លួនស្របតាមច្បាប់រដ្ឋធម្មនុញ្ញ ដូច្នេះសភានេះអាចសរសេរលិខិត សួរផ្ទាល់ជាសំណួរចំពោះ

អភិបាលខេត្ត ឲ្យឆ្លើយពន្យល់ដល់ខ្លួននូវគ្រប់កិច្ចការទាក់ទងនឹងកិច្ចការរដ្ឋបាលជាទូទៅ។ នៅក្នុងបុព្វសិទ្ធិនេះ សភាប្រជាជន អាចសុំស្នើឲដកដំណែងអភិបាលខេត្ត ចាងហ្វាងសាលាដំបូង ឲផ្លាស់មន្ត្រីរាជការណាម្នាក់ចេញពីក្រុមរាជការ ឬធ្វើការព្រមាន តាមការបោះឆ្នោតដោយយកសម្លេងភាគច្រើន៣/៤នៃចំនួនសមាជិកទាំងអស់ ជាបានការ ហើយស្នើជាបន្ទាន់ទៅក្រុមព្រឹក្សាព្រះរាជាណាចក្រ សុំឲសំរេចយល់ព្រម តាមការបោះឆ្នោត ដោយយកសម្លេងភាគច្រើនដាច់ខាត ជាបានការ។

លទ្ធិប្រជាធិបតេយ្យអឌ្ឍដោយចំពោះ ជាសាមាយោគនៃធាតុជាច្រើនដែលមាននៅក្នុងរបបចិនកុម្មុយនិស្ត និងប្រទេសយោង៉ោសស្លាវី ជារបបដឹកនាំ ជា**ការណ៍**(pragmatique)មានគោលការណ៍**បិតានិយម**(paternalisme)មានមនោគមវិជ្ជាជាទិដ្ឋិ(dogme) បង្កើតឡើងសំរាប់បំរើផលប្រយោជន៍បុគ្គលសីហនុ។

## អ្វីដែលជាសីហនុនិយម?

យើងបើកវង់ក្រចក ធ្វើវិភាគនូវសីហនុនិយម ដើម្បីស្រួលបន្តការសិក្សារបស់យើងទាក់ទងនឹងសង្គមរាស្ត្រនិយម។  សួរថា តើសីហនុនិយម ជាមនោគមវិជ្ជានយោបាយឬទេ?

សម្តេចសីហនុ តែងតែមានអំនួនជានិច្ច ថា« *ទោះបីជនណាម្នាក់ទុកព្រះអង្គជា ព្រះអង្គម្ចាស់ក្រហម មិនអាចដឹងចិត្តជាមុនបាន ទាល់គំនិត ដូរចិត្តមិនឈប់ និងសាវ៉ា តែព្រះអង្គនេះឯង ជាអ្នករក្សានគរខ្មែរ ឲរស់ក្នុងសន្តិភាព ជាងដប់ឆ្នាំរួចមកហើយ និងបានធ្វើឲប្រជាពលរដ្ឋ រួចចាកពីភាពក្រីក្រ ហើយទោះបីមានគេស្អប់ព្រះអង្គយ៉ាងណាក៏ដោយ តែព្រះអង្គមានប្រជាប្រិយភាពពិសេសក្នុងចំណោមប្រជាពលរដ្ឋ៤*»។

បើយើងយកសំដីសម្តេចសីហនុខាងលើនេះមកពិនិត្យ យើងឃើញមានគំនិតបី ដែលទ្រង់លើកយកវា មកធ្វើជាយោង នៃជោគជ័យនយោបាយរបស់ទ្រង់គឺ:**សន្តិភាព ការអភិវឌ្ឍ** និង **ប្រជាប្រិយភាព**។  វត្ថុធាតុមួយទៀត ដែលទ្រង់លើកយកវាមកធ្វើជា សេះសឹក របស់ទ្រង់លើឆាកអន្តរជាតិ គឺ **អព្យាក្រឹតភាព**។  អព្យាក្រឹតភាពនៃកម្ពុជានេះឯង ដែលទ្រង់យកវាមកធ្វើជាប្រធាននៃនិក្ខេបបទសំរាប់ថ្នាក់បណ្ឌិតរបស់ព្រះអង្គ ហើយទ្រង់យកវា មកពន្យល់ បែបសន្និសិទ នៅមុខគណ:មេប្រយោគ នៅសាកលវិទ្យាល័យច្បាប់នៅទីក្រុងប៉ារីស នាថ្ងៃទី២៩

មិថុនាឆ្នាំ១៩៦៤។

វិធីសាស្ត្ររបស់សីហនុនេះ គឺជារូបមន្តដែលគេច្រើនយកមកនិយាយថា:«ជ័យជំនះនៅទីបញ្ចប់គឺជាការបង្ហាញនូវភាពត្រឹមត្រូវនៃមយោបាយដែលបានយកមកប្រើ»។ មានន័យថា សីហនុនិយាយពីជោគជ័យរបស់ខ្លួន ដោយមិនលើកមកបង្ហាញថា ជោគជ័យនេះ ទ្រង់ទទួលបានបែបណានោះឡើយ។

នៅសម័យសង្គមរាស្ត្រនិយម បើគេសួរសំណួរទៅអ្នកសីហនុនិយម ថាអ្វីទៅដែលជា«សីហនុនិយមនោះ?»ចម្លើយគឺមានប្រាំចំណុច:**បិតាភាព សន្តិភាព ការអភិវឌ្ឍ ប្រជាប្រិយភាព** និង **អព្យាក្រិតភាព**។ តើពួកអ្នកសីហនុនិយម គេនាំគ្នាការពារចំណុចទាំងប្រាំនេះបែបណា?

**បិតាភាព** ព្រោះគេមានជំនឿផ្ទាប់មុខថា សម្តេចឪរបស់គេ ស្រឡាញ់រាស្ត្រខ្មែរដូចជាកូនចៅផ្ទាល់របស់ព្រះអង្គ។

**សន្តិភាព** ព្រោះនយោបាយរបស់សម្តេចឪគេ បានធ្វើឲស្រុកខ្មែរក្លាយជាកោះសន្តិភាពពិតដែលជាកត្តានាំឲប្រជារាស្ត្ររស់មានសុភមង្គល និងការរួបរួមជាតិខ្មែរ។

**ការអភិវឌ្ឍ** សន្តិភាពនេះឯង ដែលអាចឲសម្តេចឪគេ ធ្វើនយោបាយអភិវឌ្ឍន៍ជាតិ លប់បំបាត់នូវសេចក្តីក្រីក្ររបស់រាស្ត្រខ្មែរបាន នយោបាយអប់រំជាតិ ដូចយ៉ាង អប់រំមូលដ្ឋានដើម្បីលប់បំបាត់នូវភាពមិនចេះអក្សរ;បង្កើតនៅតាមជនបទ ឲមានសាលាបឋមសិក្សា; បង្កើតតាមស្រុក ខេត្ត ឲមានអនុវិទ្យាល័យ និងវិទ្យាល័យ;ក្នុងផ្នែកឧត្តមសិក្សា បង្កើតមហាវិទ្យាល័យគ្រប់វិស័យសិក្សា ដូចយ៉ាង អក្សរសាស្ត្រ វិទ្យាសាស្ត្រ ច្បាប់ វិជ្ជាពេទ្យ ឱសថវិជ្ជា បច្ចេកវិជ្ជា វិចិត្រសិល្បៈនិងអាជីវៈ វិជ្ជាគ្រូ វិជ្ជាកសិកម្ម វិជ្ជាអ្នកបណ្តុះនិងរក្សាព្រៃ វិជ្ជាបសុពេទ្យ វិជ្ជាសាធារណការ វិជ្ជាភ្លេងនិងសំនៀង វិជ្ជាល្ខោន។ វិជ្ជាទាំងឡាយនេះ ជាកម្រងចំណេះជាតិខ្មែរថ្មី នៅក្រោមការដឹកនាំរបស់សម្តេចឪ បិតាឯករាជ្យជាតិ និងសិក្សាធិការជាតិ។

**ប្រជាប្រិយភាព** ជាអំណរគុណរបស់ប្រជារាស្ត្រចំពោះសម្តេចឪ ដែលព្រះអង្គថ្វាយនូវកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងប្រាជ្ញា របស់ព្រះអង្គ ឥតខ្លាចនឿយហត់ ជាកម្លាំងកសាងឲជាតិរុងរឿងគ្រប់ទិវារាត្រី ដើម្បីរក្សាឯករាជ្យជាតិ និងបូរណភាពទឹកដី ចំពោះមុខប្រទេសជិនខាង

ដែលគេចិញ្ចឹមហិច្ឆិតារាប់ពាន់ឆ្នាំ ដើម្បីលេបស្រុកខ្មែរ។

**អព្យាក្រិតភាព** ដូចប្រទេសស្វីស ជាផ្លូវតែមួយគត់សំរាប់រក្សាស្រុកខ្មែរ ឲរស់ក្នុងសន្តិភាពនៅក្នុងសង្គ្រាមនៅយៀកណាម រវាងយួនខាងជើង មានជំនួយពីលោកកុម្មុយនិស្ត និងខាងត្បូងមានវត្តមានយោធាអាមេរិកកាំងនៅក្នុងស្រុកយួនខាងត្បូងជាបង្អែក។ ការជ្រើសរើសអង្គការនៃប្រទេសមិនចូលក្នុងប្រតិព័ន្ធ(bloc)ណាមួយ ជាការបញ្ជាក់បន្ថែមទៀត នូវការប្តេជ្ញាចិត្តរបស់សម្តេចឪ យកអព្យាក្តិតភាពជាខែលសំរាប់ការពារឯករាជ្យជាតិ និងសន្តិភាពនៃប្រជាជាតិខ្មែរ។

ចំពោះអ្នកសីហនុនិយម តម្លៃល្អលុបទាំងប្រាំវត្ថុធាតុនេះ ដែលជាកម្រកផូផង់នៃសីហនុនិយម ត្រូវការចំបាច់មានបាទពីរ ដែលជាអំណោយព្រះ ជូនដល់ប្រជាជាតិខ្មែរ គឺរាជបល្ល័ង្គនិងពុទ្ធសាសនា ដែលជាគូររស់ស្លាប់រួមជាមួយគ្នា ដើម្បីសុខដុមក្នុងសង្គមជាតិខ្មែរ។

យើងនឹងលើកយកទស្សនៈសីហនុនិយម វិនិច្ឆ័យដោយពួកអ្នកសីហនុនិយម មកពិនិត្យជាបន្តបន្ទាប់ក្នុងការសិក្សារបស់យើង ថាតើទស្សនៈនេះ មានការពិតដែរឬទេ?

យើងបិទវង់ក្រចក ហើយវិលត្រឡប់មកពិនិត្យបន្ត ថាតើសង្គមរាស្ត្រនិយម ជាផ្លូវនយោបាយកណ្តាលពិតមែនដែរឬ?

តើចលនាសង្គមរាស្ត្រនិយម ជាចលនាមួយថិតនៅលើផ្លូវលទ្ធិប្រជាធិបតេយ្យសេរីដែរឬទេ? ហើយមានដំណើរកើនឡើងជាលំដាប់ពីដំណាក់មួយទៅដំណាក់មួយទៀតនៅក្នុងដំណើរជាវិវឌ្ឍន៍ធម្មតានៃលទ្ធិប្រជាធិបតេយ្យសេរី ឬជាការដូរដាច់ស្រឡះ តាមដំណើរបដិវត្តន៍?

ដូចយើងបានលើកមកបង្ហាញខាងលើរួចមកហើយ ថាការកកើតសង្គមរាស្ត្រនិយម គឺវាមិនពិត ជាដំណើថ្មី តាមគន្លងនៃការវិវឌ្ឍន៍ជាធម្មតានៃលទ្ធិប្រជាធិបតេយ្យសេរី ក៏វាមិនពិតដែរជាដំណើរបដិវត្តន៍ ព្រោះការកកើតនេះ វាចេញពីរដ្ឋប្រហាររដ្ឋធម្មនុញ្ញ ដូច្នេះតាមធម្មជាតិរបស់វា គឺវាពុំអាចថិតនៅក្នុងភូមិជាមួយនឹងលទ្ធិប្រជាធិបតេយ្យសេរីបាននោះឡើយ ដោយហេតុនេះ វាពុំមែនជាផ្លូវកណ្តាលនៅក្នុងភូមិតែមួយនោះបានដែរ។ ចលនាសង្គមរាស្ត្រនិយមវាគ្មានមានវត្ថុធាតុអ្វី ដែលយើងអាចប្រដូចបានទៅនឹងលទ្ធិប្រជាធិបតេយ្យសេរីបាននោះទេទោះបីសីហនុ ខំលាបម្សៅពណ៍ផ្កាឈូកលើមុខវាក៏ដោយ ព្រោះលទ្ធិចលនានេះ គឺសីហនុនាំចូល

ពីចិនកុម្មុយនិស្ត ជាភាគរាយ មកផ្គុំនៅក្នុងស្រុកខ្មែរ លាយជាមួយប្រពៃណីនិយម៥នៃប្រជារាស្ត្រឆាប់ជឿ មិនមែនដើម្បីបំពេញចិត្តរាស្ត្រនោះទេ គឺសំរាប់បំរើផលប្រយោជន៍ព្រះអង្គនៅក្នុងគតិឯកធិបតេយ្យ(individualisme)។ យើងអាចទុកចលនាសង្គមរាស្ត្រនិយម ជាកូនឥតខាន់ស្លា នៃលទ្ធិកុម្មុយនិស្តនិយមចិនក្រហម កើតឡើងជាកូនចង្រៃសំរាប់បំផ្លាញសង្គមខ្មែរ។ «**លទ្ធិប្រជាធិបតេយ្យឲរាស្ត្រស្រួលយល់**»ដែលសម្តេចសិហនុយកវា មកធ្វើជាពាក្យស្លោក រិតតែបង្កើតភាពស្មុកស្មាញក្នុងគតិរាស្ត្រថែមទៅទៀត ព្រោះក្នុងលទ្ធិនេះ មានកើតចំនួនកាន់តែច្រើនឡើង នូវពួកអ្នកនយោបាយចិញ្ចឹមឆ្នាំងបាយ បោករាស្ត្រ ដែលខ្មែរឲឈ្មោះថា« អ្នកនយោបោក»នោះឯង។

សភាប្រជាជនខេត្តក្តី សភាជាតិក្តី គ្មានមានការទំនាទំនងដោយចំពោះជាមួយប្រជាពលរដ្ឋ ព្រោះអ្នកតំណាងរាស្ត្រថ្នាក់ជាតិ និងខេត្ត ជាតំណាងសង្គមរាស្ត្រនិយម ព្រោះចលនានេះឯងជាអ្នកជ្រើសរើសបេក្ខជនតំណាងរាស្ត្រ ក្នុងចំណោសមជិកសង្គមរាស្ត្រនិយម។

ការហាមដាច់ខាតមិនឲមានគណបក្សនយោបាយដទៃទៀត គឺជាការបង្ខំឲមានតែ«ការត្រិះរិះតែមួយគត់»ក្នុងប្រព័ន្ធនយោបាយខ្មែរ ឧបមា អ្វីដែលសីហនុយល់ថាត្រូវ គឺត្រូវរាស្ត្រ និង វរជន ទាំងបព្វជិត និងក្រហស្ថ នាំគ្នាទុកជាធម៌ព្រះ ធ្វើបដិបត្តិបូជា៦ ប្រព័ន្ធនៃការត្រិះរិះតែមួយគត់នេះ គឺជាបំណងសីហនុ បំបាត់កុំឲមានវិស័យមតិសាធារណៈ និងប្រជ្ញានៃវរជនខ្មែរៈ «ព្រះបិតាជាអ្នកថែរក្សាកូនចៅ ដូច្នេះព្រះបិតាជាអ្នកគិត»។ ការប្រមូលផ្តុំវរជនបញ្ញាវន្តឲនៅជុំវិញបិតាឯករាជ្យជាតិ ឬអ្នកដឹកនាំនេះ គឺជាទម្លាប់របស់សង្គមសក្តិភូមិ ដែលសម្តេចសីហនុកាយចេញពីក្នុងប្រពៃណីនិយមខ្មែរ យកមកអនុវត្តន៍ ដើម្បីពង្រឹងរាជាអំណាច ហេតុនេះឯងបានជាវរជនបញ្ញាវន្តលែងមានអនុភាព ដើម្បីជួយកសាងពិតប្រាកដ នូវការធ្វើបដិវត្តិសេដ្ឋកិច្ច និងសង្គមកិច្ច ឲបានជឿនលឿនឆាប់រហ័យក្រោយពីស្រុកខ្មែរបានក្លាយជាប្រទេសឯករាជ្យមក។ សម្តេចសីហនុ ទ្រង់តែងតែនិយាយថា ទ្រង់មិនមែនជាសាស្ត្រាចារ្យសាកលវិទ្យាល័យទេ តែជាកម្មករនៃកិច្ចការរដ្ឋ ធ្លាប់កាន់ដំណែងជាច្រើន មហាក្សត្រ នាយករដ្ឋមន្ត្រី ប្រមុខរដ្ឋ ដែលសុទ្ធជាមុខដំណែងពិបាក ហើយមិនច្បាស់ជាអាចទទួលសោធននិវត្តន៍ទៀតផង តែព្រះអង្គបានទទួលជោគជ័យក្នុងបេសកកម្មបំរើជាតិពិត។ តែយើងដឹងថាសញ្ញាណនៃវិជ័យនេះ វាមិនមានលក្ខណៈដាច់ខាននោះឡើយ ព្រោះគេឃើញមានពិតខ្លះ ដូច

យ៉ាងភាពប្រសើរក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ ប៉ុន្តែសីហនុ ទ្រង់លុបបំបាត់សេរីភាពនយោបាយ លុបបំបាត់តម្លៃនៃបុគ្គល ដែលជាគ្រឹះនៃលទ្ធិប្រជាធិបតេយ្យសេរី៖ឧបមា គេធ្វើទ្រុងមាស សំរាប់ដាក់សេកដ៏ល្អតែជាបក្សីឥតអណ្តាតនោះឯង។

គួរលើកមកពិចារណាបន្តិចដែរអំពីសេរីភាពនយោបាយ ព្រោះសេរីភាពនេះ វាមានកើតឡើងពីការតស៊ូដើម្បីឲទទួលស្គាល់តម្លៃ ទៅវិញទៅមក រវាងមនុស្សលោកនិងមនុស្សលោក។ ជាការតស៊ូតាំងពីមានមនុស្សលោករស់ក្នុងលោកនេះម្លេះ ដែលគេឃើញមានស្នាមនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ។ ការតស៊ូនេះទៀត ជាសញ្ញាសំគាល់នៃភាពខុសគ្នាស្រឡះរបស់មនុស្សលោកនិងសត្វ គឺក្រៅពីសេចក្តីត្រូវការអាហារ ជំរក សំរាប់សេចក្តីត្រូវការរបស់ខ្លួនប្រាណ ដែលមនុស្សលោក និងសត្វ ត្រូវការដូចគ្នា តែមនុស្សលោកខុសសត្វត្រង់មនុស្សមានសេចក្តីត្រូវការផ្សេងមួយទៀត គឺបំណងចង់ឲមនុស្សដូចគ្នាទទួលស្គាល់តម្លៃរបស់ខ្លួន។ ដើមឡើយជាការតស៊ូហឹង្សា បន្តបន្ទាប់មក មានការវិវឌ្ឍន៍បន្តិចម្តងៗទៅជាការតស៊ូធ្វើឲមានអារ្យធម៌ គឺជាការតស៊ូមានច្បាប់ជាអាជ្ញាកណ្តាល ដែលប្រជាជនក្នុងសង្គមមួយជាអ្នកបង្កើតវាឡើងដោយខ្លួនឯង ក្នុងគោលការណ៍នៃជនាធិបតី[៧]ដើម្បីអាណាប្រយោជន៍។ ការនេះហើយ ដែលគេហៅថា«លទ្ធិប្រជាធិបតេត្យសេរី» ជាស្នាដៃនៃមនុស្សជាតិដ៏ថ្លៃថ្លា និងថ្លៃថ្នូរ។ ដូច្នេះការលុបបំបាត់សេរីភាពនយោបាយ និងតម្លៃបុគ្គល ដោយសីហនុ ជាអំពើប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យសេរីផង និងប្រឆាំងនឹងមនុស្សជាតិផង។

## ទស្សនៈនៃអំណាចរបស់សង្គមរាស្ត្រនិយម

រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ក្តី ឆ្នាំ១៩៥៦ក្តី ពិតជាមានវត្តុធាតុលទ្ធិប្រជាធិបតេយ្យ សំរាប់បំរើសុផាតប្រយោជន៍ របស់ប្រជាពលរដ្ឋ មានការទទួលខុសត្រូវពិត នៅចំពោះមុខប្រជាពលរដ្ឋ តាមការបោះឆ្នោត។ ប៉ុន្តែ សម្តេចសីហនុ បង្វែរវាទៅរក«ការគោរពនៃឥស្សរជន[៨]»គឺទុកបុគ្គលព្រះអង្គជាទេវតាផង ជាបិតាផង ដែលគេឃើញមាននៅក្នុងទ្រឹស្តីទេវរាជ្យក្នុងសម័យអង្គរ៖ «មេដឹកនាំ ជាមគ្គុទេសក៏ផង ជាព្រះបាទធម្មិកផង ដឹកនាំប្រជាពលរដ្ឋទៅរកសេក្តីចម្រើននុះឯងហើយ ដែលគេមើលឃើញអំណាចរបស់សម្តេចសីហនុ ខំស្អិតស្អាងខ្លួន ឲមានភាវរូប ជាកិត្តិគុណ(auréole)ផង ជាអនុភាពដ៏អស្ចារ្យផង ចំពោះប្រជារាស្ត្រ។

យោងទៅលើការវិភាគខាងលើនេះ យើងសន្និដ្ឋានបានថា ចលនាសង្គមនិយម មិនអាចចាត់ទុកជាផ្លូវកណ្តាលបាននោះឡើយ។ ការពិតចលនានេះ គឺថិតនៅលើមាគ៌ាលទ្ធិផ្តាច់ការសុទ្ធសាត នុះឯងហើយ គេអាចចាត់ទុកសម្តេចសីហនុជាជនផ្តាច់ការ ពាក់អាវចិនកុម្មុយនិស្តស្លៀកសំពត់ក្បិតខ្មែរ មើលយូរគឺដូចអាយ៉ងល្ខោនចិន(ហិ)តែម្តង។

## ២.២.ព្រឹត្តិការណ៍ក្នុងរយៈពេលឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៦

ព្រះមហាក្សត្រសុរាម្រិត ព្រះអង្គសុគតនៅថ្ងៃទី៣មេសាឆ្នាំ១៩៦០ ក្នុងព្រះជន្ម៦៤ឆ្នាំ។ សម្តេចសីហនុ ទ្រង់មិនព្រមត្រឡប់មកទទួលរាជសម្បត្តិបន្តពីបិតាទ្រង់ ដោយខ្លាចចាញ់សបថ ដែលបានស្បថ បន្ទាប់ពីព្រះអង្គដាក់រាជ្យថ្វាយបិត ថាព្រះអង្គមិនវិលមកសោយរាជសម្បត្តិវិញជាដាច់ខាត។ ក្នុងកបិចិត្ត(caprice)នេះ សម្តេចសីហនុបានបង្កើតឲមានវិបត្តរដ្ឋធម្មនុញ្ញ ដោយយកអំណាចព្រះមកសង្កត់ មិនឲតែងតាំងមហាក្សត្រថ្មីបន្តរាជសម្បត្តិពីបិតាព្រះអង្គ។ ទ្រង់បង្ខំឲរដ្ឋសភា ធ្វើច្បាប់ពិសេស(៤មេសា) ដើម្បីបង្កើតក្រុមព្រឹក្សារាជានុសិទ្ធិ មានសមាជិកបីរូប ព្រះអង្គម្ចាស់សីសុវត្ថិ.មុនីរ៉េត៩ ជាប្រធាន លោកទ្រឿង.កាង និងលោកជូ.ពឿង ជាសមាជិក ហើយមានសមាជិកជំនួសពីររូបទៀត គឺលោកទេព.ផន និងលោកពិទូ.ដឺម៉ុងតេរ៉ូ។

ពួកអ្នកសីហនុនិយម មាននិន្នាការឆ្វេងនិយម នាំគ្នាយកបែបបទ(forme)ថ្មី នៃរបបរាជានិយម គ្មានមហាហាក្សត្រនេះ មកបកស្រាយបែបបញ្ឆោរ ថាជារបបរាជានិយមដ៏បរិសុទ្ធ ព្រោះមិនយកមហាក្សត្រជាវត្ថុធាតុសំខាន់ តែយករាជបល្ល័ង្កជាគ្រិះនៃរបប ព្រោះរាជបល្ល័ង្កជាតំណាងនៃភ្នំមេរុ ដែលពួកព្រាហ្មណ៍គេទុកជាភ្នំសក្តិសិទ្ធិក្នុងសាកលលោកនេះ។ ហេតុនេះឯងបានជាគេប្រើពាក្យក្នុងបាវចនានៅជំនាន់នោះថា«ជាតិ សាសនា និងរាជបល្ល័ង្ក»។ ទ្រឹស្តីនេះវាត្រូវនឹងអារម្មណ៍របស់សម្តេចសីហនុណាស់ ដូច្នេះឯង ព្រះអង្គត្រូវបង្កើតងារអ្វីមួយសំរាប់ព្រះអង្គ។ បំណងនេះ វាមិនជាទុក្ករៈ(ពិបាកធ្វើ)ចំពោះព្រះអង្គនោះឡើយ ព្រោះនៅពេលនោះ អ្វីដែលព្រះអង្គចង់បាន វាគ្រាន់តែព្រះអង្គហានិយាយចេញទៅ គឺពិតជាបានសំរេចដូចបំណងភ្លាម ព្រោះព្រះអង្គមានមាត់ទិព្វទៅហើយ ដូចពាក្យគេនិយាយថាៈ«បំណងព្រះអង្គគឺជាបញ្ញាតិច្បាប់»។

គួរយើងដឹងដែរអំពីការនិទានខ្លីៗមួយ សម្តេចសីហនុខឹងនឹងលោកខៀវ.សំផន និយាយជេរ ចោលតាមតែទម្លាប់ទ្រង់ នៅមុខលោកគួ.រួន(រដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ)ថា«អាហ្នឹង!.គួរតែ វៃប្រសាតខោ ប្រដៅវាម្តង»គួ.រុន បរិវារដ៏ភក្តីព្រះករុណា យកពាក្យនេះមកធ្វើបញ្ញាតិ បង្គាប់ ប៉ូលិស ឲវៃប្រសាតខោខៀវ.សំផន ទាំងថ្ងៃត្រង់មែន។

នៅថ្ងៃទី១៧មិថុនាឆ្នាំ១៩៦០ សភាជាតិ ដែលជាសភាប្រថាប់ត្រា នាំគ្នាធ្វើច្បាប់ពិសេសមួយ តែងតាំងសម្តេចសីហនុជាប្រមុខរដ្ឋអស់មួយជាជីវិត។  តំណែងនេះគឺជាលុបបំបាត់របបរាជា និយមដោយសីហនុខ្លួនឯង ទោះបីសីហនុ បំភាន់ប្រជាពលរដ្ឋ តាមការតែងតាំងមាតាព្រះ អង្គជាក្សត្រីទេពារក្ស(gardienne)នៃរាជបល្ល័ង្កក៏ដោយ ក៏វាមិនអាចលាក់នូវមហិច្ឆិតាគ្មានកំ រិត ដើម្បីអំណាចនោះបានទេះ លុបបំបាត់មហាក្សត្រដែលជាប្រមុខរដ្ឋ តែបង្កើតដំណែង ប្រមុខរដ្ឋអស់មួយជីវិត ឲស្របច្បាប់រដ្ឋធម្មនុញ្ញ ហើយមានលក្ខណ:ជាតំណែងអចិន្ត្រៃយ គឺ ជាការធ្វើរដ្ឋប្រហាររដ្ឋធម្មនុញ្ញម្តងទៀត ដើម្បីរំលាយរបបរាជានិយមចោលនោះឯង។  តែ ការរំលាយនេះទៀត ជាទង្វើចំឡែកណាស់ គឺសីហនុនៅរក្សាជានិច្ចនូវ ឯកសិទ្ធិ និងបុព្វសិទ្ធិ មហាក្សត្រ ក្នុងដំណែងប្រមុខរដ្ឋទាំងអស់ ដូច្នេះព្រះអង្គក្លាយជាប្រមុខរដ្ឋផង ជាប្រមុខ អំណាចនយោបាយផង សួរថា តើលក្ខណ:បែបនេះ គេហៅវាថាអ្វីទៅ?.មិនមែនជាជនផ្តាច់ ការនោះឬ?

របបដែលសីហនុបង្ខំឲពលរដ្ឋខ្មែរយកមកប្រតិបត្តិនៅពេលនោះ គឺជារបប«***វិជ័យនៃអវិជ្ជា***» និង«***ល្ងង់ខ្លៅដាច់អហង្ការ***»ជាប្រមុខរដ្ឋ មានមារយាទជាឪត្លានភាព(vulgaire)គិតតែពីថត កុន បង្កើតព្រឹត្តិប័ត្រ«ផ្សេងៗ»ចុះផ្សាយរូបថតខុសសីលធម៍(érotique)ថោកទាបប្រមាថ មើលងាយតម្លៃប្រពៃណីខ្មែរ របបនេះ មានឈ្មោះថា«សង្គមរាស្ត្រនិយម» ដែលជារបបកើត ចេញពីសេពមេថុនកម្ម រវាងរបប**សិទ្ធិអំណាច**(autoritaire)និងរបប**សមស្ត**(totalitaire)។

ដើម្បីបំភាន់រាស្ត្រខ្មែរ ថាព្រះអង្គជាអ្នកសង្គមរាស្ត្រនិយមលេខ១ សម្តេចសីហនុធ្វើសង្គមម្ហូប និយកម្ម យកលំអានចិនកុម្មុយនិស្តជាគ្រិះនយោបាយ យកគំនិតកំណែទម្រង់សេដ្ឋកិច្ចអ្នក ឆ្វេងនិយមខ្មែរមកធ្វើជាមធ្យោបាយឧបសាធន(accessoire)យកប្រជាភិថុតិជាឧបករណ៍នៃ ការឃោសនា ទាំងអស់នេះ គឺក្នុងគោលបំណងតែមួយគឺ"អំណាចអញសីហនុ"។  គួររំលឹកបន្តិច

ដែរថាក្នុងចន្លោះឆ្នាំ១៩៥៦ ១៩៥៧ សម្តេចសីហនុ បានអនុញ្ញាតឲរាជរដ្ឋាភិបាលដឹកនាំដោយលោកសាន.យុន យកគំនិតពួកអ្នកជឿនលឿនមកសាកល្បងអនុវត្តិ គំនិតនោះមានចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រនៃសមាគមន៍សហភាពនៃនិស្សិតខ្មែរ(U.E.K)នៅពេលនោះលោកខៀវ.សំផនជាប្រធាន ហើយលោកតែងតែផ្ញើថ្វាយសម្តេចសីហនុគ្រប់លេខជានិច្ចៈការប៉ុនប៉ងរបស់រាជរដ្ឋាភិបាលសាន.យុន គឺយកផែនការកសិកម្មបែបកុម្មុយនិស្ត និងធ្វើទំនើមកម្មនៃរចនាសម្ព័ន ក្នុងវិស័យសិប្បកម្ម និងការកកើតជាដំបូងនៃមូលធន(précapitaliste)ក្នុងវិស័យសេដ្ឋកិច្ច ឧស្សាហកម្មតូចៗជាចាំបាច់។ ក្រោយមក គេឃើញលោកខៀវ.សំផន យកបន្ទាត់គំនិតនេះមកធ្វើអធិប្បាយយ៉ាងក្បោះក្បាយនៅក្នុងនិក្ខេបបទរបស់លោកនៅក្នុងឆ្នាំ១៩៥៩១០។ តែគំនិតនេះ គេធ្លាប់បានឃើញវានៅក្នុងសៀវភៅមួយ មានចំណងជើងថាៈបញ្ហាសេដ្ឋកិច្ច របស់សង្គមនិយមនៅសហភាពសូវៀត(១៩៥២) និពន្ធដោយលោកស្តា.លីនដែលអ្នកឆ្វេងនិយម នៅជំនាន់នោះ យកវាមកអាន ហើយទុកជាទិដ្ឋិ(dogme)សំរាប់គោរព។

### សកម្មភាពយោបាយនៅក្នុងប្រទេសៈ

នៅក្នុងឆ្នាំ១៩៦០ សម្តេចសីហនុ ដាក់ក្នុងរបៀបវិរៈសំរាប់ជូនសមាជជាតិលើកទី៩និងទី១០៨ពិនិត្យជាលើកដំបូងលើផែនការប្រាំឆ្នាំរបស់សង្គមរាស្ត្រនិយម។ ជាលើកដំបូងដែរ សីហនុយកសេដ្ឋកិច្ចសង្គមនិយមមកអនុវត្តន៍ជាផ្លូវការក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

នៅថ្ងៃទី១៨ធ្នូឆ្នាំ១៩៦១ សម្តេចសីហនុបានបង្កើតគណកម្មាធិការប្រឆាំងនឹងអំពើពុករលួយដែលជាជម្ងឺរាំរ៉ៃរបស់រដ្ឋបាលខ្មែរ។ ដូចធ្លាប់បានជំរាបពីខាងលើកមុនមកហើយ ថារាជក្រមការនៅស្រុកខ្មែរ ជាវណ្ណៈមួយ មានបុព្វសិទ្ធិ មានអំណាចខ្លាំងក្លាណាស់លើប្រជារាស្ត្រ មិនត្រឹមតែជាវណ្ណៈនៃអំណាច អង្គការនេះ ជាមន្ទីរជាតិសំរាប់រកស៊ីឲមានបានយ៉ាងឆាប់រហ័ស។ អ្វីដែលជាកិច្ចការរាជការ ពួកមន្ត្រី គាត់នាំគ្នាយកទៅលក់ដូរដូចជាទំនិញ បើចង់បានកន្លែងខ្លាញ់ ត្រូវមានលុយទិញ ទើបអាចទទួលដំណែងនោះបានៈអ្នកធំស៊ីតាមធំ អ្នកតូចស៊ីតាមតូចព្រោះអំពើពុករលួយ វាក្លាយជាវប្បធម៍ជាតិ។ អនានុភាពនៅចំពោះមុខបញ្ហានេះ ខ្មែរយើងនៅសល់តែការលួងចិត្តខ្លួនឯងថា ជម្ងឺត្រាំត្រែងនេះ វាមាននៅពេញពិភព

លោក ឯចំណែកអ្នកសីហនុនិយម នាំគ្នាត្អូញត្អែរអាណិតព្រះករុណារបស់គេ ថា សម្តេចព្រះអង្គខំប្រយុទ្ធបំបាត់អំពើរពុករលួយខ្លាំងណាស់ដែរ តែព្រះអង្គតែម្នាក់ឯង គ្មានជំនួយសោះពីសំណាក់មន្ត្រី គ្មានអ្នកណាហ៊ានប្តឹងបើកមុខមន្ត្រីពុករលួយ តើធ្វើដូចម្តេចទៅនឹងអាចឲវិធានការទ្រង់ មានប្រសិទ្ធិភាពកើត?.ក្នុងបញ្ហាពុករលួយ ខ្មែរយើងមានវិស័យមតិផ្សេងៗគ្នា តែសុទ្ធតែមានឆន្ទះល្អៗប្រឆាំងនឹងអំពើនេះ សួរថា តើហេតុដូចម្តេចបានជាជម្ងឺពុករលួយ វាកាន់តែធ្ងន់ធ្ងរៗឡើងជានិច្ចនៅក្នុងស្រុកខ្មែរ?

នៅក្នុងខែមករាឆ្នាំ១៩៦៣ សម្តេចសីហនុ បានថ្លែងនៅចំពោះសមាជជាតិថា ព្រះអង្គមិនប្រឆាំងនឹងការប្រកាសរបបសាធារណរដ្ឋនៅស្រុកខ្មែរនោះទេ។  ការនេះ វាជាទម្លាប់នៃការមួម៉ៅ និង កបិចិត្តរបស់ទ្រង់តែប៉ុណ្ណោះ នយោបាយដឹកនាំជាតិរបស់ទ្រង់គឺឈរលើកបិចិត្តនេះឯង ម្សិលមិញ និងថ្ងៃស្អែករបស់សីហនុ គឺបង្កើតជានិច្ចនូវបញ្ហាដល់ប្រជាជាតិខ្មែរ ព្រោះម្សិលមិញ ទ្រង់ថាក្រហម តែដល់ថ្ងៃស្អែក ទ្រង់ថាខៀវ អ្វីដែលជាការពិត វាគ្មាននោះឡើយនៅក្នុងការត្រិះរិះរបស់សម្តេចឪ។

ក្នុងខែវិច្ឆិកាឆ្នាំ១៩៦៣ ទ្រង់ធ្វើ ជាតូបនីយកម្មធនាគារ និងអាហារណករ.នីហរករ ដែលជាផ្នែកពីរសំខាន់នៃសេដ្ឋកិច្ចសេរី។  ជំហាននេះ ជាជំហានមួយទៀត ដើរឆ្ពោះទៅរកសេដ្ឋកិច្ចសង្គមនិយម ដែលជារោគលក្ខណៈ(symptôme)នៃរោគស្ពឹកនៃសេដ្ឋកិច្ចជាតិខ្មែរ។

នៅថ្ងៃទី១៣មករាឆ្នាំ១៩៦៤ ទ្រង់ធ្វើកំណែទំរង់រដ្ឋធម្មនុញ្ញ បង្កើតប្រជាតុលាការ។

## សកម្មភាពនយោបាយនៅក្រៅប្រទេស

-ថ្ងៃទី១៦ឧសភាឆ្នាំ១៩៦១:ទ្រង់ធ្វើជាប្រធាននៃសន្និសិទនៅទីក្រុងស៊ឺណែវស្តីអំពីបញ្ហានៅប្រទេសលាវ។

-ពីថ្ងៃទី១ដល់៥កញ្ញាឆ្នាំ១៩៦១:ទ្រង់ចូលរួមការប្រជុំក្នុងសន្និសិទនៃបណ្តាប្រទេសមិនចូលប្រតិព័ន្ធណាមួយនៅទីក្រុងបែលក្រាត។

-ថ្ងៃទី១៥មិថុនាឆ្នាំ១៩៦២:តុលាការអន្តរជាតិ(C.I.J) សំរេច ឲកម្ពុជាឈ្នះក្តី ក្នុងជម្លោះទាក់ទងនឹងប្រាសាទព្រះវិហាររវាងខ្មែរ.សៀម។

-ថ្ងៃទី២០កក្កដាឆ្នាំ១៩៦២:សីហនុសុំឲបើកសន្និសិទទាក់ទងនឹងអព្យាក្រិតរបស់ប្រទេស

កម្ពុជា។

-ក្នុងឆ្នាំ១៩៦២:សីហនុបើកឲមានតំណាងពាណិជ្ជកម្មយួនខាងជើងនៅភ្នំពេញ។

-ថ្ងៃទី១វិច្ឆិការឆ្នាំ១៩៦៣:សីហនុផ្តាច់ទំនាក់ទំនងតាមផ្លូវទូតជាមួយយួនខាងត្បូង។

-ថ្ងៃទី១៩វិច្ឆិកាឆ្នាំ១៩៦៣:សីហនុបដិសេធជំនួយសហរដ្ឋអាមេរិក ហើយធ្វើការអំពាវនាវសុំឲចិនកុម្មុយនិស្តបញ្ជូនអ្នកឯកទេសចិនមកជួយខ្មែរ។

-ថ្ងៃទី១៩វិច្ឆិកាឆ្នាំ១៩៦៣:សីហនុអនុញ្ញាតឲបាតុករខ្មែរ ឡោមព័ទ្ធ ហើយវាយចូលស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងអង់គ្លេសនៅកម្ពុជា។

-ថ្ងៃទី១១មិនាឆ្នាំ១៩៦៤:ប្រទេសកម្ពុជាដាក់ពាក្យបណ្តឹងទៅក្រុមព្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ អំពីការឈ្លានពានកងទ័ពអាមេរិកកាំង និងយួនខាងត្បូងមកក្នុងប្រទេសខ្មែរ។

-ក្នុងខែតុលាឆ្នាំ១៩៦៤:មានការជួបជជែកគ្នារវាងខ្មែរនិងយួនខាងជើងនៅទីក្រុងប៉េកាំង។

-ក្នុងខែមិនាឆ្នាំ១៩៦៥:មានបើកសន្និសិទនៃប្រជាពលរដ្ឋឥណ្ឌូចិននៅទីក្រុងភ្នំពេញ។

-ថ្ងៃទី៣មេសាឆ្នាំ១៩៦៥:កម្ពុជាផ្តាច់ការទាក់ទងតាមផ្លូវទូតជាមួយសហរដ្ឋអាមេរិក។

-ថ្ងៃទី១១មេសាឆ្នាំ១៩៦៦:កម្ពុជា និងយួនខាងជើង ចាប់ផ្តើមមានទំនាក់ទំនងតាមផ្លូវទូត។

-ថ្ងៃទី៣០កក្កដា លោកឧត្តមសេនីយ ស៊ាល.ដឺហ្គ៉ូល ប្រធានាធិបតីសាធារណរដ្ឋបារាំងសែសបានអញ្ជើញមកធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជា។ លោកបានធ្វើសុន្ទរកថាមួយ ស្តីអំពីបញ្ហាសង្គ្រាមនៅយៀកណាម ក្នុងនោះ លោកបានឲវិស័យមតិលោកថា ដំណោះស្រាយនៃសង្គ្រាមនេះ មានតែផ្លូវនយោបាយប៉ុណ្ណោះទើបអាចបញ្ចប់សង្គ្រាមបាន។

បើយើងធ្វើការសង្ខេបនយោបាយសម្តេចសីហនុក្នុងរយះពេល៥ឆ្នាំ(១៩៦០ដល់ដល់១៩៦៥) គឺជាដំណើរដើរចូលដោយខ្លួនឯងទៅរស់នៅក្នុងទ្រុងកុម្មុយនិស្ត ហើយក៏ជាការលុបបំបាត់ដោយខ្លួនឯងនូវធម្មានុរូប(légitimité)របស់ទ្រង់ ដែលវាមានពីប្រជាប្រិយភាព អភិវឌ្ឍន៍ និង នយោបាយអព្យាក្រិតរបស់ព្រះអង្គ។ យើងនឹងបន្តការសិក្សារបស់យើងអំពីផលវិបាកដែលកើតចេញមកពីការបែរនយោបាយរបស់សម្តេចសីហនុ ដែលនាំឲសេដ្ឋកិច្ចជាតិ

វិនាស ហើយឲប្រជាជាតិខ្មែរ ធ្លាក់ចូលទៅក្នុងសង្គ្រាម ដែលបង្កើតឡើងដោយពួកកុម្មុយនិស្ត ដែលជាប្រិយមិត្តរបស់ព្រះករុណាសីហនុ។

**ការប្រើពាក្យ៖**

របបសិទ្ធិអំណាច(régime autoritaire)=របបហាមប្រជាពលរដ្ឋមិនឲធ្វើ។ របបនេះ វាយកម្ទេចអ្នកប្រឆាំង។

(Annah Arendt)

របបសមស្ត(régime totalitaire)=របបបង្ខំប្រជាពលរដ្ឋឲធ្វើ ជារបបមានគណបក្សតែមួយ។

បញ្ចុះបញ្ចូលប្រជាពលរដ្ឋតាមការបង្ខំឲធ្វើតាមមនោគមវិជ្ជារបស់គណបក្ស។

មហាជន=La masse.

**ឯកសារនិងសៀវភៅយោង៖**

Conférence S.A.R. Le Prince Norodom Sihanouk  Chef de l'Etat du Cambodge à la faculté de Droit de Paris(1964).

១ J.LACOUTURE;  P.DEVILLIERS;  P.PRESCHEZ។

២ លទ្ធិប្រជាធិបតេយ្យអឌ្ឍដោយចំពោះ=Démocratie semi-directe។

៣ សភាប្រជាជន(Assemblées Populaires)របៀបបោះឆ្នោតជ្រើសតាំងគឺដូចគ្នានឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្ររដ្ឋសភា ចំនួនមានពី៥នាក់ទៅ១៨នាក់

ទៅតាមចំនួនប្រជាជនក្នុងខេត្ត នៅទីក្រុងភ្នំពេញមានតំណាង៧នាក់។

៤ ដកស្រង់ពីសន្និសិទសម្តេចសីហនុនៅសាកលវិទ្យាល័យច្បាប់នៅទីក្រុងប៉ារីស នាថ្ងៃទី២៩មិថុនាឆ្នាំ១៩៦៤។

ចុះផ្សាយនៅក្នុងទស្សនាវដ្តីច្បាប់ និងនយោបាយ នៅក្នុងលេខទី៤ ខែតុលា.ធ្នូ ឆ្នាំ១៩៦៤។

៥ ប្រពៃណីនិយម=Folklore.

៦ បដិបត្តិបូជា=បូជាពីការប្រតិបត្តិត្រឹមត្រូវតាមធម៌ព្រះពុទ្ធ។

៧ ជនាធិបតី=Souveraineté populaire។

៨ កាគោរពឥស្សរជន=Culte de personnalité.

៩ ជារដ្ឋទាយាទអភ័ព្វ ព្រោះក្រោយពីបិតាព្រះអង្គ ហ្លួងសីសុវត្ថិមុនីវង្សសុគត បារាំងមិនរើសយកព្រះអង្គឲគ្រងរាជ្យ បែរជាទៅជ្រើស

រើសសម្តេចសីហនុ ជាក្មួយរបស់ព្រះអង្គឲគ្រងរាជ្យទៅវិញ។

១០ Thèse de Khieu Samphan : L'économie du Cambodge et ses problèmes d'industrialisation (សេដ្ឋកិច្ចនៅកម្ពុជា និងបញ្ហា

ឧស្សាហូបនីយកម្ម។

# ៦

## សម័យឯករាជ្យ

## ដើមកំណើតនៃការត្រិះរិះនយោបាយខ្មែរ

យើងបើកវង់ក្រចក ដើម្បីសិក្សាអំពីដើមកំណើតនៃការត្រិះរិះនយោបាយខ្មែរ មុននឹងបន្ត ពិនិត្យមើលសម័យសង្គមរាស្ត្រនិយមទី៣ ព្រោះវានាំឲយើងអាចស្គាល់នូវកម្លាំងនយោបាយ ខ្មែរនៅក្នុងជំនាន់នោះ។

យើងដឹងថា សង្គមបុរាណខ្មែរ អាចរក្សាការរស់នៅរបស់ខ្លួនអស់ច្រើនសតវត្ស នៅក្នុងស្ថិរ ភាពដ៏ប្រសើរ ប្រេះនឹងនិច្ចលភាព មានអ្នកចេះដឹងប្រកបដោយគតិបណ្ឌិត មានរាស្ត្រស្លូត បូត ចេះគោរពប្រតិបត្តិ នាំគ្នារស់ក្នុងបរិយាកាសស្ងប់ស្ងៀមនៅក្រោមបារមីព្រះមហាក្សត្រ និងព្រះពុទ្ធសាសនា ក្នុងជំនឿជឿកម្មវាសនា។ តែនៅពេលដែលប្រជារាស្ត្រចាប់ផ្តើមដឹកខ្លួន ថា ជោគវាសនារបស់ខ្លួន វាអាចប្រសើរលើសពីជីវិតដែលខ្លួនកំពុងរស់នៅ ហើយអ្នកចេះដឹង សំគាល់ឃើញថា សេរីភាព និងបច្ចេកទេស អាចបើកទស្សនវិស័យឥតមានកំរិត សំរាប់ សកម្មភាពនៃមនុស្សលោក ដែលជាទង្វើ អាចបំលាស់ប្តូរ សង្គមបុរាណ ឲទៅជាសង្គមសម័យ ប្រកបដោយសេចក្តីចម្រើន។ ការបំបើកភ្នែកនេះ នាំបង្កើត ការត្រិះរិះនយោបាយ ដែលជា ការត្រិះរិះជាថាមវន្ត បង្កើតបញ្ហា ហើយបញ្ហានេះគឺប្រៀបាននឹងជីរ សំរាប់ដាំដើមឈើនៃការ ចំរើនលូតលាស់នេះឯង ហើយការលូតលាស់នេះ ត្រូវចាំបាច់មានលទ្ធិប្រជាធិបតេយ្យជាបាទ ផងជាមធ្យោបាយផង សំរាប់ចែកផលឲស្មើគ្នាទៅតាមបុញ្ញាកិរិយារបស់ពលរដ្ឋម្នាក់ៗនៅក្នុង សង្គមជាតិ។ ហេតុនេះឯង យើងអាចទុកការត្រិះរិះនយោបាយជាកត្តាសំរាប់រំសាយចេញពី សង្គមនូវទម្លាប់ជាអវិជ្ជមាន ទុកតែទំនាមជាវិជ្ជមាន យកវាមកបូកជាមួយបច្ចេកទេស ទំនើប សំរាប់បំរែបំរួលសង្គមខ្មែរឲរីកតែពិស្តារឆាប់រហ័សទៅទៀត ក្នុងសេរីភាព សមភាព និងអភិវឌ្ឍន៍។

### ដំណេកកម្លាំងនយោបាយក្នុងសម័យសង្គមរាស្ត្រនិយម

ដូចធ្លាប់បានជំរាបរួចមកហើយថា ក្រោយពីចលនាសង្គមរាស្ត្រនិយមដណ្តើមបានអំណាច ទាំងអស់មកក្នុងកំលុងឆ្នាំ១៩៥៦ កម្លាំងនយោបាយដែលធ្លាប់មានសកម្មភាព បាននាំគ្នា

សម្ងំដេក រង់ចាំឱកាសល្អ ដែលខ្លួនយល់ឃើញថាវាដល់កាល អាចឲខ្លួនងើបធ្វើសកម្មភាពនយោបាយបានឡើងវិញ។ កម្លាំងនោះមាន៤ក្រុម(៖)អ្នកជាតិនិយម អ្នកស្តាំនិយម អ្នកជឿនលឿននិយម និងអ្នកកុម្មុយនិស្តនិយម។

## ការភ្ញាក់រលឹកនៃអ្នកស្នេហាជាតិ

ជាបឋម គួរយើងលើកយកចំណុច នៃការភ្ញាក់រលឹកនៃអ្នកស្នេហាជាតិ មកធ្វើជាយោងក្នុងការកកើត នៃការត្រិះរិះនយោបាយខ្មែរ។ យើងគួរកត់សំគាល់ថា ការហូរចូលនៃវប្បធម៌បស្ចឹមប្រទេស មកក្នុងស្រុកខ្មែរក្នុងសម័យអាណាព្យាបាលបារាំង(១៨៦៣ ១៩៥៣)គ្មាននាំមក នូវពន្លឺនៃសេរីភាព និងសិទ្ធិមនុស្សសំរាប់សង្គមខ្មែរនោះឡើយ ព្រោះថាសទ្ធិសញ្ញាអាណាព្យាបាលបារាំងជាមួយនឹងខ្មែរ ជាសទ្ធិសញ្ញានយោបាយ និងយោធា ដែលមានចំណុចធំពីរ(៖)ការពារមហាក្សត្រ និងប្រយោជន៍បារាំង និងខ្មែរនៅចំពោះមុខប្រទេសជិតខាង មានយួន សៀម។

ខ្មែរយើងភាគច្រើនតែងតែយល់ឃើញថា សទ្ធិសញ្ញាអាណាព្យាបាលបារាំងជា«**អំពើមួយមិនល្អតែជាការចាំបាច់ណាស់**»សំរាប់សង្គ្រោះជាតិខ្មែរពីមហិច្ឆិតាជាវិត្ថារកម្ម នៃប្រទេសសៀម និងយួន។ តែសទ្ធិសញ្ញានេះនៅរក្សាជានិច្ចនូវស្ថានភាពជាប្រទេសខ្ញុំបរទេស គឺស្រុកខ្មែរគ្រាន់តែដូរអ្នកត្រួតត្រាតែប៉ុណ្ណោះ។ ក្នុងស្ថានភាពនេះ ខ្មែរយើងគ្រាន់តែបានធ្វើការប្រៀបធៀបថាចៅហ្វាយថ្មី គាត់មានចិត្តល្អជាងចៅហ្វាយចាស់ ហើយនាំគ្នារស់ធ្វើជាបាវគេបន្តទៅទៀត ឥតនាំគ្នាមានបារម្ភអំពីអានាគតជាតិនោះឡើយ។ បើកាលណាមានចលនាប្រឆាំងនឹងរបបអាណានិគម ដូចយ៉ាងចលនារំដោះជាតិរបស់លោកក្រឡាហោមគង់ក្តី អាចារ្យស្វាក្តីក្នុងសតវត្សទី១៩ ខ្មែរយើងភាគច្រើនក៏នាំគ្នានិយាយតាមការចោទរបស់បារាំង និងរាជានិយម ថាជាអំពើក្បត់ជាតិ។ ពិតប្រាកដណាស់ ខ្មែរយើងនាំគ្នានិយាយតាមគេបែបនេះ ព្រោះខ្លាចអំណាចអ្នកត្រួតត្រា បើគេថាល្អ ត្រូវតែនាំគ្នាថាល្អ បើគេថាអាក្រក់ត្រូវនាំគ្នាថាអាក្រក់ រឿងនេះ បើយើងមិនបានយកមកពិចារណាឲបានម៉ត់ចត់ គឺនាំគ្នាគិតថាជារឿងធម្មតា ឧបមាថា តើមនុស្សណាមួយមិនខ្លាចស្លាប់?.តែបើយើងយកវាមកគិតបន្តិច យើងឃើញថាក្នុងពាក្យខ្មែរ ក៏មានពាក្យ«វិរបុរស» សួរថាតើពាក្យនេះវាបាត់ពីសតិខ្មែរអស់ហើយឬ?.បើបាត់មែន រឿងនេះ វាមិនមែនជារឿងធម្មតាទេសំរាប់ជាតិ ព្រោះពាក្យវិរបុរសនេះ មានសារជាតិវា ពីរសំខាន់ គឺ សេចក្តីក្លាហាន និងសេចក្តីលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ និងកិត្តិយសជាតិ។ សញ្ញាណនៃប្រយោជន៍ជាតិនេះ វាខុសគ្នានឹងប្រយោជន៍រួម ព្រោះប្រយោជន៍រួម ឬអាណាប្រយោជន៍នៅក្នុងប្រទេសមាននីតិរដ្ឋ មានច្បាប់រដ្ឋសំរាប់ការពារវា ឯចំណែកប្រយោជន៍ជាតិ ដែលជាឧត្តមប្រយោជន៍ មានអ្នកការពារ គឺប្រជាពលរដ្ឋ ដែលជាប្រជាធិបតីនេះឯង។ ការពារប្រយោជន៍ជាតិ ជាករណីយកិច្ច សិទ្ធិ និងជាកតព្វកិច្ចរបស់ពលរដ្ឋម្នាក់ៗនៅក្នុងឆន្ទៈទូទៅនៃប្រជាពលរដ្ឋ។ ដូច្នេះបើប្រជាជាតិក្លាយជាប្រជាជាតិខ្ញុំគេ ប្រជាពលរដ្ឋនេះ

ឯងជាអ្នកទទួលខុសត្រូវទី១ព្រោះខ្លួននេះឯងជាអ្នកការពារ។ ដូចសភាសិតខ្មែរមួយចារចែងថាៈ«ដំរីខ្វាក់ ទ្រមាក់ឆ្កួត»មានន័យថាបើរាស្ត្រល្ងង់ គឺច្បាស់ជាមានស្តេចឆ្កួតដឹកនាំជាតិជាពុំខាន។

ការកកើតគំនិតនយោបាយខ្មែរនៅក្នុងសតវត្សទី១៩ គឺនយោបាយប្រឆាំងនឹងរបបអាណានិគមបារាំង ព្រោះរបបនេះ ឲសិទ្ធិដល់ជនជាតិយួនរស់នៅកម្ពុជាក្រោម ជាកម្មសិទ្ធិស្របតាមច្បាប់ មិនថែមតែប៉ុណ្ណោះ គេបញ្ចូលជនជាតិយួន ឲមករស់នៅក្នុងបណ្តាខេត្តឋិតនៅជុំវិញបឹងទន្លេសាប គេយកជនជាតិយួនមកត្រួតអ្នករាជការខ្មែរនៅគ្រប់ក្រសួង ជាពិសេសក្រសួងសន្តិសុខជាតិ និងរតនាគារភិបាល។ ក្នុងភូមិសេដ្ឋកិច្ច បារាំង គេមិនសូវយកចិត្តទុកដាក់ជួយខ្មែរឲធ្វើអភិវឌ្ឍន៍ជនបទ ក្នុងផ្នែកកសិកម្ម ក៏ដូចក្នុងផ្នែកសិប្បកម្ម គេគិតតែធ្វើនយោបាយសេដ្ឋកិច្ច បំរើតែប្រយោជន៏អាណានិគម យកឈ្មួញចិន និងយួនជានាដការជាដើមអាទ៍ ឬជាឈ្មួញកណ្តាល នាំចូលទំនិញពីបរទេសមកលក់ ដែលជាអំពើធ្វើឃាតដោយមិនចំពោះផលលិតកម្មក្នុងស្រុក នាំឲសេដ្ឋកិច្ចជាតិ បាត់ស្វ័យភាពនូវផលិផលចាំបាច់សំរាប់ការរស់នៅរៀងរាល់ថ្ងៃ។ ដូចលោកប៉ុន.ចន្ទម៉ុលលើកមកបង្ហាញនៅក្នុងសៀវភៅរបស់លោក «គុកនយោបាយ»នៅពេលសង្គ្រាមលោកលើកទី២ផ្ទុះឡើង ប្រជាជនខ្មែរជួបប្រទះនូវការខ្វះខាតគ្រប់បែបយ៉ាងជាពិសេសក្រណាត់សំរាប់កាត់ធ្វើសំលៀកបំពាក់ ព្រោះខ្មែរគេតបានដាំកប្បាស ខ្វះរោងតម្បាញមិនតែប៉ុណ្ណោះ បារាំងជំនាន់នោះ គេទុកអាជីវកម្មនេះជាទោស បើចង់ត្បាញគឺលួចធ្វើ ហើយបើអាជ្ញាធរចាប់បាន គេយកទៅដាក់គុក។ វិធានការនេះ គឺសំរាប់ការពារឈ្មួញកណ្តាល នាំឲរាស្ត្រខ្មែររស់ក្នុងទុក្ខដូចសត្វ គឺស្រាតនៅក្នុងខ្ទម ព្រោះអត់សារុង និងសំពត់ស្លៀកពាក់។ ព្រឹត្តិការណ៍ពិតនេះ នាំឲយើងសួរថា តើរបបអាណានិគមនៅពេលនោះ មានធាតុជារបបបែបណាដែរ?

ឃើញបែបនេះ ខ្មែរចាប់ផ្តើមមានមនោសញ្ចេញនា យល់ឃើញថា អាជ្ញាធរអាណាព្យាបាលបារាំង ក្បត់ជាតិខ្មែរ ធ្វើនយោបាយបំរើប្រយោជន៍ឯកជន និងប្រយោជន៍ខ្លួនឯង។ រឿងនេះ អ្នកតាមដានប្រវត្តិសាស្ត្រជាតិ ដឹងថា គំនិតប្រឆាំងនឹងបារាំង ចាប់ផ្តើមដុះចេញជារូបភាពនយោបាយពិត តាមការបង្កើតសារពត៍មាន«អង្គរវត្ត»នៅឆ្នាំ១៩៣៦ ពីសំណាក់អ្នកស្នេហាជាតិខ្មែរមួយក្រុម ដែលយើងលើកយកឈ្មោះមហាបុរសទាំងនោះមករំលឹកគុណ មាន(៖) ភិក្ខុហែម.ជៀវ ខៀវ.ជុំ ប៉ាង.ខាត់ លោកស៊ឹង.ង៉ុកថាន់ អៀវ.កើស ស៊ឹម.វ៉ា ទេព.ប៉ាន់ ប៉ុណ្ណ.ចន្ទម៉ុលនិងអ្នកស្នេហាជាតិអនាមិកជាច្រើនទៀត។ សារព័តមាននេះ ជាការផ្តើមនៃគំនិតប្រឆាំងនឹងរបបអាណានិគម ហើយក្រោយមក មនៈសិការជាតិនេះ នាំបង្កើតបាននូវកម្លាំងសង្ឃឹម អាចមានលទ្ធភាពប្រមូលខ្មែរអ្នកស្នេហាជាតិ ធ្វើសកម្មភាពនយោបាយ ដូចយ៉ាងនៅថ្ងៃទី២០កក្កដាឆ្នាំ១៩៤២ មានបាតុកម្មមួយផ្ទុះឡើងនៅភ្នំពេញ រួមទាំងព្រះសង្ឃ និងគ្រហស្ថ ដឹកនាំដោយលោកស៊ឹង.ង៉ុកថាញ់ និងប៉ាច.ឈឿន ដង្ហែក្បួន ហើយស្រែកទាមទារឲ

បារាំងដោះលែងភិក្ខុហែម.ចៀវ ដែលអាជ្ញាធរបានចាប់ព្រះអង្គដាក់ពន្ធនាគារ ពីបទធ្វើសកម្មភាពនយោបាយប្រឆាំងនឹងបារាំង។ បន្ទាប់ពីព្រឹត្តិការណ៍នេះមក មនះសិការខ្មែរនេះត្រូវបានអាជ្ញាធរអាណាព្យាបាលបារាំង បង្ក្រាបគតប្រណី តែទោះបីយ៉ាងណាក្តី ក៏ពុំអាចសម្លាប់ឧត្តមគតិរំដោះជាតិនេះបាននោះឡើយ ព្រោះសម្បជញ្ញខ្មែរ ហើយថែមទាំងមានការប្តេជ្ញាចិត្តថានឹងរំដោះជាតិឲបាន ក៏នាំគ្នារកមធ្យោបាយបង្កើតចលនាតស៊ូរ ដូចយ៉ាង មានការបង្កើតចលនា«ខ្មែរតស្សូរៈ»ក្នុងកំលុងឆ្នាំ១៩៤៦(សុំអានសៀវភៅ ចរិតខ្មែរ និពន្ធដោយលោក ប៉ុណ្ណ.ចន្ទម៉ុល)។

ក្រោយពីចប់សង្គ្រាមលោកលើទី២មក កងទ័ពសម្ពន្ធមិត្របានឈ្នះសង្គ្រាមលើកងទ័ពណាស៊ីនៅអឺរ៉ុប និងកងទ័ពជប៉ុននៅអាស៊ី គេក៏បានអនុញ្ញាត ឲកងទ័ពបារាំងសេរី ដឹកនាំដោយលោកឧត្តមសេនីយ ដឺហ្គោល ដែលជាសមាសភាគមួយនៃកងទ័ពសម្ពន្ធមិត្ត មកចាត់ចែងការសុំចាញ់កងទ័ពជប៉ុននៅតេណ្ឌូចិន គួររំលឹកដែរថានៅក្នុងរយៈពេលសង្គ្រាមលោកលើកទី២ អាជ្ញាធរបារាំងនៅតេណ្ឌូចិន បានគាំទ្ររបបលោកសេនាប្រមុខប៉េតាំង ឬវិស៊ី ហើយសម្តេចសីហនុនេះ ជាមហាក្សត្រជ្រើសរើសឡើងដោយរបបវិស៊ីនេះឯង ហេតុនេះឯងនៅពេលទ័ពបារាំងសេរីមកដល់ស្រុកខ្មែរ ហ្លួងសីហនុភ័យណាស់ រត់ទៅពួនក្នុងវត្តខ្លាចបារាំងចាប់ ទី១ ព្រោះបានចូលជប៉ុន ប្រកាសឯករាជ្យតាមអនុសាសន៍ជប៉ុននៅថ្ងៃទី១២មិនាឆ្នាំ១៩៤៥ ទី២ទទួលរាជ្យសម្បត្តិក្នុងរបបវិស៊ី ដែលជារបបធ្វើសហការជាមួយរបបណាស៊ី។ ពេលមកដល់ស្រុកខ្មែរ អាជ្ញាធរបារាំងសេរី តតបានសើរើការសំរេចទាំងឡាយរបស់អាជ្ញាធរបារាំងនៅក្រោមអំណាចរបបវិស៊ីននោះឡើយ ព្រោះគេទុកប្រយោជន៍បារាំងជាធំ អ្វីដែលសំខាន់របស់គេ គឺប្រត្យាស្ថាបនារបបអាណានិគមនៅតេណ្ឌូចិន តែគោលបំណងនេះ ត្រូវបានសហរដ្ឋអាមេរិកផង និងចក្រភពអង់គ្លេសឃាត់មិនឲសមិទ្ធិបាន ហេតុនេះឯងបានជាបារាំង បង្ខំខ្លួនឯងធ្វើកិច្ចសញ្ញាបណ្តោះអាសន្នជាមួយរដ្ឋាភិបាលខ្មែរ បន្ទាប់មក គេង្កើតសហភាពបារាំង ដែលមានប្រទេសអតីតអាណានិកមជាសមាជិក ដើម្បីបន្តវត្តមានរបស់ខ្លួននៅក្នុងអតីតបណ្តាប្រទេសទាំងនោះ ឲរាស្របច្បាប់អន្តរជាតិផង និងសិលធម៌ផង។

ការបង្កើតរដ្ឋធម្មនុញ្ញខ្មែរលើកទី១ក្នុងឆ្នាំ១៩៤៧ បង្ហាញពីការកកើតគំនិតលទ្ធិប្រជាធិបតេយ្យសេរីក្នុងគតិអ្នកស្នេហាជាតិខ្មែរ តែកំណើតនេះ ក៏វាក្លាយជាការគំរាមកំហែងដល់អាជ្ញាធរសហភាពបារាំងនៅស្រុកខ្មែរនោះដែរ។ យើងដឹងថា នៅពេលសរសេររដ្ឋធម្មនុញ្ញ ពួកបារាំងដែលជាសមាជិកគណកម្មការនៃការតែងសេចក្តីរដ្ឋធម្មនុញ្ញ នៅមានឥទ្ធពលខ្លាំងណាស់លើអ្នកតែងច្បាប់ខ្មែរ ទី១គេការចេះដឹងរបស់គេ មកសង្កត់លើខ្មែរ ទី២បារាំង គេយកអំណាចមកកំហែង បែបហឹង្សាផង និងលួងលោមផង ឲខ្មែរយល់ឃើញដូចគេ ក្នុងគោលបំណងការពារប្រយោជន៍របស់បារាំង និងមហាក្សត្រខ្មែរ ដែលគេទុកជា សម្ពន្ធមិត្រអាចទុកចិត្ត

បាន និងមានភក្តីភាព។ ដូច្នេះនៅពេលនោះ គំនិតនយោបាយអ្នកស្នេហាជាតិខ្មែរ គឺការពារលទ្ធិប្រជាធិបតេយ្យជាដាច់ខាត ចំពោះមុខបារាំងផង និងរបបរាជាធិបតេយ្យផង។ នៅពេលដែរ អ្នកស្នេហាជាតិខ្មែរចាប់ផ្តើមមានការសង្ស័យទៅលើរបបរាជានិយម ថាជារបបធ្វើសហការជាមួយបារាំងប្រឆាំងនឹងប្រយោជន៍ខ្មែរ ដែលជាការកកើតក្នុងគំនិតខ្មែរអ្នកស្នេហាស្អប់ជាដំបូង នូវរាជាធិបតេយ្យ។

អស់រយៈពេល៩ឆ្នាំ(១៩៤៧ ១៩៥៦)អ្នកស្នេហាជាតិ ដែលជាអ្នកប្រជាធិបតេយ្យនិយម ធ្វើការទប់ទល់ តាមមធ្យោបាយដែលខ្លួនមាន ទប់ទល់នឹងការប៉ុនប៉ង របស់អ្នករាជានិយម ដែលមានហ្លួងសីហនុជាអ្នកនាំមុខ បង្កើតឡើងវិញនូវរបបរាជាធិបតេយ្យ ការការពារនេះ បានជួបប្រទះនឹងឧបសគ្គរបាំងអំណាចផ្តាច់ការ បង្កើតឡើងដោយហ្លួងសីហនុ។ របាំងនោះមានឈ្មោះថាចលនាសង្គមរាស្រ្តនិយម បន្លំធ្វើជា ចលនាជាតិនិយម តែជាជាតិនិយមឥតអត់អោន និងបង្គអធិករណ៍ជានិច្ចជាមួយអ្នកប្រជាធិបតេយ្យនិយម។ ក្នុងរយៈពេលនេះឯងអ្នកប្រជាធិបតេយ្យ លែងមានការសង្ស័យទៅលើអត្ថទត្ថភាពនៃរបបរាជាធិបតេយ្យ ហើយដូរពីការស្អប់ ទៅជាការប្រឆាំងនឹងរបបរាជានិយមតែម្តង ព្រោះមើលឃើញច្បាស់ថា ស្តេចសីហនុទ្រង់ក្លាយជាជនផ្តាច់ការ និងជាអរតារនៃបដិបក្ខជាតិ ឧទាហរណ៍ ទ្រង់តាំងខ្លួនជាប្រមុខរដ្ឋអស់មួយជាជីវិត ជាអ្នកដឹកនាំនយោបាតអស់មួយជីវិតនេះ គឺជាងាររបស់មហាក្សត្រផ្តាច់ការនោះឯងហើយ។

តែការប្រឆាំងនឹងរបបរបបរាជានិយមរបស់អ្នកស្នេហាជាតិ ជាការប្រឆាំងជ្រើសរើស ព្រោះក្នុងចំណោមអ្នកស្នេហាខ្មែរ មានភាគច្រើន នៅតែរំលឹកបែបអំណរគុណ ដល់ស្គាល់ស្នាដៃមហាក្សត្រខ្មែរដែលបានកសាងស្រុកខ្មែរ ឲក្លាយជាមហានគរ តែមិនបានយកមកពិចារណាថា តើរាស្រ្តខ្មែរត្រូវមហាក្សត្រទាំងឡាយនោះ បង្ខំឲធ្វើពលិកម្មហួសពីកម្លាំងមនុស្សបែបណាខ្លះ ដើម្បីធ្វើសមិទ្ធិនេះ។ រួមសេចក្តីមក ក្នុងគតិនេះ គេអាចធ្វើអនុមានបានថា រហូតមកដល់បច្ចុប្បន្ននេះ សូម្បី ក្នុងចំណោមអ្នកប្រជាធិបតេយ្យនិយម ភាគច្រើន គាត់មិនដែលប្រឆាំងរបបរាជានិយមក្នុងឋានៈជារបបដឹកនាំនោះទេ តែគ្រាន់តែប្រឆាំងនឹងមហាក្សត្រណាដែលគ្មានទសពិធរាជធម៌តែប៉ុណ្ណោះ។ ទស្សនៈនេះចម្លែកណាស់ ហើយមានព្យាកុលភាពនៅក្នុងគំនិតតស៊ូដើម្បីសេរីភាព និងសមភាព ព្រោះយកបុគ្គលមកដាក់ពីលើប្រព័ន្ធ តែឥតបានគិតថា ប្រព័ន្ធទេ ដែលជាពុម្ព ក្រសៃចិត្តមនុស្ស ហើយការនេះ វាពុំអាចមានវិលោមបានទេ។ ហេតុនេះឯង បើគេចង់ដូររបៀបដឹកនាំជាតិ គឺជាបឋម ត្រូវដូរប្រព័ន្ធរបប ទើបអាចដូរចរិតអ្នកដឹកនាំបាន។ ទស្សនៈទុកបុគ្គលលើប្រព័ន្ធនេះឯងហើយ ដែលសហគមន៍អន្តរជាតិគេនៅតែយល់ឃើញថា ប្រជាពលរដ្ឋខ្មែរជាអ្នករាជានិយម បើត្រូវរកមធ្យោបាយមកដោះស្រាយវិបត្តិនយោបាយ ត្រូវចាំបាច់យករបបរាជានិយមមកធ្វើជាការដោះស្រាយ ព្រោះវា

ជាកត្តាអាចបង្រួបបង្រួមខ្មែរបាន។

ដូច្នេះ យើងអាចសង្ខេបបានថា ការត្រិះរិះនយោបាយខ្មែរជាអាទ៍ គឺប្រឆាំងនឹងអាណានិគម (១៩៣៦ ១៩៤៧)បន្ទាប់មកទប់ទល់ ដោយយកលទ្ធិប្រជាធិបតេយ្យជាអាវុធ មិនឲរបបរាជាធិបតេយ្យកើតបានឡើងវិញ(១៩៤៧ ១៩៥៦)ក្រោយមកទៀត ប្រឆាំងនឹងរបបរាជាធិបតេយ្យក្លែងខ្លួនជារបបជាតិនិយមផ្តាច់ការ(សង្គមរាស្ត្រនិយម ឬសីហនុនិយម)ដែលជារបបមានលក្ខណៈជារបបសមន្តនិយម(១៩៥៦ ១៩៧០)។

## ខ្នែងនៃការត្រិះរិះនយោបាយខ្មែរ

ការវិវឌ្ឍន៍នៃការត្រិះរិះនយោបាយខ្មែរ ដែលយើងលើកយកវា មកធ្វើសង្ខេបខាងលើនេះ វាមានបែកខ្នែង កើតជាមែកផ្សេងៗគ្នានៃដើមឈើនយោបាយខ្មែរ។ តែយើងដឹងថានៅក្នុងរយៈពេលនោះ នៅក្នុងពិភពលោក មានលទ្ធិនយោបាយច្រើនបែបយ៉ាង ប្រឈរមុខទល់គ្នា គឺលទ្ធិរាជានិយម លទ្ធិប្រជាធិបតេយ្យសេរី លទ្ធិសង្គមនិយម លទ្ធិកុម្មុយនិស្ត និងលទ្ធិសង្គមជាតិនិយម(វ៉ាស៊ីស និងណាស៊ី)។ លទ្ធិទាំងនោះរួមជាបីមែកធំៗៈមែកធំទី១ គឺមែកប្រជាធិបតេយ្យមានមែកតូចពីរ គឺរបបប្រជាធិបតេយ្យសង្គមនិយម និងរបបប្រជាធិបតេយ្យសេរី;មែកធំទី២ គឺមែកសិទ្ធិអំណាចនិយម មានរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងរាជាធិបតេយ្យ មែកធំទី៣ គឺសមន្តនិយម មានរបបកុម្មុយនិស្ត និងសង្គមជាតិនិយម។ យើងសួរជាសំនួរថាតើអាណានិគមនិយម ជាអ្វី?.អាណានិគមនិយម ជានយោបាយវាតទឹកដីរបស់បណ្តាមស្ទឹមប្រទេសមួយពួក ដែលជាប្រទេសមានកម្លាំងយោធា និងសេដ្ឋកិច្ច អាចមានលទ្ធភាពអនុវត្តនយោបាយវាតទឹកដី និងឥទ្ធិពល មកលើបណ្តាប្រទេសទន់ខ្សោយ ដើម្បីរកផលប្រយោជន៍ តើយើងអាចទុកអាណានិគមនិយមនៅក្នុងមែកធំណាបាន?.អាណានិគមនិយម អាចដាក់នៅលើមែកសិទ្ធិអំណាចនិយមក៏បាន សមន្តនិយមក៏បាន អ្វីដែលខុសគ្នា គឺបិតនៅលើរបបសេដ្ឋកិច្ច និងកំរិតពលការនៃអាជ្ញាធរអាណានិគមទៅលើប្រជាជនរស់នៅក្រោមអំណាចអាជ្ញាធរអាណានិគម។

### ១.ការត្រិះរិះនយោបាយខ្មែរនៅក្នុងរយៈពេល ពីឆ្នាំ១៩៣៦ ដល់១៩៤៧

ការត្រិះរិះនេះ កើតចេញដំបូង ក្នុងគំនិតស្នេហាជាតិ ប្រឆាំងនឹងអាណានិគមបារាំង ដែលអ្នកស្នេហាជាតិខ្មែរជំនាន់នោះយល់ឃើញថា អាណានិគមនិយម ជារោគានៅក្នុងខ្លួនជាតិខ្មែរត្រូវចាំបាច់សម្លាប់វាចោល។ សម្លាប់ គឺជាពាក្យប្រៀបនឹងការរំដោះជាតិ ដែលបែកខ្នែងជាពីរមែក ចេញពីមែកអ្នកស្នេហាជាតិៈមែកទី១ គឺគំនិតជាតិនិយម យល់ឃើញថាខ្មែរត្រូវពឹងលើខ្លួនឯងដើម្បីរំដោះជាតិ គំនិតនេះ ផ្ទុយពីមែកទី២ យល់ឃើញថាខ្មែរត្រូវចូលរួមក្នុងចលនារំដោះឥណ្ឌូចិន ដែលជាចលនាដឹកនាំដោយគណបក្សកុម្មុយនិស្តយួន មានខ្មែរ និងលាវជា

គណបក្សប៊ុំណ។ តែគំនិតរំដោះជាតិទាំងពីរនេះ មានទស្សនៈដូចគ្នាមួយ គឺរំដោះជាតិតាមមធ្យោបាយសឹក ព្រោះអាជ្ញាធរអាណានិគម គេប្រឆាំងដាច់ខាតតាមមធ្យោបាយហឹង្សានឹងគំនិតចង់បានឯករាជ្យជាតិពីសំណាក់ប្រជាជនអាណានិគម។ ដូច្នេះតាំងពីដើមទីមកម្លេះ វាមានទំនាស់ជាសារវន្តរួចស្រេច នៅក្នុងទស្សនៈរំដោះជាតិ រវាងខ្មែរអ្នកជាតិនិយម នឹងខ្មែរអ្នកកុម្មុយនិស្តឥណ្ឌូចិន[6]។ ចំណុចមិនស្របគ្នា មានលើបញ្ហាអានាគតនៃកម្ពុជាក្រោមផងនឹងតួនាទីនៃអ្នកដឹកនាំចលនារំដោះផង។ ក្នុងគោលបំណងគណបក្សកុម្មុយនិស្តឥណ្ឌូចិនគឺរំដោះជាតិទាំងបីពីអាណានិគមផង និងឯកភាពប្រទេសយួនផង ក្នុងឯកភាពយួននេះ គឺជាឯកភាពរួមនៃដំបន់តុងកឹង អាណាមនិងកូសាំងស៊ីន(ដែនដីមួយភាគធំនៃកម្ពុជាក្រោម) ក្នុងស្រុកយួនតែមួយឥតអាចបែកចែកបាន។ ដូចខ្មែរដឹងស្រាប់រួចមកហើយ នៅពេលខ្មែរអ្នកជាតិនិយមបង្កើតចលនារំដោះជាតិ«ខ្មែរឥស្សរៈ»នៅក្នុងឆ្នាំ១៩៤៦ ពួកយួនកុម្មុយនិស្តវាយកឈ្មោះនេះមកប្រើដែរ នាំឲខ្មែរយើងជំនាន់នោះមានការច្របូកច្របល់នៅក្នុងគតិរហូតមកដល់ខ្មែរយើងដាក់ឈ្មោះឲពួកខ្មែរចូលយួននោះ ថាខ្មែរយៀកម៊ិញ ដើម្បីបែងចែកឲដាច់ពីខ្មែរឥស្សរៈ។ គោលបំណងយួនចង់ត្រួតត្រាខ្មែរ ដើម្បីរំលាយជាតិខ្មែរ មានជានិច្ចចាប់ផ្ដើមពីសតវត្សទី១៧មកម្លេះ ដូច្នេះការបញ្ចូលទឹកដីកម្ពុជា ឲនៅក្នុងទឹកដីយួនដែលមានចែងនៅក្នុងផែនការរំដោះស្រុកយួនពីអាណានិគមបារាំង ជាការបន្តនយោបាយវាតទឹកដីតែប៉ុណ្ណោះ។

ក្រោយពីសង្គ្រាមលោកលើកទី២ចប់មក ខ្មែរអ្នកជាតិនិយម បែកចេញជាពីរពួក ពួកទី១ គឺខ្មែរឥស្សរៈបន្តសកម្មភាពរំដោះជាតិតាមមធ្យោបាយសឹក ចំណែកពួកទី២ ជាអ្នកជាតិនិយមយល់ឃើញថា ខ្មែរអាចរំដោះជាតិ តាមវិធីអហឹង្សា ដោយយកលទ្ធិប្រជាធិបតេយ្យ និងលក្ខន្តិកៈថ្មីនៃនគរខ្មែរ ជាមធ្យោបាយទាមទារឯករាជ្យពីបារាំង ពួកទី២នេះ ជាអ្នកប្រជាធិបតេយ្យនាំគ្នាបង្កើតគណបក្សនយោបាយ ចូលរួមបោះឆ្នោតលើកទី១នៅក្នុងឆ្នាំ១៩៤៦ ដើម្បីបង្កើតសភាធម្មនុញ្ញ។ នៅក្នុងឆ្នាំ១៩៤៧ ស្រុកខ្មែរ ចាប់ផ្ដើមមានរដ្ឋធម្មនុញ្ញ ជ្រើសរើសរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញជារបបដឹកនាំជាតិ។ របបនេះ មានធាតុជារបបប្រជាធិបតេយ្យសេរីពហុបក្ស នៅក្នុងនោះមាននិន្នាការនយោបាយធំពីរខុសគ្នា ពូកទី១ គឺត្រូវចាំបាច់ទាមទារឯករាជ្យភ្លាមពីបារាំង ដូចយ៉ាងគណបក្សប្រជាធិបតេយ្យ ពួកទី២ គឺត្រូវបន្តធ្វើសហការជាបណ្ដោះអាសន្នជាមួយបារាំង ដើម្បីបក់បោយយកប្រយោជន៍ពីបារាំងមកកសាងជាតិដូចយ៉ាងគណបក្សសេរីភាព ពួកទី២នេះ មានការគាំទ្រពីព្រះមហាក្សត្រសីហនុ។ បារាំង គេឆ្លៀតយកទំនាស់នេះ មកធ្វើជាមធ្យោបាយសំរាប់បន្តការពារប្រយោជន៍របស់គេ។ នៅចំពោះការគំរាមកំហែកកាន់តែខ្លាំងៗពីសំណាក់យួនកុម្មុយនិស្តក្នុងសមរភូមិនៅស្រុកយួន បារាំងបានសុខចិត្តប្រគល់ឯករាជ្យឲខ្មែរនៅក្នុងឆ្នាំ១៩៥៣ ដើម្បីចៀសវាងកុំឲមានកើតសមរភូមិទី

[6] ខ្មែរកុម្មុយនិស្តឥណ្ឌូចិននេះ ក្រោយមកខ្មែរយើងនាំគ្នាហៅថាខ្មែរវៀតមិញ។

២នៅកម្ពុជា តែឯករាជ្យនេះមានជាតិពុលសំរាប់ខ្មែរ ព្រោះបារាំងកាត់ទឹកដីកម្ពុជាក្រោម និងកោះខ្មែរជាច្រើនពីទឹកដីខ្មែរ ការនេះមានការបញ្ជាក់ ឲយើញច្បាស់នៅក្នុងសន្និសិទ នៅទីក្រុងស៊ីណែវ ក្នុងឆ្នាំ១៩៥៤ បារាំងបានប្រគល់ទឹកដីកម្ពុជាក្រោមឲទៅយួន នៅក្នុងក្របខណ្ឌនៃឯកភាពស្រុកយួន ដែលជាការទាមទារដាច់ខាតពីសំណាក់យួនកុម្មុយនិស្ត ទោះបីនៅពេលនោះ មានការចែកជាបណ្ដោះអាសន្ន ស្រុកយួនជាពីរដំបន់នយោបាយក៏ដោយ គឺយួនខាងត្បូង និងយួនខាងជើង។ ពេលនោះសម្ដេចសីហនុ ឃោសនាភូតប្រជាពលរដ្ឋខ្មែរ ថាព្រះអង្គមានជោគជ័យណាស់នៅក្នុងសន្និសិទនៅទីក្រុងស៊ីណែវ ដោយព្រះអង្គជាបិតាឯករាជ្យជាតិ អាចរក្សាឯកភាពកម្ពុជាបាន មិនដូចស្រុកយួនមានចែកទឹកដីជាពីរ តែព្រះអង្គលាក់នូវការបាត់ទឹកដីកម្ពុជាក្រោមទាំងមូល ហើយទឹកដីខ្មែរនេះ ត្រូវបារាំង និងយួន គេស្រុះស្រួលគ្នាទទួលស្គាល់ជាផ្លូវការ នៅក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ថាជាទឹកដីរបស់ស្រុកយួន ដូច្នេះ សន្និសិទនៅទីក្រុងស៊ីណែវ ជាបរាជ័យមួយខ្លាំងណាស់ចំពោះប្រជាជាតិខ្មែរ។ គណៈប្រតិភូខ្មែរ ចូលរួមនៅក្នុងសន្និសិទនោះ គ្រាន់តែជាគណៈប្រតិភូប្រថាប់ត្រា នៃការព្រមព្រាងរវាងបារាំង និងយួន តែប៉ុណ្ណោះ នាំគ្នាចុះហត្ថលេខា តាមបារាំងបង្គាប់ ឥតមានរក្សាទុកចំណុចទឹកដីកម្ពុជាក្រោម ថាខ្មែរនៅរក្សាសិទ្ធិជានិច្ច ថាទឹកដីជាទឹកដី ជាប្រវត្តិសាស្ត្ររបស់ខ្មែរ។ សម្ដេចសីហនុអាចលាក់នូវរឿងអាស្រូវនេះបាន នៅពេលព្រះអង្គមានអំណាច តែព្រះអង្គពុំអាចមានឥទ្ធានុភាពជាអាទិទេព កែឆ្នៃប្រវត្តិសាស្ត្រជាតិខ្មែរ និងមនុស្សជាតិបាននោះឡើយ។

## ២.ការត្រិះរិះនយោបាយខ្មែរនៅក្នុងរយៈពេល ពីឆ្នាំ១៩៤៧ ដល់១៩៥៦

ការត្រិះរិះខ្មែរនៅក្នុងរយៈពេលនោះ គឺការពារលទ្ធិប្រជាធិបតេយ្យនៅចំពោះមុខការប៉ុនប៉ងនូវវិវឌ្ឍនៃរបបរាជាធិបតេយ្យ។ ដូចយើងធ្លាប់បានលើកវាយកមកពិពណ៌នាពីមុនរួចហើយ ថាសម្ដេចសីហនុ ទ្រង់មិនដែលសុខចិត្តសុខកាយ ទទួលស្គាល់រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៤៧នោះទេព្រោះវា ជាការប្រមាថនឹងព្រះចេស្តាព្រះមហាក្សត្រខ្មែរ ដូច្នេះព្រះអង្គប្រើមធ្យោបាយគ្រប់បែបយ៉ាងឥតលជ្ជីភាពតាមតែវិចិន្តា ដោយមានជំនួយពីបារាំងផង ដើម្បីសម្លាប់លទ្ធិប្រជាធិបតេយ្យនេះឲបានជាដាច់ខាត។ ព្រះអង្គទទួលបានវិជ័យ ព្រោះអ្នកប្រជាធិបតេយ្យខ្មែរភាគច្រើនជាអ្នកឪកាសនិយម ប្រែប្រួលចិត្តគំនិតទៅតាមផលប្រយោជន៍ដែលខ្លួនអាចរកបានសំរាប់ខ្លួនផ្ទាល់ ដូចយ៉ាង អ្នកចេះដឹក យកចំណេះរបស់ខ្លួនទៅដូរនឹងយសស័ក្តិបានកម្រៃច្រើន អ្នកល្ងង់ យកកម្លាំងបាយ ទៅបំរើអ្នកមានអំណាច ដើម្បីឧត្តជីវិត ដែលខ្លួនទុកជាលាភ រាស្ត្រមិនរឹងរូស សុខចិត្តទ្រាំរស់ក្នុងភាពតោកយ៉ាក ព្រោះចង់បានសុខកាយតែមួយពេល។ អត្តទត្តភាពជាទូទៅនេះ វាជាជម្ងឺគ្រាំគ្រែងរបស់ជាតិខ្មែរ ស្ទើរតែគ្មានឪសថណាអាចព្យាបាលវាបាន។

ការត្រិះរិះនយោបាយខ្មែរលើលទ្ធិប្រជាធិបតេយ្យមានលក្ខណៈបែបណា?

ចំពោះអ្នកប្រជាធិបតេយ្យខ្មែរជំនាន់នោះ យល់ឃើញថាសេរីភាព និងការជឿនលឿន ជាគូរនឹងគ្នា ហេតុនេះឯង អ្នកទាំងនោះជ្រើសរើសយកលទ្ធិប្រជាធិបតេយ្យសេរីជាគោលនៃការត្រិះរិះនយោបាយរបស់ខ្លួន។ គេអាចសួរជាសំណួរថា តើលទ្ធិប្រជាធិបតេយ្យសេរី វាជាល់អានអាចយកវា មកអនុវត្តិបានក្នុងសង្គមខ្មែរ នៅពេលនោះ វាកំពុងមានបរិវត្តន៍ ពីសង្គមបុរាណទៅរកសង្គមនៃអន្តរភាព ដែរឬទេ?

ក្នុងវិការនេះ លោក Aristote ពិចារណាថា ដំណាក់កាសនៃអន្តរភាព វាច្រើនតែមានកើតអំពើកំណាចក្នុងសង្គម ការសង្កេតនេះ គេឃើញមានកើតពិតមែន នៅក្នុងបដិវត្តន៍បារាំងក្នុងសតវត្សទី១៨។ ចំណែកលោកMontesquieu វាយតម្លៃថា នៅក្នុងសង្គមនៃបណ្តាប្រទេសអាស៊ី ដែលទុកសេវភាព ជាទម្លាប់ក្នុងការរស់នៅរបស់ប្រជាជន យកវាមកផ្សាំនឹងសេរីភាពគឺពិតជាការលំបាកមួយខ្លាំងណាស់។ សួរថា តើសេចក្តីអះអាងនេះ វាមានសេចក្តីពិតដែរឬទេ? ចម្លើយមាននៅក្នុងឧទាហរណ៍ក្នុងទីនេះ ដូចនៅប្រទេសឥណ្ឌា សៀម ហ្វីលីពិន ម៉ាឡេយ៉ូ កូរ៉េខាងត្បូង អាំងដូណេស៊ី ជប៉ុន អ្នកនយោបាយគេ ស្រុះស្រួលគ្នាយកលទ្ធិប្រជាធិបតេយ្យសេរីមកអនុវត្តន៍ប្រកបដោយជោគជ័យ។ តើអ្វីជាសោនៃភាពជោគជ័យនេះ?

គួរកត់សំគាល់ដែរថា នៅក្នុងរយៈពេលពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៥៦ លទ្ធិកុម្មុយនិស្តចាប់ផ្តើមមានឥទ្ធិពលបណ្តើរៗនៅក្នុងមជ្ឈដ្ឋានអ្នកប្រជាធិបតេយ្យខ្មែរ ព្រោះមកពីចំហាយជ័យជំនះនៃគណបក្សកុម្មុយនិស្តចិន លើអ្នកជាតិនិយមចិន នៅស្រុកចិន វាហើរចូលមកក្នុងដំបន់មជ្ឈិមបូព៌ាប្រទេស ជ័យជំនះនេះជាលាភមួយដល់គណបក្សកុម្មុយនិស្តឥណ្ឌូចិន ដឹកនាំដោយយួនកុម្មុយនិស្ត វាយកលទ្ធិនេះមកឃោសនានៅក្នុងស្រុកខ្មែរ ពន្យល់ប្រជាជនថាជាមធ្យោបាយតែមួយគត់ អាចយកវាមកវាយដេញបារាំងចេញពីឥណ្ឌូចិន ដូច្នេះជនជាតិទាំងបី ខ្មែរ លាវ និងយួន ជាទន្លេបីពិតមែន តែកំពុងហូរចូលទៅកាន់មហាសាគរតែមួយ ដែលមានឈ្មោះថាឥណ្ឌូចិន ដូច្នេះត្រូវចាំបាច់រួមគ្នា ដើម្បីកំចាត់ចក្រពន្តិបារាំង។ ក្នុងទស្សនៈទីដល់តែមួយនេះឯងហើយ យួនកុម្មុយនិស្ត វាទុកជនជាតិទាំងបីនេះ ជាមូលដ្ឋានចិត្ត និងសហគម សំរាប់បំរើមហិច្ឆតាវាទទឹកដីវា។ តែទោះបីយ៉ាងណាក៏ដោយ ទស្សនៈយួននេះគ្មានឯកភាពក្នុងជួរអ្នកកុម្មុយនិស្តខ្មែរឡើយ ដែលនាំបង្កើតឲមានទំនាស់មិនចេញមុខ រវាងអ្នកជឿលើយួនកុម្មុយនិស្ត និងអ្នកយកចិនកុម្មុយនិស្តជាល់អាន។

### ៣.ការត្រិះរិះនយោបាយខ្មែរនៅក្នុងរយៈពេល ពីឆ្នាំ១៩៥៦ ដល់១៩៦៥

នៅក្នុងឆ្នាំ១៩៥៦ សម្តេចសីហនុ បានដណ្តើមអំណាចបានទាំងអស់ អំណាចមហាក្សត្រ អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ដូច្នេះអំណាចនៅស្រុកខ្មែរចាប់ពីឆ្នាំង១៩៥៦ ជាអំណាចផ្តាច់ការ មានលក្ខណៈជាសមន្តនិយម។ ក្នុងរបបផ្តាច់ការនេះ រុញឲអ្នកប្រជាធិបតេយ្យជ្រើសរើសផ្លូវពីរផ្ទុយគ្នាដាច់ខាតៈទី១ ចុះចូលសីហនុ ទី២ ប្រឆាំងនឹង

ស្តេចសីហនុ។ ដូចធ្លាប់បានជំរាបខាងលើរួចមកហើយ អ្នកប្រជាធិបតេយ្យ ភាគច្រើនបានចុះចូលសីហនុតាំងពីយូរយារមកហើយ ដែលជាកត្តានាំឲសម្តេចសីហនុមានលទ្ធភាព ដណ្តើមអំណាចបានយ៉ាងងាយស្រួល។ នៅសល់អ្នកក្រាញ តែលើកនេះ ត្រូវនាំគ្នាបិទមាត់ ឬនាំគ្នារត់ចូលព្រៃទៅចូលជាមួយពួកខ្មែរសេរី ឬចូលបំរើអង្គការកុម្មុយនិស្តលួចលាក់ ពុំនោះទេ គឺច្បាស់ជាសម្តេចសីហនុចោទជាជនក្បត់ជាតិជាពុំខាន។

ក្នុងខណៈនោះ មានបញ្ញវន្ត ជាអ្នកជឿនលឿននិយម មានសញ្ញាប័ត្រថ្នាក់បណ្ឌិតពីប្រទេសបារាំង លោកហ៊ូ.យន់ ហ៊ុយ.នឹម និងខៀវ.សំផន នាំចូលមកក្នុងស្រុកខ្មែរ នូវការត្រិះរិះសេដ្ឋកិច្ចបែបសង្គមនិយម។ ការត្រិះរិះនេះ ជាដំបូង ធ្វើឲសម្តេចសីហនុមានការយកចិត្តទុកដាក់ ព្រោះទ្រង់យល់ឃើញថា វាអាចមានប្រយោជន៍ដល់នយោបាយរបស់ព្រះអង្គ តែក្រោយមក ទ្រង់ចាប់ផ្តើមមានទំនាស់ជាមួយបញ្ញាវន្តទាំងនោះ ព្រោះព្រះអង្គចោទជនទាំងនោះថាមានលាក់មនោគមវិជ្ជាកុម្មុយនិស្ត ដែលព្រះអង្គទុកវា ជាសត្រូវទី២របស់ទ្រង់ បន្ទាប់ពីខ្មែរសេរី ដែលទ្រង់ទុកជាសត្រូវទី១។ ទំនាស់នេះ តម្រូវឲបញ្ញាវន្តទាំងបីរត់ចូលព្រៃទៅចូលបំរើអង្គការកុម្មុយនិស្ត ដែលមានយួនកុម្មុយនិស្តជាអ្នកពិនិត្យត្រួតត្រាលើខ្មែរនៅឡើយ។

បើយើងធ្វើសង្ខេបនៃការត្រិះរិះនយោបាយខ្មែរតាំងពីឆ្នាំ១៩៣៦មក យើងឃើញមានការវិវឌ្ឍន៍ ពីគំនិតប្រឆាំងអាណានិគម ប្រឆាំងនឹងការវិលត្រឡប់នៃរបបរាជាធិបតេយ្យ ប្រឆាំងនឹងរបបសមន្តនិយម(សង្គមរាស្ត្រនិយ) រហូតមកដល់នឹងការប្រឆាំងនឹងបុគ្គលសីហនុ ដែលខ្មែរអ្នកប្រជាធិបតេយ្យក្តី អ្នកកុម្មុយនិស្តនិយមក្តី ទុកបុគ្គលសីហនុជាឧបសគ្គធំបំផុត នៃការរិកចំរើន នៃសង្គមខ្មែរ និងសេរីភាពនៃប្រជាពលរដ្ឋខ្មែរ។ ការប្រឆាំងនោះមានគោលបំណងច្បាស់លាស់ណាស់ នៅក្នុងការត្រិះរិះនយោបាយរបស់អ្នកប្រជាធិបតេយ្យ៖

១.ប្រឆាំងនឹងអាណានិគម ដើម្បីឯករាជ្យ,

២.ប្រឆាំងនឹងរបបរាជាធិបតេយ្យ ដើម្បីការពាររដ្ឋធម្មនុញ្ញ,

៣.ប្រឆាំងនឹងរបបសមន្តនិយម ដើម្បីប្រត្យាស្ថាបនាលទ្ធិប្រជាធិបេតយ្យ,

៤.ប្រឆាំងនឹងបុគ្គលសីហនុ ដើម្បីការពារប្រយោជន៍ជាតិ។

## ការប្រើពាក្យ៖

ដើមកំណើត=Genèse;ការត្រិះរិះនយោបាយ=Pensée politique;ប្រជារាស្ត្រ=Sujets;ពលរដ្ឋ=Citoyen;បុញ្ញាកិរិយា=Action méritoire;ការកកើត=Formation;ភូមិ=Domaine;ប្រជាជន=Population;ដំណេកកម្លាំងនយោបាយ=Force politique dormante;របបសមន្តនិយម=Totalitarisme;ស្តេច=Prince;ពលការ=Coercition;វិលោម=Inverse;;ខ្នែង=Ramification;សិទ្ធិអំណាចនិយម=Autoritarisme;សង្គមជាតិនិយម=National-socialisme;គណបក្សបុរំណ=Parti supplétif;សារវន្ត=Fondamental;លជ្ជីភាព=Honte;បរិវត្តន៍=Mutation;អន្តរភាព=Transition;សេវភាព=Servitude;វិការ=transformation;មូលដ្ឋានចិត្ត និងសហគម=Base sentimentale et communautaire។

# ៧

## សម័យឯករាជ្យ

## សម័យសង្គមរាស្ត្រនិយម

## ៣. រយៈពេលពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៧០

### ការបង្វែរទិសនយោបាយ

ដូចយើងដឹងរួចហើយ ក្រោយពេលដែលសម្តេចសីហនុបង្កើតចលនាសង្គមរាស្ត្រនិយម ដែលជារបបមានធាតុផ្ទុយស្រឡះពីរបបប្រជាធិបតេយ្យសេរី ទ្រង់ចាំបាច់បង្វែរទិសនយោបាយ ដើម្បីរកការគាំទ្រលើឆាកអន្តរជាតិដល់នយោបាយរបស់ទ្រង់។ ដោយធាតុចលនាសង្គមរាស្ត្រនិយមជាអំណាចផ្តាច់ការ ដូច្នេះព្រះអង្គបានជ្រើសរើសយករបៀបដឹកនាំកុម្មុយនិស្តមកធ្វើជាគំរូនៃការដឹកនាំរបស់ទ្រង់ ដូចយ៉ាងមានៈគណបក្សនយោបាយតែមួយ មនោគមវិជ្ជានយោបាយតែមួយ និងអនុវត្តនូវជំនឿទុកបុគ្គលព្រះអង្គជាព្រះ។ លក្ខណវិនិច្ឆ័យទាំងបីនេះហើយ ដែលជាការបង្ហាញនូវធាតុរបបសង្គមរាស្ត្រនិយមជារបប**សមស្តនិយម**[7] ក្នុងចំណុចជ្រើសរើសរបៀបដឹកនាំកុម្មុយនិស្តមកធ្វើជាគំរូនេះទៀត ស្តេច[8]សីហនុធ្វើការបែងចែកនូវរបៀបដឹកនាំ និងមនោគមវិជ្ជា ទ្រង់ទុកមនោគមវិជ្ជាកុម្មុយនិស្តជាសត្រូវក្នុងប្រទេស តែយករបៀបដឹកនាំផ្តាច់ការរបស់វា មកអនុវត្តៈ ជាសត្រូវ ព្រោះរបបកុម្មុយនិស្ត វាជារបបប្រឆាំងនឹងវណ្ណៈ ហើយវាយរំលាយវណ្ណៈ ប៉ុន្តែរបៀបដឹកនាំរបស់វា ជារបៀបមានធម្មជាតិ មិនសូវខុសគ្នាពីរបបរាជាធិបតេយ្យនោះទេ គឺអំណាចទាំងអស់ វាថិតនៅលើដៃអ្នកដឹកនាំតែម្នាក់គត់។ ការបង្វែរទិសនយោបាយនេះ ស្តេចសីហនុយកសសរបីមកធ្វើជាចន្ទល់នយោបាតថ្មីរបស់ទ្រង់ ៖ នយោបាយអព្យាក្រិត នយោបាយសង្គមនិយម នយោបាយប្រជាភិថុតិ។ ទី១ ជានយោបាយការបរទេស, ទី២ ជានយោបាយសេដ្ឋកិច្ច និង ទី៣ ជានយោបាយក្នុងប្រទេសៈ

### ១.នយោបាយប្រជាភិថុតិ

នយោបាយប្រជាភិថុតិ ជានយោបាយផ្ទៃក្នុង ប្រើសំរាប់បោកបញ្ឆោតទឹកចិត្ត**ប្រជាជន**[9] តាមវិធីបិយ៉ាងៈ ទី១.ធ្វើសុន្ទរកថាយ៉ាងយូរ និយាយសរសើរតែខ្លួនឯង បង្ហាញនូវការសម្បាយ

---

[7] សមស្តនិយម=Totalitarisme។
[8] ស្តេច=Prince។
[9] ប្រជាជន=Population;ប្រជាពលរដ្ឋ=Peuple;ប្រជារាស្ត្រ ឬរាស្ត្រ=Sujets;មហាជន=Masse។

វិករាយហួសហេតុលើគ្រប់ទុក្ខ ឬបញ្ហារបស់សត្រូវរបស់ខ្លួនដែលកំពុងជួបប្រទេះ បើស្តាប់ហើយ ឃើញនូវកាយវិការវិញ ហាក់បីឃើងព្ទ ឬ ឃើញបុគ្គលមួយដែលមាន**ជម្ងឺសតិ”វវក់”**[10] ដូច មនុស្សឆ្កួតជ្រូក និយាយឲបានតែនិយាយ ព្រោះគ្មាននរណាហ៊ាននិយាយជំទាស់។ ការនេះជា សញ្ញានៃលក្ខណៈជនផ្តាច់ការ និយាយពន្យល់គេ តែមិនដែរហ៊ានធ្វើការពិភាក្សាផ្ទុយគ្នា ដែល ជាគំនិតជំទាស់ទល់មុខគ្នានោះឡើយ ហើយនៅពេលណា មានជនណាម្នាក់គេហ៊ាន សួរ ឬ ឲ យោបល់ផ្ទុយពីខ្លួន គឺទុកជននោះជាសត្រូវខ្លួនមួយរំពេច។ ទី២. ធ្វើការចែកអំណោយដល់ រាស្ត្រ ដើម្បីទាក់ទាញឲមកស្វាគមន៍ខ្លួន អង្គុយស្តាប់ខ្លួននិយាយរាប់ម៉ោងកណ្តាលថ្ងៃត្រង់ កែនអ្នកស្រែចំការ អ្នករាជការ សិស្សានុសិស្ស ឲមកចាំទះដៃអបអរសាទរជាអាទ៍។ ទី៣ និយាយ ឲរាស្ត្រសប្បាយដូចអ្នកកំប្លែង យកវេទិការជាតិធ្វើជារោងអាយ៉ៃ។ ទិដ្ឋភាពទាំងបី នេះ គឺទុកដូចជាការបង្ហាញ នូវសិល្បៈសីហនុដើម្បីជាការកំសាននោះឯង។ រួមសេចក្តីមក គេ អាចចាត់ទុកស្តេចសីហនុជាមេដឹកនាំអវិជ្ជា គ្មានមានអ្វីបន្តិចសោះដែលអាចចាត់ទុកជា «មនុស្សទៀងត្រង់» ជាជនប្រឆាំងនូវគ្រប់ «បញ្ហា» ដែលមាននៅក្នុងប្រទេស ហេតុនេះឯង បានគេឃើញសីហនុសំដែងនូវការជំទាស់ជានិច្ចនឹងបញ្ញាវន្ត និងអ្នកមានសញ្ញាប័ត្រជាទូទៅ ទ្រង់តែងតែប្រឆាំងនឹងជនណាដែលគេមានវប្បធម៌ ឬ មានការយល់ដឹង[11] ក្នុងខ្លួន ដែល សីហនុខ្លួនឯងគ្មាន។

## ២.នយោបាយសង្គមនិយម

ជានយោបាយសេដ្ឋកិច្ចបែបសង្គមនិយម យកវាមកធ្វើជានយោបាយអភិវឌ្ឍជាតិ ឈប់ ទទួលជំនួយសហរដ្ឋអាមេរិក និងលោកសេរី តែបែជាទទួលជំនួយចិន និង លោកកុម្មុយនិស្ត ដោយចោទប្រកាន់ថាជំនួយអាមេរិកជាជំនួយមានចំណង ឯជំនួយចិនប្រជាមានិតវិញជា ជំនួយឥតមានចំណង។ ជម្រើសនេះគឺសំរាប់តែយកវា មកបំរើនយោបាយផ្ទាល់ខ្លួនព្រះអង្គ តែប៉ុណ្ណោះ ព្រោះទ្រង់មានជំនឿថាចិនគេការពារអំណាចសីហនុ ឯអាមេរិកាំងវិញ គេឲជំនួយ ដើម្បីការពារប្រយោជន៍ប្រជាពលរដ្ឋខ្មែរ ការពារលទ្ធិប្រជាធិបតេយ្យ ដូច្នេះគេមិនការពារ ប្រយោជន៍បុគ្គលនោះឡើយ។ ក្នុងទស្សនៈបែបនេះឯងហើយ ដែលវានាំ រំខានដល់ស្តេចសីហនុ ក្នុងការទទួលជំនួយសហរដ្ឋអាមេរិក។ ជំនួយអាមេរិកាំង ដែលសីហនុលើកមកធ្វើរូបមន្ត ឃោសនាពន្យល់រាស្ត្រ ថាជាជំនួយមិនល្អនោះ ឬ មានចំណង តែការពិតចំណងនោះគឺសហរដ្ឋ អាមេរិក គេមានល័ក្ខខណ្ឌគេមួយច្បាស់លាស់ គឺហាមដាច់ខាតមិនឲយកជំនួយនេះមកប្រើ សំរាប់ប្រឆាំងនឹងប្រយោជន៍សហរដ្ឋអាមេរិកតែប៉ុណ្ណោះ ដូច្នេះបើអ្នកណាមានការយល់ដឹង គឺ មិនអាចទុកល័ក្ខខណ្ឌនេះ ជាការមិនត្រឹមត្រូវនោះឡើយ។ ឯចំណែកជំនួយចិនប្រជាមានិត វិញ គ្មានខសំខាន់បែបអាមេរិកាំងមែនពិត តែយើងឃើញស្រាប់ហើយ តើចិនឆ្លៀតទាញយក ផលប្រយោជន៍ពីខ្មែរបែបណាដើម្បីយកទៅជួយយួនកុម្មុយនិស្ត តែទង្វើនេះ សីហនុ ទ្រង់ធ្វើជា

[10] ជម្ងឺសតិវវក់=Manie។ ជម្ងឺកើតពីទម្លាប់អាក្រក់។
[11] ការយល់ដឹង=Le bon sens។

មើលពុំឃើញ ព្រោះចិន គេជានាការពារអំណាចសីហនុ។ ចំពោះសីហនុ ខសន្យាចិននេះ វាគ្រប់គ្រាន់សំរាប់ព្រះអង្គ ទោះបីជាតិស្លាប់ វាគគឈឺក្បាលអ្វីដល់ទ្រង់នោះឡើយ។ នេះហើយនយោបាយសង្គមនិយមរបស់ស្តេចសីហនុ!

ស្រុកខ្មែរជំនាន់នោះ ជាប្រទេស**ឧនាភិវឌ្ឍ**[12] តែសីហនុស្រែកប្រាប់រាស្ត្រថា ជាកោះសន្តិភាពមានគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច អប់រំជាតិ។ ល។ អស់រយៈពេលដប់ឆ្នាំ (១៩៥៦-១៩៦៦)ស្តេចសីហនុជាអ្នកដឹកនាំផ្តាច់ការ ដឹកនាំវិស័យទាំងបីដែលបានរៀបរាប់ខាងលើនេះទៅរកជនក្ស័យ ព្រោះគម្រោងអភិវឌ្ឍន៍ដែលសីហនុបង្កើតខ្លួនឯង មិនដែលបានសំរេចដូចការគ្រោងទុក ព្រោះសីហនុតែងតែមានចំណង់ចម្លែក ដូរតាមតែខ្លួនយល់ឃើញ នាំឲ្យអ្នកដឹកនាំខ្មែរឯទៀតៗលែងដឹងថាសីហនុចង់បានអ្វីពិតប្រាកដ។ ការផ្លាស់ប្តូររបស់សីហនុនេះ លោក Charles Mayer កត់សសំគាល់ថា «*ចាប់ពីខែវិច្ឆិកាឆ្នាំ១៩៦៦ ស្តេចសីហនុ ក្លាយជាមនុស្សរវើរវាយ។ ទ្រង់ឆ្លងរយៈពេលទព្វលភាព ហាក់បីដូចដើរឆ្លងផ្លូវទទេស្អាតជាច្រើន ពីផ្លូវសប្បាយរីករាយចិត្តខ្លាំង ទៅរកផ្លូវកោលាហល*» លោកបន្តថា «*ទ្រង់ក្លាយជាមនុស្សឆាប់ខឹងចងគំនុំ បញ្ជាឲចាប់ដាក់គុកជនណាដែលទ្រង់សង្ស័យថាជាអ្នកកុម្មុយនិស្ត "មៅនិយម" ដេរប្រមាថគេឯង*»។

ការបារម្ភរបស់ស្តេចសីហនុ វាមានហេតុផល ព្រោះសហរដ្ឋអាមេរិកបានសំរេចចិត្តធ្វើអន្តរាគមន៍ ដោយចំពោះនៅក្នុងសង្គ្រាមនៅប្រទេសយៀកណាម គឺក្នុងថ្ងៃទី៨មិនាឆ្នាំ១៩៦៦ លោកប្រធានាធិតី L. Johnson បានបញ្ជាឲកងទ័ពអាមេរិកាំងមកបោះទ័ពនៅក្នុងខេត្ត Da Nang នៅក្នុងប្រទេសយួនខាងត្បូង។ បេសកកម្មរបស់កងទ័ពនេះគឺៈ ការពារសេរីភាពរបស់ប្រជាពលរដ្ឋនៃយុវសាធារណរដ្ឋយៀកណាមខាងត្បូង ដែលកំពុងទទួលការគំរាមកំហែងពីសំណាក់កម្លាំងកុម្មុយនិស្ត នៅអាសុី ជាពិសេសនៅដំបន់អាសុីអគ្នេយ៍ មាន ចិន និង យួនកុម្មុយនិស្ត ជាអ្នកបង្កហេតុ។

នរណាក៏ដឹងដែរថា ស្តេចសីហនុ ចាប់ពីឆ្នាំ១៩៦៣មក ទ្រង់ដូរនយោបាយអព្យាក្រិត្យ ១៨០° បែទៅជួយជ្រោមជ្រែងយួនកុម្មុយនិស្ត តាមការស្នើរសូមពីចិនប្រជាមានិត ដូចយ៉ាងអនុញ្ញាតឲកងទ័ពយៀកកុង រាប់ម៉ឺននាក់ មកតាំងជំរុំសឹកនៅក្នុងទឹកដីខ្មែរ ដើម្បីវា ស្រួលងាយវាយ ប្រហារយួនខាងត្បូង និង ទ័ពអាមេរិកាំង នៅវៀតណាម។ ក្នុងឆ្នាំ១៩៦៣នោះដែរយួនកុម្មុយនិស្ត ចាប់ផ្តើមបង្កើត ឲមាន មូលដ្ឋានបដិវត្តខ្មែរកុម្មុយនិស្ត ផ្នែកយោធា នៅក្នុងទឹកដីខ្មែរ ដើម្បីទុកធ្វើជា **អាធារពស្តុភារ**[13] ក្នុងគោលបំណងសំរួល ការវិលត្រឡប់ ខ្មែរយៀកម៉ិញដើម្បីពង្រីកសកម្មភាពបដិវត្តន៍យោធាក្នុងដែនដីខ្មែរ មួយវិញទៀត គឺដើម្បី ពង្រីកពង្រិច មូលដ្ឋានសេដ្ឋកិច្ចសង្គ្រាម ដោយនាំចូល ជនជាតិយួន ដែលមានចិត្តស្រឡាញ់កុម្មុយនិស្ត មកប្រកប របររកស៊ី តាមច្រាំងទន្លេប៉ាសាក់ និង មេកុង។ មកដល់ឆ្នាំ១៩៦៦-១៩៦៧ ជនជាតិយួនទាំងនោះ បាននាំគ្នា បន្តដំណើរតាមទូក រហូតមកដល់ ខេត្តតាកែវ និង ខេត្ត

[12] ឧនាភិវឌ្ឍ=Sous-développement គ្មានការចម្រើន។
[13] អាធារពស្តុភារ= ជំនួយជាជាសម្ភារៈយោធា Support logistique។

ពោសាត់ រួចមកតាំង ជម្រោគអណ្តែត ក្នុងបឹងទន្លេសាបតែម្តង។ ដោយមានជំនួយនយោ-បាយ ពីស្តេចស៊ីហនុផង យួនកុម្មុយនិស្ត អាចបង្កើត មូលដ្ឋានសេដ្ឋកិច្ច សំរាប់ជាជំនួយសង្គ្រាម ជាច្រើន នៅក្នុងស្រុកខ្មែរ មាននៅៈ ស្រុកពាមឈរ គុងហុង ទូកមាស ។ ល។ ដោយយកខេត្ត ពោសាត់ ជាមូលដ្ឋានធំ។

ដូចបានជំរាបខាងលើរួចមកហើយ អន្តរាគមន៍ដោយចំពោះ កងទ័ពអាមេរិកាំងនៅវៀតណាមខាងត្បូងក្នុងខែមីនាឆ្នាំ១៩៦៦ នាំឲស្តេចសីហនុ ពីបាកលាក់បាំងការអនុញ្ញាត ឲយួនកុម្មុយនិស្ត ប្រើទឹកដី ដើម្បីធ្វើសង្គ្រាមប្រឆាំងទ័ពអាមេរិកាំងនៅវៀតណាមខាងត្បូង។ ជំនួយនេះ បង្ខំឲអាមេរិកាំងធ្វើអន្តរាគមន៍ជាសំងាត់តាមផ្លូវសឹក ចូលមកក្នុងទឹកដីខ្មែរ តាមការទំលាក់គ្រាប់បែក លើមូលដ្ឋានសឹកយៀកកុង នៅក្នុងស្រុកខ្មែរ ដែលនាំឲប្រជាជនខ្មែរ រស់នៅក្បែរមូលដ្ឋានសឹកយៀកកុង ទទួលរងគ្រោះអំពីការទំលាក់គ្រាប់បែកនេះ ដូចយ៉ាងនៅភូមិចន្ទ្រាក្នុងខេត្តស្វាយរៀងនៅក្នុងឆ្នាំ១៩៦៦ជាអាទ៍។ ប្រតិកម្មយួនកុម្មុយនិស្តក្នុងដំណាក់ការថ្មីនេះ គឺវា បង្ខំឲខ្មែរកុម្មុយនិស្ត បង្កើនសកម្មភាព វិទ្ធង្សនា ដើម្បីឲមានអសត្ថិសុខនៅក្នុងស្រុកខ្មែរ ដូចយ៉ាងមានការបោះខិតប័ណ្ណ ក្នុងស្រុកបារាយ (មណ្ឌលលោកហុយ-នឹម) ប្រឆាំង នឹងរាជរដ្ឋាភិបាល ដឹកនាំដោយ លោក លន់-នល់ ដោយចោតប្រកាន់ថា ជារដ្ឋាភិបាលខ្ញុំអាមេរិកាំង។ ខិតប័ណ្ណ អំពាវនាវ ឲប្រជាជនរត់ចូលព្រៃ ដើម្បីធ្វើកាតតស៊ូប្រឆាំង នឹងអាមេរិកាំង។ រាជរដ្ឋាភិបាល ដឹកនាំដោយ លោក លន់-នល់ ជាសត្រូវ នឹងយៀកកុង ព្រោះរដ្ឋាភិបាលនេះ ធ្វើនយោបាយ ទប់មិនឲអ្នកកសិករ លក់ស្រូវឲយៀកកុងតាមផ្សាខ្មៅ ដោយបង្កើតអង្គការពិសេស សំរាប់ទិញស្រូវពីកសិករ។ តែនយោបាយនេះ នាំឲប្រជាកសិករ មិនសប្បាយចិត្ត ព្រោះគាត់អាចលក់ឲយៀកកុង ដោយបានតម្លៃ៣ដង លើសពីតម្លៃទិញរបស់រាជរដ្ឋាភិបាល។ ឧទាហរណ៍ នៅភូមិសំឡូតក្នុងខេត្តបាត់ដំបង យៀកកុង ឆ្លៀតយក កំហុសខ្លះពីសំណាក់ អ្នករាជការ និងនាយទាហ៊ានខ្លះ ក្នុងរឿងទំនាស់ដីថ្លីជាមួយប្រជាជន បញ្ឆេះប្រជាជនឲបះបោរប្រឆាំង នឹងរាជរដ្ឋាភិបាល។ សីហនុ ភ័យខ្លាច គេចបញ្ហា ទុកឲរដ្ឋាភិបាលមានទំនាស់ជាមួយប្រជាកសិករ យាងចេញពីស្រុកខ្មែរ នៅថ្ងៃទី៦មករាឆ្នាំ១៩៦៧យ៉ាងបន្ទាន់បំផុត។ ក្នុងការបះបោរនេះ យៀកកុងបញ្ជា ឲក្រុបខណ្ឌយៀកម៉ិញ ចេះនិយាយខ្មែរច្បាស់ កំពុងធ្វើបេសកកម្មនៅស្រុកសៀម ចូលមកក្នុងដំបន់សំឡូត ដើម្បីរៀបចំឲមានកាតតស៊ូតាមផ្លូវអាវុធជាមួយកងទ័ពជាតិខ្មែរ នាំឲមានផ្ទុះអាវុធបន្តិចបន្តួច និង ការភាសប្រជាកសិកេមួយចំនួនធំ រត់ទៅពួននៅក្នុងព្រៃ។

ក្នុងខែកុម្ភៈឆ្នាំ១៩៦៧ ពួកកុម្មុយកុម្មុយនិស្តនាំគ្នា នាំគ្នាបោះខិតបណ្ណ រិះគន់សីហនុ ចោទប្រកាន់ថាទ្រង់ទៅរស់នៅប្រទេសបារាំង ចាយលុយរាស្ត្រខ្មែរ រកសេចក្តីសុខ។ ខិតបណ្ណនេះ ធ្វើឲសីហនុមានកំហឹងខ្លាំងណាស់ ពេលទ្រង់យាងត្រឡប់មកស្រុកខ្មែរវិញ នាថ្ងៃទី៩មីនា មួយថ្ងៃបន្ទប់មក ទ្រង់បានឆ្លើយតម នឹងខិតបណ្ណថា ទ្រង់នឹងដឹកនាំប្រជាពលរដ្ឋទៅរកសង្គមនិយម តែដាច់ខាត មិនធ្វើនយោបាយ ដើរទៅចូលក្នុងលទ្ធិកុម្មុយនិស្តនោះឡើយ។ ថ្ងៃទី១១

មីនា ខៀវ-សំផន ដឹកនាំមហាបាតុកម្ម ដ៏ធំមួយនៅភ្នំពេញ ដើម្បីសំដែងការគាំទ្រនយោ-បាយស្តេចសីហនុ តែគោលបំណងធំ  គឺទាមទារ ឲលោក លន់-នល់ លារលែងពីដំណែងនាយករដ្ឋមន្ត្រី ឯណោះទេ។  សីហនុ ឆ្លើយតបនឹងមហាបាតុកម្ម តាមការកោះប្រជុំសមាជជាតិវិសា-មញ្ញមួយ អញ្ជើញ សមាជិកខ្មែរយៀកម៉ិញ ឲចូលរួមក្នុងសមាជជាតិនេះ។  អ្វីដែលគួរឲចំឡែក គឺវាគ្និន ដែលជាសមាជិកខ្មែរយៀកម៉ិញ ឡើងថ្លែងថា ពួកខ្លួន មានការអាណិតអាសូរដល់ជនជាតិយួន ដែលបានមករស់នៅក្នុងស្រុកខ្មែរ នៅតាមទល់ដែន ខ្មែរ-យួន មានការភិតភ័យខ្លាំងណាស់ ពីការលុកលុយ នៃទ័ពវៀតណាមខាងត្បូង និង អាមេរិកាំង មកក្នុងទឹកដីខ្មែរ ដើម្បីមកធ្វើបាបខ្លួន ដូច្នេះ វាគ្និននេះ បានសូមស្នើដល់សីហនុ ឲផ្តល់អាវុធដល់ជនជាតិយួនទាំងនោះ ដើម្បីអាចនឹងការពារខ្លួនបាន។  សេចក្តីស្នើនេះ នាំឲ អ្នកចូលរួមលក្នុងសមាជជាតិពេលនោះ មានការផ្ទាក់ផ្អើលជាខ្លាំង តែបែរជានាំគ្នាយល់ក្នុងចិត្តថានេះជា ឧត្តមនយោបាយរបស់សម្តេចឪ។

គួរលើករឿងឧត្តមនយោបាយសម្តេចសីហនុមួយមកនិទាន ជូនមិត្តអ្នកអាន ៖

លោក វរសេនីយឯក ហ្វៃណង់ដេរ-សូស្តែន រដ្ឋលេខាធិការ ក្រសួងសន្តិសុខ នៅក្នុងរាជរដ្ឋាភិបាល ដឹកនាំដោយលោក លន់-នល់ ជំនាន់នោះ មានដើមគំនិត ធ្វើអង្កេត អំពីទីតាំងមូលដ្ឋានសឹក យួនកុម្មុយនិស្ត នៅក្នុងដែនដីខ្មែរ។  ក្រោយពីបានដឹងច្បាស់ គ្រប់ទីតាំងមូលដ្ឋានសឹកពួកយៀកកុងរួចហើយ លោក វរសេនីយឯក បានយកឯកសារនេះ ទៅប្រាប់ លោក វរសេនីយឯក អ៊ុំ-ម៉ាណូវិន, ជាមិត្តរួមជំនាន់ទី២ នៃសាលានាយទាហ៊ាន,  រដ្ឋលេខាធិការ  ក្រសួងការពារផ្ទៃដីក្នុងប្រទេស  ដែលជាបងប្រុស អ្នកម្នាង មូនិច។  លោក អ៊ុំ-ម៉ាណូវិន យកឯកសារនេះ ទៅទូលថ្វាយសម្តេចសីហនុ។  ក្រោយពីបានទតឃើញឯកសារនេះ សីហនុសួរទៅ លោក ម៉ាណូវិនថា «តើ លោក សូស្តែន យល់បែបណាទៅ?» លោក ម៉ាណូវិនឆ្លើយថា «ក្នុងស្ថានភាពបែបនេះ បើពួកយៀកកុក ចង់វាយយកស្រុកខ្មែរ គឺវាអាចវាយយកបាន ក្នុងរយៈពេលតែ២៤ ម៉ោងតែប៉ុណ្ណោះ»។

ពីបីថ្ងៃក្រោយមក លោក សូស្តែន បានត្រូវ លោកឧត្តមសេនីយ ញឹក ជូឡុង  អគ្គមេបញ្ញាការជាន់ខ្ពស់ នៃកងទ័ពខេមរភូមិន្ទ  កោះហៅលោក ឲមកជួបលោកជាប្រញាប់ នៅស្រុកយ៉ាក់ឡោម ក្នុងខេត្តរតណៈគីរី។  តាមយន្តហោះ ពីភ្នំពេញ មកខេត្តរតណៈគីរី លោក សូស្តែន មានអារម្មណ៍រីករាយ ដោយយល់ថា ការធ្វើអង្កេតរបស់លោក ប្រហែលជាមានប្រយោជន៏ណាស់សំរាប់ជាតិ បានជា អគ្គមេបញ្ញាការជាន់ខ្ពស់កងទ័ពជាតិ អញ្ជើញលោកមកជួបដូច្នេះ ហើយស្នាដៃនេះ ប្រហែលអាចឲលោក អាចឡើងឋានន្តរស័ក្តិ ពិសេស ជាឧត្តសេនីយជាពមខាន។ លោក បានមកដល់យ៉ាក់ឡោម នៅម៉ោង៩យប់ ចូលជាជួបលោក ជូឡុង ជាបន្ទាន់។ លោក ជូឡុង ឃើញមុខ លោក សូស្តែនភ្លាម និយាយគំរោះ មកកាន់លោកថា «អែងភ្លីភ្លើឬ! បានជាធ្វើអង្កេតរឿងយៀកកុង តើនរណាឲអែងធ្វើ? អែង មិនដឹងរឿងអស់ហ្នឹង ជាឧត្តមនយោបាយរបស់សម្តេចនោះទេ? អែង ត្រឡប់ទៅភ្នំពេញវិញ ប្រមូលឯកសារដុតចោល

ទាំងអស់ ហើយឈប់និយាយរឿងនេះប្រាប់នរណាទៀត»។ តាមយន្តហោះវិលត្រឡប់ពីកន្លែងកំសាន្ត នៅយ៉ាក់ឡោម របស់លោក ជូឡុងវិញ លោកសូស្តែន ក្នុងអារម្មណ៍លោក មិនមានការភិតភ័យអ្វីពីទោសដែលលោកអាចនឹងទទួល តែគ្រាន់តែមានសេចក្តីក្រៀមក្រំក្នុងចិត្តតែប៉ុណ្ណោះ។

ក្នុងឆ្នាំ១៩៦៧ សម្តេចសីហនុ បានបញ្ជាឲសម្លាប់ ជាសាធារណ: វរជន នៃចលនាខ្មែរសេរី លោក ចៅ-បូរី ចៅ-មាធូរា (ជាបងប្អូនបង្កើតនឹងគ្នា) និង សៅ-ង៉ុយ នៅត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ។ សុំជំរាបមិត្តអ្នកអានថា វរជនទាំងបីរូបនេះ បានសូមចុះចូល រាជរដ្ឋាភិបាល តាមរយ: លោក អ៊ិន-តាំ អភិបាលខេត្តតាកែវ នៅក្នុងជំនាន់នោះ ប៉ុន្តែស្តេចសីហនុ មិនយកការសុំចុះចូលនេះ ជាបានការ សំរេចយក វរជនទាំងបីនេះ យកទៅបាញ់ចោលនៅត្រពាំងក្រឡឹង យ៉ាងសាហាវបំផុត ដោយយកកំហឹង និង ការសងសឹក ជាធម៌។ រហូតដល់ ថ្ងៃស្លាប់ លោក អ៊ិន-តាំ គាត់មានវិប្បដិសារីជានិច្ចក្នុងរឿងនេះ ព្រោះលោក ជាអ្នកលួងលោមអ្នកទាំងបី ឲចុះចូលសម្តេចសីហនុ។

ត្រឡប់មកនិយាយពី បញ្ហាបះបោរនៅសំឡូតវិញ ក្រោយពីមានមហាបាតុកម្ម រៀបចំដោយពួកសីហនុនិយម នៅមុខរដ្ឋសភា សូមឲសម្តេចឪ ដឹកនាំរាជរដ្ឋភិបាលថ្មីមួយ លោក ឧត្តមសេនីយ លន់-នល់ ដាក់ពាក្យលាឈប់ពីដំណែងនាយករដ្ឋមន្ត្រី នាថ្ងៃទី២៩មេសាឆ្នាំ១៩៦៧។ រាជរដ្ឋាភិបាលពិសេសមួយ ដែលមានស្តេចសីហនុជានាយក បានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហានៅសុះឡូត។ ក្នុងខែមិថុនា សីហនុបញ្ជាឲកងទ័ពអាកាសទំលាក់គ្រាប់បែក នៅភូមិ បឹងឃ្នុំ ថ្វាក់ និង ឬសីព្រះ ស្លាប់ប្រជាជនជាច្រើន។ លោក Milton Osborne អ្នកនិពន្ធបរទេសសរសេរថា «រាជរដ្ឋាភិបាលពិសេស ដោះស្រាយបញ្ហា ដោយប្រើកម្លាំងយ៉ាងខ្លាំងបំផុត» តែរឿងនេះ លោក ខៀវ-សំផន នៅក្នុងសៀវភៅ[14] របស់លោក សរសេរថា រដ្ឋាភិបាល ដឹកនាំដោយ លោក លន់-នល់ ជាអ្នកប្រព្រឹត្តិទៅវិញ។ ក្នុងចំណេរនេះ លោក ខៀវ-សំផន គាត់ប្រតិបត្ត គំនិត «លើកជើងសីហនុ ដើម្បីសុំរស់តែប៉ុណ្ណោះ» មិនសមឋានៈខ្លួនជាបញ្ញវន្ត នោះឡើយ នេះហើយជាអ្នកបដិវត្តន៍ មានមាយាទថោកទាបបំផុត!

យើងឃើញថា ក្នុងឆ្នាំ១៩៦៧ សីហនុ អនុវត្តនយោបាយ «កាប់សម្លាប់» ទាំងអ្នកខាងឆ្វេងផង និង អ្នកខាងស្តាំ» ដែលជាអ្នកប្រឆាំងនឹងនយោបាយទ្រង់។ ការសម្លាប់នេះបែបនេះ សីហនុ យល់ឃើញថា ជានយោបាយអព្យាក្រិត របស់ទ្រង់នោះឯង គឺរកសមតា ក្នុងការកាប់សម្លាប់មនុស្ស៖ សម្លាប់ពួកខ្មែរសេរី គឺចង់បង្ហាញចិនយួនកុម្មុយនិស្ត ថាខ្លួនជា «ស្តេចក្រហម» សម្លាប់ពួកខ្មែរក្រហម គឺចង់បង្ហាញអាមេរិកាំង ថាខ្លួនជា «ស្តេចអាព្យាក្រិត» តែការពិត ចាប់ពីឆ្នាំ១៩៦៦ នយោបាយសីហនុ គ្រប់វិស័យ បានជួបប្រទះនឹងបរាជ័យគ្រប់បែបយ៉ាង ដែលនាំឲទ្រង់ក្លាយជាអ្នកដឹកនាំឆ្កួតជ្រូក គិតតែសម្លាប់មនុស្ស ដើម្បីការពារអំណាច ដែលកំពុងនាំជាតិដើរទៅរកជ្រោះមរណ: ៖

[14] Khieu Samphan : L'histoire récente du Cambodge et mes prises de position – L'Harmattan។

**ភូមិសេដ្ឋកិច្ច**៖ ក្នុងវិស័យកសិកម្ម បរាជ័យ នាំឲប្រជាកសិករ ៩០% ទទួលផលអាក្រក់ជាក់ស្តែង ដូចយ៉ាងក្នុងវិស័យ សម្ភារៈទំនើប ធនធានសំរាប់ធ្វើអភិវឌ្ឍន៍ បរាជ័យក្នុងវិស័យ សហករណ៍ដែលជាវិស័យមួយសំខាន់ក្នុងលទ្ធិសេដ្ឋកិច្ចសង្គមនិយម ដែលមានលោក ហ៊ូ-យន់ ជាអាឡាចារ្យ។ ក្នុងវិស័យឧស្សាហកម្ម គ្មានលទ្ធផលដែលអាចទុកជាការលើកទឹកចិត្តសំរាប់របបសេដ្ឋកិច្ចនោះឡើយ ភាពអន់នេះ កើតមានមកពីហេតុផលសំខាន់ពីរយ៉ាង៖ អវត្តមាន នូវ **សនិទានភាព** (rationalité) ក្នុងការបង្កើត និង កន្លែងសង់ រោងចក្រ។ ក្នុងវិស័យពាណិជ្ជកម្ម និង ធានាគារ ការបង្កើតក្រុមហ៊ុនជាតិ នីហរកម្ម និង អាហរណកម្ម ភណ្ឌាគាររដ្ឋ ធំសំបើម ដើម្បីលក់ទិញទំនិញអោយខ្លះ បានក្លាយជាសម្បត្តិផ្ទាល់ខ្លួន របស់ក្រុមបរិវារស្តេចសីហនុមានសិទ្ធិលួចរដ្ឋ ក្លាយជាមហាសេដ្ឋី យ៉ាងឈាប់រហ័សបំផុត យករូបិយប័ណ្ណ លួចរដ្ឋ ចេញពីប្រទេសមកបរទេសតាមតែទំនើងចិត្ត។ ល។

**ភូមិសីលធម៌**៖ វិបត្តិសីលធម៌ មានកំរិតមួយគួរឲភ័យសំរាប់ជាតិខ្មែរ ព្រោះក្រុមបរិវារស្តេចសីហនុ លែងខ្លាច តម្លៃប្រពៃណីជាតិ ដោយយកអំពើពុករលួយ ជាតម្លៃជាតិ លួចជាតិឥតខ្លាចច្បាប់ ជិះជាន់រាស្ត្រឥតខ្លាចធម៌ព្រះ បង្ខំឲរាស្ត្រសំពះ ព្រោះខ្លួនជាញាតិ នឹងស្តេច និងអ្នកម្នាង។ ហើយបើមាន ជនណាហ៊ានរិះគត់ ចោទភ្លាមថា ជាជនក្បត់ជាតិ។ យុត្តិធម៌ យកច្បាប់ជាមធ្យោបាយ សំរាប់ចំរិតរកលុយ ជនពាល យកមុខងារជាមន្ត្រី សំរាប់រកស៊ី ស្តេចសីហនុ ថតកុន ដើរតួ ជាដារាកុន ចំរៀង ទុកខ្លួនជា ជនមជ្ឈត្តកៈ[15] អ្វីដែលទ្រង់ធ្វើ គឺសំរាប់តែអញតែប៉ុណ្ណោះ។

**ភូមិអព្យាក្រិត**៖ ទ័ពអាមេរិកាំង រកឃើញ មូលដ្ឋានសឹកយៀកកុងនៅស្រុកខ្មែរ នាំ ឲអព្យាក្រិតសីហនុ ក្លាយជា អព្យាក្រិតសិប្បនិម្មិត នាំឲទ័ពអាមេរិកាំងនៅស្រុកយួនខាងត្បូងលែងគោរព ព្រោះស្រុកខ្មែរវាក្លាយ ជាគ្រោះថ្នាក់ សំរាប់យុទ្ធសាស្ត្រយោធា កាពារសាធារណរដ្ឋវៀតណាមខាងត្បូង ពីការវាយប្រហារ ពីសំណាក់ សាធារណរដ្ឋសង្គមនិយមវៀតណាម (យួនខាងជើង ជារដ្ឋកុម្មុយនិស្ត)។ អព្យាក្រិតសីហនុ វាគ្រាន់ជាឆ័ត្រ របស់លោកកុម្មុយនិស្ត ប្រើដើម្បី បិទបាំងកងទ័ពយួនកុម្មុយនិស្តនៅក្នុងស្រុកខ្មែរ និង ជាអាធារភស្តុភាកងទ័ព (support logistique) របស់វា។

**ភូមិរបបសង្គមរាស្ត្រនិយម**៖ ចលនាសង្គមរាស្ត្រនិយម បានក្លាយបន្តិចម្តងៗ ទៅជាឧបករណ៍ សំរាប់សង្កិនសង្កត់ប្រជារាស្ត្រ និង អ្នកនយោបាយ ដែលគេមាន និន្នាការនយោបាយខុសពីគំនិតសីហនុ ដែលជាគំនិតមានអត្ថរស់ជា ការច្របាច់ ការជញ្ជក់ និង ការសង្កត់

---

[15] ជនមជ្ឈត្តកៈ= L'homme égocentrique។

ដើម្បីបំរើប្រយោជន៍ផ្ទាល់ខ្លួន។ ចលនាសង្គមរាស្ត្រនិយម បានធ្វើឲរដ្ឋខ្មែរ លែងមានលក្ខណៈជានិតិរដ្ឋ ដែលជាឧបសគ្គ នូវការធ្វើ វិត្ថាកម្ម នៃលទ្ធិប្រជាធិបតេយ្យ សេរី ( l'expansion de la démocratie libérale) នៅស្រុកខ្មែរ។

កត្តាទាំងបួនដែលបានរៀបរាប់ខាងលើនេះ ជាសញ្ញាបង្ហាញជាមុន នូវអស្តង្គត នៃរបបសីហនុនិយម។ អំពើផ្តេសផ្តាស របស់សីហនុ បានចោទជាបញ្ហា នូវភាពស្របច្បាប់របស់វា ដូចយ៉ាងទុករាជបល្ល័ង្គ ឥតមានស្តេចគ្រងរាជ្យ ការលុបចោលពហុបក្ស ដើម្បីចលនាសង្គមរាស្ត្រនិយមបានរស់ បាច់សម្លាប់អ្នកប្រឆាំង ដើម្បីសេចក្តីសុខផ្ទាល់ខ្លួន។ ល។
ចាប់ពីឆ្នាំ១៩៦៧ ស្តេចសីហនុ ធ្វើនយោបាយបំរើ ចិន និង យួន កុម្មុយនិស្ត លក់ទឹកដីខ្មែរឲយៀកកុង ក្បត់ជាតិ សាសនា ដើម្បីមានះ ទោះបីដឹងខ្លួនថា ធ្វើខុសយ៉ាងណាក៏ដោយ ក៏នៅតែចចេស មិនព្រមទទួលស្គាល់កំហុសរបស់ខ្លួននោះឡើយ។ តែកំហុសរបស់សីហនុ វាឥតស្គាល់មានះរបស់ស្តេចអង្គនេះឡើយ ព្រោះវិបាក កើតចេញពីកំហុសទាំងឡាយនោះ វាជាមហន្តរាយសំរាប់សីហនុខ្លួនឯងផង និង សំរាប់ជាតិផង។

**១.សំរាប់សីហនុ** គឺនាំឲទ្រង់បាត់ប្រជាប្រិយភាព ចំពោះ ប្រជាជនភាគច្រើន, អ្នករាជការ, ទាហ៊ាន, យុវជន, វរជន,សមាជិកសភា។ល។ ត្រូវដឹងថា ប្រជាប្រិយភាពនេះឯងហើយ ជាមូលដ្ឋាន នៃធម្មានុរូបភាព(légitimité) របស់ស្តេចសីហនុ។ មូលដ្ឋាននេះ យើងធ្លាប់បានរៀបរាប់បង្ហាញខាងលើរួចមកហើយ។

**២.សំរាប់ជាតិ** គឺនាំឲប្រជាជាតិ រស់ជាប្រទេសឧនាភិវឌ្ឍនៅក្នុងដំបន់អាស៊ីអគ្នេយ៍ ព្រោះមិនបានឆ្លៀតឪកាស ក្នុងរយៈពេលសន្តិភាព ក្នុងឯករាជជាតិ ដែលស្រុកខ្មែរ កម្រ នឹងបានជួបប្រទេះនៅក្នុងប្រវត្តិសាស្ត្រ ធ្វើអភិវឌ្ឍន៍ជាតិ ឲប្រជាជាតិក្លាយជាប្រទេស សេរី និង សម័យ។ ម្យ៉ាងមួវិញទៀត នៅពេលសង្គ្រាម នៅវៀតណាម ស្រុកខ្មែរឥតបានរកប្រយោជន៍, ១. ដើម្បីយកមក ពង្រឹង និង ធ្វើទំនើបកម្មកងទ័ពជាតិ ដើម្បីការពារឯករាជ្យជាតិ និង បូរណភាពដែនដី, ២. ដើម្បី ធ្វើអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យអប់រំជាតិ។ ឧទាហរណ៍៖ ប្រទេសថៃ, ហ្វីលីពិន គេឆ្លៀតរកចំណេញបានច្រើនណាស់នៅពេលសង្គ្រាមនៅវៀតណាម ឯចំណែកនយោបាយសីហនុ បែរជានាំប្រជាជាតិ ទៅជាប់ករ ដោយមុធាភាព (gratuitement) ក្នុងទ្រង់កុម្មុយនិស្តចិន/យួន ដែលជាពេជ្ឈឃាត លទ្ធិប្រជាធិបតេយ្យសេរីនៅស្រុកខ្មែរ។
ការចចេសក្នុងកំហុសទាំងនោះ ដែលជាកត្តា នៃការវិនាស ដោយខ្លួន របបសង្គមនិយម ឬសីហនុនិយម។ ហេតុនេះឯង បានជាសភាជាតិ, ស្របតាមច្បាប់រដ្ឋធម្មនុញ្ញ, បានបោះឆ្នោតទំលាក់ សីហនុ ពីដំណែងប្រមុខរដ្ឋ ពីកំហុស ក្បត់ជាតិ បំរើប្រយោជន៍បរទេស នៅថ្ងៃទី១៨មិនាឆ្នាំ១៩៧០។

តែសីហនុ យកគំនុំ ជាវិចារណញ្ញាណរបស់ទ្រង់ អំពាវនាវ ឲទ័ពយួនកុម្មុយនិស្ត វាយប្រហារកងទ័ពជាតិខ្មែរដើម្បីអំណាច នាំឲសង្គ្រាមផ្ទុះឡើងនៅក្នុងស្រុកខ្មែរ ដែលជាវិនាសកម្ម ដ៏ធំមួយដល់ប្រជាពលរដ្ឋខ្មែរ។

ចាប់ពីឆ្នាំ១៩៧០មក សីហនុ ជាអ្នកធ្វើឲបាត់ឯករាជ្យជាតិ, បូរណភាពទឹកដី ហើយជួយកុម្មុយនិស្តខ្មែរ/យួន ដោយមានការគាំទ្រ ពីសំណាក់ប្រតិព័ន្ធ វ៉ាសូវី វៃ និង ចិនកុម្មុយនិស្តប្រហារ សាធារណរដ្ឋខ្មែរ ព្រោះសាធារណរដ្ឋនេះ ហ៊ានចេញមុខ ជាអ្នកការពារឯករាជ្យជាតិ និង បូរណភាពទឹកដីខ្មែរ ពីការវាយលុក កងទ័ពកុម្មុយនិស្តយួន មកក្នុងដែនដៃខ្មែរ។ មកដល់សព្វថ្ងៃនេះ ពួកកម្មុយនិស្តនិយមចិនក្តី និយមយួនក្តី តាំងខ្លួនជាអ្នកមានជ័យជំនិះលើសាធារណរដ្ឋខ្មែរ តែជ័យជំនិះនោះ វាគ្រាន់តែយកមករស់ ជាខ្ញុំកញ្ជះ យួន និង ចិន តែប៉ុណ្ណោះឯង។ ខ្មែរក្រហម បានធ្វើឲប្រទេសខ្មែរបាត់ឯករាជ្យ ព្រោះខ្វាស់សមត្ថភាព ការពារជាតិ ឯចំណែក ខ្មែរយៀកមុិញ បានធ្វើឲប្រទេសខ្មែរ បាត់ទឹកដី ព្រោះរស់ជាអាយ៉ងយួន រីឯស្តេចសីហនុ តាំងពីនៅរស់ រហូតស្លាប់ជាខ្មោច បានធ្វើឲរាស្ត្រខ្មែរ រស់ជាជាតិសាសន៍ខ្ញុំគេ ព្រោះតែចង់រក្សាអំណាច។ នេះហើយ ជាស្នាដៃ ពួកកុម្មុយនិស្តនិង រាជានិយមខ្មែរ! សួរថាតើនរណា ជាអ្នកចាញ់យួន? សាធារណរដ្ឋខ្មែរ? ឬ កុម្មុយនិស្តខ្មែរ?

សារធារណរដ្ឋខ្មែរ ប្រយុទ្ធ ការពារឯករាជ្យជាតិ បូរណភាពទឹកដីខ្មែរ តែឥតសាញរកឯកភាពជាតិ ដើម្បីស្វែងរកកម្លាំងជាតិ សុខចិត្តដាក់អាវុធប្រគល់អំណាចឲសីហនុ ដោយយល់ឃើញថា ស្តេចនេះអាចមានលទ្ធភាព បង្រួបបង្រួមជាតិ ដើម្បីប្រឈមមុខ នឹងគ្រោះថ្នាក់យួនកុម្មុយនិស្ត នៅពេលដែលអាមេរិកាំងដកទ័ពចេញពីប្រទេសវៀតណាម តែស្តេចសីហនុ រស់ជាអាយ៉ងចិនកុម្មុយនិស្ត រួមគំនិតជាមួយខ្មែរក្រហម យកបានអំណាច ទៅធ្វើបដិវត្តន៍វណ្ណៈ ទុករាស្ត្រខ្លួនឯងជាសត្រូវ គិតតែពីកាប់សម្លាប់ ឥតគិតពីគ្រោះថ្នាក់យួនរួមជាមហាវៀតណានោះឡើយ។

និយាយថា សាធារណរដ្ឋចាញ់សង្គ្រាមខ្មែរក្រហមទៅចុះ ហើយថាខ្មែរ ជាឈ្នះលើខ្មែរទៅចុះ គឺដើម្បីសន្តិភាពសំរាប់ប្រជាពលរដ្ឋខ្មែរ ការនេះ វាគ្មានជាការខ្វាសអ្វីនោះទេ តែដល់យកជ័យជំនះ ទៅឲចាញ់យួន ការនេះឯង គឺពិតជា ការថោកទាបបំផុតសំរាប់ប្រជាជាតិខ្មែរ។ ខ្មោចសីហនុក្តី ខ្មោចប៉ុលពតក្តី ប្រកដជាចុះនរកសំរាប់ឋានបិសាចជាពុំខាត៕

## សេចក្តសន្និដ្ឋាន

សតវត្សទី២០ នៅស្រុកខ្មែរ ជាងពាក់កណ្ដាលសតវត្ស អាចចាត់ទុកវា ជាសតវត្សស្ដេចសីហនុ (១៩៤១-១៩៩៣)។ ស្ដេចសីហនុឡើងសោយរាជ្យសម្បត្តិលើកទី១ ក្នុងឆ្នាំ១៩៤១ ហើយឡើងសោយរាជ្យសម្បត្តិលើកទី២ ក្នុងឆ្នាំ១៩៩៣។ លើកទី១ ដោយសាររបបអាណានិគម បារាំងគេយកធ្វើជាស្ដេចអាយ៉ង ដើម្បីស្រួលងាយ នឹងត្រួតត្រា សំរាប់បំរើប្រយោជន៍អាណានិគម។ អ្នកសីហនុនិយម តែងនាំគ្នាយល់ឃើញថា បារាំងទេ ជាអ្នកយល់ច្រឡំ គឺក្រោយពីបានឡើងគ្រោងរាជ្យមក គឺសម្ដេចសីហនុទេ ដែលធ្វើឲបារាំងឈឺក្បាល ពិបាក នឹងដឹកនាំព្រះអង្គ ព្រោះព្រះអង្គ មានប្រាជ្ញាវៃឆ្លាតណាស់ អាចមានលទ្ធភាព ដឹកនាំបារាំងវិញទេ សួរថាតើនៅត្រង់ណា ដែលពួកអ្នកដែលមានទស្សនៈបែបនេះ យកមកធ្វើជាសំអាង?

ពីឆ្នាំ១៩៤៦ មកមកដល់១៩៥៦ សីហនុ បន្តបំរើនយោបាយបារាំង ដើម្បីសម្លាប់របបលទ្ធិប្រជាធិបតេយ្យសេរី នៅស្រុកខ្មែរ បារាំងបន្តដឹកនាំជាតិខ្មែរ តាមរយៈវប្បធម៌ ដូចយ៉ាង ការប្រើភាសាបារាំងសំរាប់សិក្សា នាំឲយុវជន រស់ក្នុងឋានៈ ជាជនឧនាភិវឌ្ឍ ចំពោះមុខ ជនជាតិបារាំង ទោះបីមានខ្មែរមួយចំនួនតូច អាចទទួលលទ្ធកម្មបាន ចំណេះផ្នែកបច្ចេកទេសពីបារាំង តែជាង៩០% ឥតមានសម្បទា ព្រោះមានការលំបាកខ្លាំងក្នុងការរៀនភាសាបារាំងផង និង ចំណេះបច្ចេកទេសផង។ កំហិតទាំងពីរនេះហើយ ជាហ្វ្រាំង បង្អើនអ្នកចេះដឹងខ្មែរ ដែលនាំឲប្រទេសខ្មែរ មានការយឺតយ៉ាវក្រៃពេក ក្នុងវិស័យចំណេះចេះដឹងបែបសម័យដោយប្រៀបធៀបនឹងប្រទេសជិតខាងមាន យួន និង សៀម ជាអាទ៍។ បើយោងតាមស្ថិតិជាផ្លូវការ មកដល់ឆ្នាំ១៩៦៩ និសិត្សខ្មែរគ្រប់មហាវិទ្យាល័យ មានចំនួនត្រឹមពាន់នាក់តែប៉ុណ្ណោះ បើប្រៀបធៀបនឹង ប្រទេសថៃ និង វៀតណាមទាំងពីរ ប្រទេសនិមួយៗ គេមានចំនួន រាប់សែននាក់ ឯណោះ។

ចាប់ពីឆ្នាំ១៩៥៦ សីហនុ ធ្វើរដ្ឋប្រហារ រំលំ លទ្ធិប្រជាធិបតេយ្យសេរី ហើយបង្កើតរបបផ្ដាច់ការ នាំឲប្រជាជនខ្មែរ រស់ក្នុងភាពឥតសេរីភាព បញ្ចូញមតិយោបល់ ដែលជាសារវន្ដ នៃមនុស្សលោក ដែលជាសត្វមានប្រាជ្ញា នៃការពិចារណា។ សេរីភាព ដែលអាចនាំឲមនុស្សលោក មានសភាពចម្រើនក្នុងផ្នែកប្រជ្ញា គឺសេរីភាពនយោបាយនោះឯង ព្រោះសេរីភាពនេះ ហៅរកកត្តាពីរ ដើម្បីបង្កើតគំនិតវិជ្ជមាន គឺសេចក្ដីក្លាហាន និងប្រាជ្ញា។ តែកត្តាទាំងពីរនេះ ជាសត្រូវ នឹងអំណាចផ្ដាច់ការ ហេតុនេះឯង បានជាស្ដេចសីហនុខំធ្វើយ៉ាងណា ឲប្រជាពលរដ្ឋខ្មែរ រស់ក្នុងអន្ធការនិយម[16]ជានិច្ច ដើម្បីងាយស្រួលដឹកនាំដូចឃ្វាលគោ។ ចលនាសង្គមរាស្ត្រនិយមនេះឯង ដែលសីហនុ យកមកធ្វើជាឧបករណ៍ សំរាប់សមិទ្ធិរបបរាជានិយមផ្ដាច់ការ ដែលមានព្រះអង្គ ជាស្ដេចឥតមកុដ។ ស្ដេចបែបនេះ រស់របូត ពីកំហិត នៃទសពិធរាជធម៌ រស់ជា សុញ្ញាជន (ជនឥតតម្លៃ) ជម្ពជន (មនុស្សស្លាប់គំនិត) ចេះតែការកាប់សម្លាប់មនុស្សលោក ដែលជាទុរិជ្ជា។

---

[16] អន្ធការនិយម=ភាពល្ងង់ខ្លៅ ; obscurantisme។

មកដល់ឆ្នាំ១៩៦៣ សីហនុប្រកាសដូរមិត្ត ប្តូរលោកសេរី មកយក លោកកុម្មុយនិស្ត មាន ចិន ជាសមមិត្ត។ ឈប់ទទួលជំនួយអាមេរិកាំង តែសូមជំនួយចិនក្រហម ដូរនឹងដែនដីកម្ពុជា ឲយៀកកុង យកទ័ពមកតាំងទី ដើម្បីស្រួលវាយ វៀតណាមខាងត្បូង។ ជម្រើសនេះ ស្តេចសីហនុ យកជំនួយសហរដ្ឋអាមេរិក ជាបញ្ហានយោបាយខ្មែរ ទ្រង់ បង្កើតបញ្ហាដោយ មិនរួញរា ដើម្បីប្តូរនយោបាយនគរលើឆាកអន្តរជាតិ ដែលនាំជាតិទៅរកភាពមហន្តរាយ។ ម្យ៉ាងមួយទៀត សីហនុបង្កើត អភូតកថា (mythe) លើបុគ្គលិកលក្ខណៈព្រះអង្គ ថាព្រះអង្គ ជាព្រះបាទធម្មិក មានឫទ្ធបារមី ស្គាល់ភក្តិមាគ៌ា (salvation)សំរាប់សង្គ្រោះប្រជារាស្ត្រ ជាវង្សវរ័ន្ត អាចកសាងមហានគរខ្មែរបានឡើងវិញ។ ចាប់តាំងពីឆ្នាំ១៩៦៣ សីហនុ ប្រើ នយោបាយ រកអ្នកទទួលកំហុសដែលខ្លួនបានប្រព្រឹត្ត[17] និង បង្កើតអភូតកថា ជាសញ្ញាអ្នកផ្ញើ នៃសីហនុនិយម។ អ្វីដែលជាកំហុសរបស់សីហនុ ទ្រង់តែងតែរកអ្នកទទួលខុសត្រូវជានិច្ចដើម្បីយករួចខ្លួន ហើយអ្វីដែលជា ជោគជ័យគឺ ទ្រង់ជាម្ចាស់វាជានិច្ចដើម្បីឲប្រជារាស្ត្រទទួលស្គាល់ខ្លួនព្រះអង្គ ជាព្រះបាទធម្មិក ដែលជាប្រជារាស្ត្រ ធ្លាប់តែមានជំនឿងុបងុល លើអបិយជំនឿ។

ចាប់ពីឆ្នាំ១៩៦៧ សីហនុ ក្លាយជាពេជ្ឈឃាត ហួងហែងខ្មែរអ្នកជា យកទៅសម្លាប់ដូចសត្វធាតុ ដែលជាអំពើឃ្លាងពីកន្លងធម៌ព្រះពុទ្ធ។ សីហនុ ក្លាយជាភីជន (l’homme arrogant) ឬ មនុស្សឈ្លើយ មានកំហឹងកម្រោលជានិច្ច តាមរកសម្លាប់មនុស្ស ដើម្បីរំសាយចេញ ការភិតភ័យក្នុងចិត្ត ខ្លាចគេទម្លាក់ពីដំណែង។ សេចក្តីតានតឹងក្នុងចិត្តនេះ ក្លាយជាជម្ងឺសិតិ ទុកមិត្តជាសត្រូវ ទុកសត្រូវជាមិត្ត ទុកខ្លួន ជាសាវ័ក ម៉ៅសេងទុង ហូជីមិញ ស្រមៃ ថាខ្លួនជាព្រះថ្មី បង្កើតបាន នូវលទ្ធិសង្គមរាស្ត្រនិយម ស្មើនឹង ពុទ្ធសាសនា បង្ខំរាស្ត្រ ឲធ្វើជាសង្គមរាស្ត្រនិយមជន ដើម្បីឃោសនា លើឆាកអន្តរជាតិ ថាខ្លួនមានប្រជាប្រិយភាពក្នុងសង្គមខ្មែរ។ សីហនុរហូតដល់ថ្ងៃស្លាប់ ជាអរតា នៃ អធម៌នោះឯង៕

**ចប់**

**ថ្ងៃទី២២ឧសភាឆ្នាំ២០១៤**

# សេចក្តីបន្ថែម

## ស៊ីហនុជាបិតាជាតិបែបណា ?

[17] រកអ្នកទទួលកំហុសដែលខ្លួនឯងបានប្រព្រឹត្ត=rechercher le bouc émissaire។

## អារម្ភកថា

អត្ថបទនេះសរសេរជាភាសាបារាំងក្នុងខែកញ្ញាឆ្នាំ១៩៧៩ដោយខ្មែរ”អ្នកវឌ្ឍននិយម”មួយក្រុម ស្រឡាញ់របបលទ្ធិប្រជាធិបតេយ្យសេរី និងរបបសាធារណរដ្ឋ ដើម្បីទុកជាឯកសារជាប្រវត្តិសាស្ត្រសំរាប់កូនខ្មែរជំនាន់ក្រោយអោយបានដឹងឮអំពីធាតុពិតរបស់ស្តេចស៊ីហនុ ដែលជាបិតាជាតិក្លែងក្លាយចូលរួមចំណែកយ៉ាងសកម្មក្នុងអំពើ”សម្លាប់មហាជនខ្មែរ” ក្នុងឋានៈជាប្រមុខរដ្ឋអស់មួយជិវិតនៃរដ្ឋ”កម្ពុជាប្រជាធិបតេយ្យ” ដែលជារដ្ឋអនុវត្តន៏នយោបាយសម្លាប់មហាជនខ្មែរក្នុងចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។អត្ថបទនេះត្រូវបានប្រគល់ជូនដល់ចលនាមូលខ្មែរមានសេរីភាពក្នុងក្រខណ្ឌសិក្ខាសាលានៃចលនា ជាឯកសារចូលរួមចំណែកក្នុងការពិចារណាអំពីការដំណោះស្រាយនៃបញ្ហាខ្មែរនាឆ្នាំ១៩៨៨។

**អត្ថបទនេះបកប្រែ សំរួល និងសង្ខេបជាភាសាខ្មែរដោយ ឧប សៅ សង្ហា**

ដើម្បីផ្សាយជូនជាព័តិមានដល់ប្រជាពលរដ្ឋមជ្ឈដ្ឋានទុំហើយការផ្សាយនេះគ្មានគោលបំណងជាមានះសំរាបប្រមាថមើលងាយសម្តេចស៊ីហនុនោះឡើយ តែជាសិទ្ធិជាករណីយកិច្ចរបស់ខ្មែរ ដើម្បីខ្មែរ ចងទុកក្នុងសតិជាប្រវត្តិសាស្ត្រនូវអំពើព្រៃផ្សៃមានកើតឡើងក្នុងប្រទេសខ្មែរ ដែលមានក្រុមខ្មែរក្រហមក្រោមការ ដឹកនាំសម្តេចស៊ីហនុនិងប៉ុលពតក្នុងចន្លោះឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ បានកាប់សម្លាប់ប្រជាជនខ្មែរអស់ជំនួនប្រហែល២លាននាក់។

**ការផ្សាយនេះ ទុកជាការរកយុត្តិធម៍ជូនចំពោះខ្មែររងគ្រោះនូវអំពើព្រៃផ្សៃនេះ។**

### ១.ហេតុអ្វីបានលើកសួរជាសំនួរនេះ ?

ពីព្រោះសម្តេចនរោត្តមស៊ីហនុជាអ្នកទទួលខុសត្រូវដ៏ធំមួយនៅចំពោះមុខប្រវត្តិសាស្ត្រនូវមរណភាពខ្មែររាប់លាននាក់តែទោះបីយ៉ាងនេះក៏ដោយក៏របបនយោបាយនៅភ្នំពេញបច្ចុប្បន្នចាត់ទុកព្រះអង្គជា”វរៈក្សត្យ”។

ទោះបីនៅមានអ្នកស៊ីហនុនិយមតិចតួចបំផុតនៅមានជំនឿលើ”**អភូតកថាស៊ីហនុ**”ជំនឿនេះជារឿងរបស់គេព្រោះអ្នកទាំងនោះត្រូវគេផ្សាំងតាំងពីកើតមកម្លេះអោយគោរព”បិតាជាតិ”ដូចកូនក្មេងត្រូវគេបង្ខំអោយគោរព”គ្រូបាធ្យាយ”ទាសកុមារទាំងនោះនៅក្រិនគំនិតពុំអាចក្លាយជាមនុស្សពេញវ័យបានហើយមានគតិសំរាប់ជីវិតឧត្តជីវិតក្រៅពីការប្រតិបាប្ធន៏ដាច់ខាតចំពោះបិតាជាតិនេះ។

អ្វីដែលមិនទំនងនាំអោយយើងហួសចិត្តក្នុងការរកដំណោះស្រាយបញ្ហាខ្មែរនាឆ្នាំ១៩៩១មាន

ប្រទេសជាច្រើនតម្រង់ដោយបង្ខំចិត្តពលរដ្ឋខ្មែរអោយជ្រើសរើសស្តេចចង្រៃនេះជា មធ្យោបាយតែមួយគត់សំរាប់ដោះស្រាយបញ្ហាខ្មែរទុកជាព្រះបាទធម្មិកហាក់បីដូចជាប្រជាជាតិខ្មែរមានមនុស្សតែម្នាក់គត់!ហាកបីដូចជានយោបាយរបស់ប្រទេសមហាអំណាចពេល នោះគ្មានសម្បទាដោយជ្រើសរើសកូនរ៉ែកតែមួយនេះទុកជាមនុស្សយកការបាននិងទទួល ព្រមបានជាកូនសោរបស់បញ្ហាខ្មែរ។

ឯកសារចេញពីប្រភពអ្នកស៊ីហនុនិយមនៅមានទម្ងន់តិចជាងភស្តុតាងពិតនៃប្រវត្តិសាស្ត្រ អំពីអំពើដែលស្តេចស៊ីហនុតែងប្រព្រឹត្តជានិច្ចអស់រយៈពេលជិតពាក់កណ្តាលសតវត្សដែល មានលទ្ធផលជាក់ស្តែងគឺ”**ការសម្លាប់មហាជនខ្មែរ**”សេចក្តីខ្មាសការអាម៉ាសមុខបរាជ័យស្រំ ដែលរបស់ប្រទេសខ្មែរក៏ដូចមហាអំណាចត្រួតត្រាលើស្តេចនេះដែរ។

ការចចេសនៃអំពើរបស់ស្តេចស៊ីហនុនៅមិនស្មើនឹងក្រុមមនុស្សខ្វាក់នឹងជំនឿ”អភូតកថា ស៊ីហនុ”ជ្រើសរើយសចម្លើយងាយក្នុងគំនិតងាយដោយផ្អែកទៅលើ”ឫទ្ធិភាពនៃបុគ្គលឬ អំណាចបុគ្គល”របស់ស្តេចស៊ីហនុនេះនាំអោយយើងខំពិចារណាធ្វើសំយោគក្នុងចម្លើយយើង ចំពោះសំនួរយើង:”ស្តេចស៊ីហនុជាមនុស្សបែបណា”។សំយោគយើងនេះមិនគ្រាន់តែចង់ចង្អុល បង្ហាញនៃភាពមិនទំនងក្នុងការរកវិធីដោះស្រាយបញ្ហាខ្មែរដែលនាំអោយរព្ញួយប្រជាពលរដ្ឋ មួយសំរាប់តែប្រយោជន៏ស្តេចមួយអង្គតែប៉ុណ្ណោះ។

យើងមិនសូវឆ្ងល់ប៉ុន្មានទេលើតួអង្គស៊ីហនុតែយើងមានការចាប់អារម្មណ៍ជាខ្លាំងទៅលើភាព មានៈនៃអ្នកគាំទ្រដ៏ចំណានដែលនាំគ្នាប្រោះតួអង្គស្តេចស៊ីហនុអោយរស់វិញបានករណីនេះនាំ អោយយើងសួរជាសំនួរច្រើនដូចតទៅ:តើដើម្បីប្រយោជន៏អ្វី? ដោយយើងគ្មានមានអនុស្សាវ រីយ៏អ្វីសោះពីចិត្តសប្បុរសរបស់ស្តេចស៊ីហនុហើយគ្មានការរំភើបចំពោះតួអង្គស្តេចនេះឬ ចំណាយពេលវេលាធ្វើការផ្សាយជាសាធារណអោយបុគ្គលនេះពុំនោះទេក្នុងសេចក្តីសង្ឃឹមទប់ មិនអោយអាយ៉ងនេះបោកកុហកពលរដ្ឋខ្មែរតទៅទៀតក្នុងអាកប្បកិរិយាកំប្លែងដូចតួ ល្ខោនហើយផ្សាយប្រាប់ដល់សាធារណជនអន្តរជាតិគ្រប់មជ្ឈដ្ឋានមានអ្នកបវរនិពន្ធអ្នកសារ ព័តិមានអ្នកនយោបាយដែលធ្លាប់បានគាំទ្រស្តេចនេះអោយដឹងឮអំពីអំពើនិងគំនិត មារយាទរបស់ស៊ីហនុក្នុងការចូលរួមសម្លាប់ប្រជាពលរដ្ឋខ្មែរ!(បម្រុងរៀបចំសម្លាប់ដោយ ចំពោះឬមិនចំពោះ)។

## ២.ស៊ីហនុអាទិករនិងជាអ្នកចូលដៃដ៏ធំមួយក្នុងអំពើសម្លាប់មហាជនខ្មែរ

ការសម្លាប់មហាជនខ្មែរក្នុងរបប”កម្ពុជាប្រជាធិបតេយ្យ”មិនមែនជាព្រឹត្តិការណ៏ដោយចៃ ដន្យនោះទេការសម្លាប់មហាជនខ្មែរនេះជាដំណើរដ៏យូរអង្វែងមួយជាប្រវត្តិសាស្ត្រដែលមាន ស្តេចស៊ីហនុជាស្ថាបត្យករជាអ្នកទទួលខុសត្រូវសំខាន់មួយក្នុងរយៈពេល៣៤ឆ្នាំក្នុងអំណាច

ផ្តាច់ការចន្លោះឆ្នាំ១៩៤២ដល់១៩៧៦។ពេលណាស៊ីហនុខំលាងខ្លួនកាន់តែខ្លាំងឡើងពេលនោះស៊ីហនុកាន់តែបង្ហាញភាពវណ្ណជើងរបស់ខ្លួនកាន់តែខ្លាំងក្នុងភាពច្របូកច្របល់របស់ខ្លួនភាពកុមារភាពភាពមិនទំនងក្នុងការជាក់ស្តែងនៃការចូលរួមការសម្លាប់មហាជនខ្មែរ៖

**បើគ្មានស្តេចនេះព្រឹត្តិការណ៍សម្លាប់មហាជនខ្មែរមិនអាចនឹងមានកើតឡើងបាននោះទេ!**

ប្រវត្តិសាស្ត្រវាមានសតិនិងតុលាការវាបានចងក្រងទុកយ៉ាងល្អិតល្អន់នូវអំពើបាបកម្មរបស់ស៊ីហនុដែលបានត្បាញអំពើសម្លាប់មហាជនខ្មែរតាំងពីយូរអង្វែងមកហើយ៖

-ការឡើងគ្រោងរាជសម្បត្តិក្នុងនាមជា"អាយ៉ង"មានតួនាទីជាឆ្កែយាមរបស់អាណានិគមបារាំងបន្ទាប់មកទៀតក្លាយជាកញ្ជះកុម្មុយនិស្តចិនយួន។

-ការវាយប្រហារ (ចន្លោះឆ្នាំ១៩៤៨ដល់១៩៥២)ប្រឆាំងលទ្ធិប្រជាធិបតេយ្យនៅក្មេងខ្ចីរំលាយរដ្ឋសភាបីដងជាបន្តគ្នាមិនដាច់ដោយមានជំនួយពីកម្លាំងអាជ្ញាធរអាណានិគមហើយពេលរំលាយសភាម្តងៗចាប់តំណាងរាស្ត្ររបស់គណបក្សប្រជាធិបតេយ្យជាគណបក្សឈ្នះឆ្នោតដាក់ពន្ធនាគារ។

-ការដាក់រាជសម្បត្តិក្នុងខែមិនាឆ្នាំ១៩៥២ជាឧបាយដោះខ្លួនពីភាពអប្រជាប្រិយនៅចំពោះមុខសំទុះនៃចរន្តលទ្ធិប្រជាធិបតេយ្យនិងការខ្លាចក្រែងបរាជ័យរបស់គណបក្សរាជានិយមក្នុងការបោះឆ្នោតសភាតាមការអនុលោមនៃកិច្ចព្រមព្រៀងក្រុងស៊ីណែវក្នុងអំឡុងឆ្នាំ១៩៥៤។

-ការបរាជ័យដ៏អន់បំផុតគ្រប់វិស័យក្នុងការដឹកនាំរដ្ឋចន្លោះឆ្នាំ១៩៥៥ដល់១៩៧០ក្នុងអំណាចផ្តាច់ការរបស់ចលនាសង្គមរាស្ត្រនិយមទោះបីមានជំនួយបរទេសពីលោកខាងលិចនិងខាងកើតយ៉ាងណាក៏ដោយ។

-ការបង្ក្រាបដ៏ខ្លោចផ្សាដ៏កម្រោលឥតពិចារណាប្រឆាំងនឹងអ្នកប្រជាធិបតេយ្យអ្នកវឌ្ឍននិយមក្រុមគ្រូបង្រៀនក្រុមនិស្សិតអ្នកស្នេហាជាតិក្នុងអំឡុងឆ្នាំ១៩៦៧និងឆ្នាំ១៩៧០។

-ការតម្លោះងារពីប្រមុខរដ្ឋក្នុងខែមិនាឆ្នាំ១៩៧០ ដោយសភាជាតិ (រដ្ឋសភានិងក្រុមព្រឹក្សាព្រះរាជាអាណាចក្រ)។

-ការផ្តន្ទាទោសប្រហារជីវិតក្នុងអំឡុងឆ្នាំ១៩៧១ ពីបទក្បត់ជាតិ។

-ក្នុងតួនាទីជាប្រធានរណសិរ្សបង្រួបបង្រួមជាតិខ្មែររាជរដ្ឋាភិបាលបង្រួបបង្រួមជាតិខ្មែរ (១៩៧០១៩៧៥)ធ្វើការដើម្បីជោគជ័យប៉ុលពតបើគ្មានសហការនេះគឺគ្មានជ័យជំនិះនិងការសម្លាប់មហាជនខ្មែរនោះទេ។

-ការរួមចំណែកក្នុងតួនាទីជាប្រមុខរដ្ឋអស់មួយជីវិតនៃរបបខ្មែរក្រហមក្នុងការជម្លៀសប្រពលរដ្ឋចេញពីទីក្រុងដើម្បីងាយសម្លាប់ជនណាដែលគេចាត់ទុកជាសត្រូវហើយយល់ស្រប

នយោបាយរបស់ក្រុមប៉ុលពត"សម្លាប់មហាជនខ្មែរ"។យើងត្រូវចងចាំជានិច្ចថាក្នុងរបប "កម្ពុជាប្រជាធិបតេយ្យ"នេះឯងហើយជាដើមកំណើតនៃបដិវត្តន៍និយម"មៅសេងទុង"នៅស្រុកខ្មែរដែលផ្តល់អោយមានហេតុសម្លាប់មនុស្ស ដោយក្រោធពិរោធទោសៈប្រកបដោយការសងសឹកបង្ហូរឈាមខ្មែរពោរពាសនគរពីសំណាក់ពួកប៉ុលពត។

_ការពារដោយសូរភាពរបបប្រល័យជាតិសាសន៍ក្នុងការជជែកតវ៉ានៅអង្គារសហប្រជាជាតិក្នុងខែមករាឆ្នាំ១៩៧៥បន្ទាប់ពីរបបឃោឃៅនេះត្រូវទ័ពយួនវាយរំលាយចោលនៅទី៧មករា ក្នុងឆ្នាំងដែល។ទង្វើបង្ហាញជាក់ស្តែងថាស្តេចស៊ីហនុនេះអោយតែបាននិយាយក្នុងនាមជា" មេ"ទោះបីជាមេពួកឃាដករក៏សប្បាយដែរ។

_ការភូតកុហកការខ្វះសេចក្តីក្លាហានផ្តួញសំនួរអ្នកសារព័ត៌មានរបស់ទូរទស្សន៍បារាំង" Antenne2" ថាពួកប៉ុលពតតែងតែក្លែងសម្លេងខ្លួន ផ្សាយតាមវិទ្យុ"កម្ពុជាប្រជាធិបតេយ្យ" ពិការកោតសរសើររបបប្រល័យជាតិសាសន៍។

-នយោបាយដូចអំពើនៃចោរប៊ិនប្រសប់ ក្នុងឧបាយបញ្ឆោតជាទុច្ចរិតប្រជាពលរដ្ឋ អំពីមហាទ្រឹស្តីអព្យាក្រឹត សន្តិភាព និងសង្គមនិយម សុទ្ធតែល្បួចចម្លងពីអ្នកប្រជាធិបតេយ្យ ដែលគេមានប្រជាប្រិយភាពមុនខ្លួន ដើម្បីជ័យជំនិះរបបរាជានិយមប្រតិកិរិយារបស់ខ្លួន។

-មានជំនឿជាជំងឺទៅលើ"**ភាពអញនិយម**" មានទោសៈ មានវេរប្បដិវេរ សំរាប់តែប្រឆាំងនឹងប្រជារាស្ត្រខ្លួនឯង ហើយមិនព្រមថយខ្លួនពីឆាកនយោបាយដោយឥតអៀនខ្មាស ក្រោយពីធ្លាក់ដំណែងពីប្រមុខរដ្ឋ មិនតែមិនព្រមថយខ្លួន គឺថែមទាំងធ្វើអធិដ្ឋានអោយមាន"ទឹកជំនន់កុម្មុយនិស្ត"អោយជោរជនលិចលង់ប្រជាជាតិខ្មែរ ក្នុងគោលបំណងតែមួយគត់ គឺសងសឹកប្រជាពលរដ្ឋខ្លួនឯង ដែលខ្លួនចាត់ទុកជាប្រជាជនអកតញ្ញូចំពោះខ្លួន។

គ្រប់ទង្វើ គ្រប់គំនិតមារយាទនៃស្តេចស៊ីហនុ ដែលបានពិពណ៌នាខាងលើនេះ បញ្ជាក់ថាស្តេចស៊ីហនុ ឆបោកជានិច្ចប្រជាពលរដ្ឋខ្មែរគ្រប់ឱកាសដែលខ្លួនបានដឹកនាំរដ្ឋចំនួនជិនពាក់កណ្តាលសតវត្សរ៍។ស្តេចស៊ីហនុទទួលបរាជ័យជានិច្ច លើកលែងតែស្នាដៃខ្លួនមួយគត់ គឺការអនុវត្តន៍"ការសម្លាប់មហាជនខ្មែរ"ដែលជាមហាជោគជ័យរបស់ជននេះ។

នេះហើយជាទុក្ខវេទនាដែលប្រជាពលរដ្ឋខ្មែររងគ្រោះពីសំណាក់ស្តេចពាលនេះ ហើយត្រូវគេនៅតែបង្ខំអោយទទួលស្គាល់ស្តេចអសមត្ថភាព មានចម្មជាតិពីកំណើតជាមនុស្សកំណាច អសីលធម៌ គ្មានសតិជាកិត្តិយស នេះជា"បីតាជាតិខ្មែរ"។ហេតុអ្វី ?

## ៣.ស៊ីហនុ ប៉ុលពត ជាវេរចនសព្ទនឹង"ការសម្លាប់មហាជនខ្មែរ"

នៅក្នុងពិភពលោកនេះ មានតែនៅស្រុកខ្មែរមួយគត់ ដែលមានស៊ីហនុជាស្តេច មានកើតបាតុភូតហេតុអស្ចារ្យ គឺការសម្លាប់មហាជនខ្លួនឯងពីសំណាក់អ្នកដឹកនាំជាតិ។គ្រប់របប

ដែលមានស៊ីហនុជាមគ្គុទេសទ៍ តែងតែក្លាយជាអង្គការមានរបៀបមួយសំរាប់សម្លាប់ប្រជាជាតិ និងប្រជាជនខ្លួនឯង។នៅប្រទេសយៀកណាម ព្រះចៅបៅដាយ សុកចិត្តចេញពីរាជសម្បត្តិដើម្បីប្រយោជន៍ជាតិ ឯចំណែកនៅប្រទេសលាវវិញ មានលាវក្រហមដូចបដិវត្តន៍ខ្មែរដែរ តែឥតមានស្តេចលាវណាមួយ គេមានគំនិតមារយាទដូចស្តេចស៊ីហនុ ដូច្នេះប្រទេសគេក៏ឥតមានការសម្លាប់មហាជនដូចស្រុកនៅស្រុកខ្មែរនោះទេ។

គំនិតនៃអំណាច រចនាបថនៃការដឹកនាំជាតិ ចរិតជាមនុស្ស របស់ស្តេចស៊ីហនុ គឺកើតពីធាតុ ហឹនមានៈ ទោសៈ នឹងគំនិតសងសឹក របស់ជននេះ។វត្ថុធាតុទាំងនោះផ្តុំបង្កើតជារូបភាពនៃលទ្ធិ"ស៊ីហនុនិយម" ដែលជាលទ្ធិនាំបង្កើតបាតុភូតប៉ុលពតដែលវាមានប្រភេទជាលទ្ធិភ្លោះផង ជាផ្នាំបន្សាបផងនឹងស៊ីហនុនិយមផង។ដូច្នេះ ប៉ុលពតជាទាសៈប្រតិកិរិយា បះបោរប្រឆាំងនឹងស៊ីហនុ តែវាសនាវាត្រូវផ្ជាប់ជានិច្ចនឹងស្តេចស៊ីហនុដូចជាបញ្ញើក្អែកដូច្នេះឯង។ផ្អែកលើភាពផ្តាចការបង្ហួរឈាមនិយម និងទ្វការនិយម មហាវៀចវេរ របបស៊ីហនុមានធម្មជាតិជារបបរាជាធិបតេយ្យធាតុសក្តិភូមិ។ក្រោយពីបានរំដោះខ្លួនពីអាណាព្យាបាលបារាំងមក រាជាធិបតេយ្យនេះ ចាប់ផ្តើមមនៈបញ្ចេញមារយាទជាប្រតិកម្មបន្តគ្នានូវទោសៈ វេរប្បដិវេរ ហិង្សា យ៉ាងព្រៃផ្សៃបំផុត ដែលរបបរាជាធិបតេយ្យនេះតែងតែអនុវត្តន៍ជានិច្ចជាកាលដែលខ្មែរយើងបានឃើញជាក់ស្តែងក្នុងរបបកូនភ្លោះខ្មែរក្រហមៈ

-ការជន្លាសមហាជនជានិច្ចកាលក្នុងសង្គ្រាមដណ្តើមរាជសម្បត្តិ ដែលមានចែងក្នុងពង្សាវតារខ្មែរ។

-ការដុតបំផ្លាញអោយសាបសូន្យនូវអ្វីៗដែលរបបនេះទុកជា"បូរី" "អារ្យធម៌" (ផ្ទះ ខ្ទម បូជនីយស្ថាន  បដិមាករ ជាអាទ៍)។

-ការធ្វើអោយវិនាសនូវវប្បធម៌ជាតិជាសហស្សវត្ស (ដុតសៀវភៅជាចំណេះទួរទៅ វាយបំបែកបំបាក់បដិមា វត្ថុសិល្បៈ កំចាត់អ្នកចេះដឹង អ្នកមានគតិបណ្ឌិត សម្លាប់សិល្បករ ការិនី។

-ការធ្វើ"អភារុប្បនីយកម្មដាច់អហង្កាអ្វីដែលជាគុណសម្បត្តិខ្មែរ" ដូចជាការដូរឈ្មោះប្រទេស ស្ថានប្រវត្តិសាស្ត្រ ការបំបាត់ភាសាខ្មែរ បង្កើតភាសាថ្មី ការក្លែង ឬបំបិតលែងអោយគោរពប្រពៃណី បុណ្យប្រជាប្រិយ។

-ការសម្លាប់មហាជន (នៅសល់តែខ្មែរ៨០០.០០០នាក់តែប៉ុណ្ណោះនៅប្រទេសកម្ពុជា នៅពេលដែលបារាំងមកត្រួតត្រាស្រុក)ការសម្លាប់មហាជន ជានយោបាយរបបរាជាធិបតេតយ្យជាអចិន្ត្រៃយ ដែលប្រជាពលរដ្ឋខ្មែរបានផ្តិតជាប់ក្នុងសតិ មានស្រមោលក្នុងសង្គមខ្មែរ គឺ"សេក្តីខ្លាចក្រែងជាអតិបរិមាណរាជអំណាច" ការពិពណ៌នាខាងលើនេះ មានភាពបង្អង់បន្តិចនៅពេលបារាំងចូលមកត្រួតត្រានៅឥណ្ឌូចិន។តែរបបអាណានិគមយមនេះមិនបានអប់រំចិត្តគំនិតមហាក្សត្រខ្មែរ ដែលមានពូជពីវង្សក្សត្យរណបសៀម និងយួន អោយដូរចរិតទៅជាអរិយមនុស្ស ជាហេតុនាំស្តេចស៊ីហនុបន្តចរន្តវីតតែខ្លាំងឡើងៗនូវអំពើនាំអោយរលួយសង្គមខ្មែរ ដូចជាៈ

-“ឯករាជ្យខ្មែរ” មានភាពជាក្បួនហែខ្មោចយកសពជាតិខ្មែរទៅកប់ចោលក្នុងព្រៃស្មសាន
ឥណ្ឌូចិនរបស់យួន ដែលមានស្តេចស៊ីហនុជាទេពារក្ស តាំងខ្លួនជាបីតាជាតិ។
-”ខ្មែរជាកោះសន្តិភាព”ក្នុងរដ្ឋជាពេជ្ឈឃាត និងអ្នកជញ្ជក់ឈាមរាស្ត្រខ្មែរ ដែលយកបាវចនា
ត្រីមុខ ”ជាតិ សាសនា និងព្រះមហាក្សត្រ ជាគំនិតកុហកដល់មតិជាតិ និងអន្តរជាតិ ដើម្បីសំ
រាប់តែបំរើមហិច្ឆិតាលទ្ធិ”ស៊ីហនុនិយម”។ស្តេចយកបាវចនានេះមកជាន់គន្រ្ទំក្នុងរោគខូច
សតិសម្លាប់ជាតិឯង។ស្តេចអង្គនេះជាស្តេចបើកឱកាសអោយកុម្មុយនិស្តចិន យួន និងក្រុម
ប៉ុលពត កាប់សម្លាប់ព្រជាពលរដ្ឋខ្មែរ ដែលខ្លួនទុកជាអកតញ្ញូចំពោះខ្លួន ដើម្បីសងសឹក និង
វឹលត្រឡប់មកសោយរាជសម្បត្តិវិញតែប៉ុណ្ណោះ។តែមហិច្ឆិតាដែលមានក្លិនអសោចខ្លាំងនេះ
ត្រូវទំព័រប្រវត្តសាស្ត្រចងទុកនាមស៊ីហនុជាស្តេច”សម្លាប់មហាជនខ្មែរ”។
ស្តេចស៊ីហនុបានបណ្តុះគំនិតប្រជាពលរដ្ឋខ្មែរអោយមានជំនឿលើខ្លួនព្រះអង្គ តាមការ
ប្រលោមក្តី តាមការបង្ខំក្តី ដែលខ្លួនទុករាស្ត្រខ្មែរជាពលរដ្ឋល្ងង់ខ្លៅ ក្រោមល្អងធូលីព្រះ
បាត ក្នុងគោលបំណងខ្លួនតែមួយគត់ គឺ”អំណាចដើម្បីបំរើកុម្មុយនិស្តចិន យួន ជាអ្នកម្ចាស់
របស់ខ្លួន។
ក្នុងរបបស៊ូហនុនិយម ស្តេចស៊ីហនុទុករាស្ត្រខ្មែរជាហ្វូងសត្វ អោយជឿលើរាជបារមីខ្លួន ហើយ
ត្រូវក្រុមប៉ុលពតនាំទៅសម្លាប់ឥតមានអាសូរបន្តិចណាឡើយ ក្រោមនាមខ្លួនជាប្រមុខរដ្ឋ
អស់មួយជីវិតនៃ «កម្ពុជាប្រជាធិបតេយ្យ»។
អំណើតទៅ តួអង្គស៊ីហនុ មានរូបភាពជាប៉ុលពត ដូចជាស្រមោលរបស់ខ្លួន។ហេតុអ្វីដែលត្រូវ
បំភ្លេចស៊ីហនុ បើយើងនិយាយឈ្មោះប៉ុលពត ស៊ីហនុ និងប៉ុលពត ជាបុគ្គលពីរខួរក្បាលតែ
មួយ ឬដូចជាពស់មានក្បាលពីរដែរ។

## ៤.ជំនឿមិនទំនងទៅលើអភូតកថាស៊ីហនុ

តើជំនឿនេះឯងឬ ដែលគ្រប់ភាគីខ្មែរគេនាំគ្នាចាត់ទុក”ឥស្សរជន”នេះដែលតែងតែប្រព្រឹត្ត
នយោបាយបន្លំរាស្ត្រជាគោលនៃការរួបរួមជាតិ ? តាមពិតនយោបាយស្តេចស៊ីហនុមិនមែនជា
នយោបាយស្រោចស្រង់ជាតិនោះទេ ផ្ទុយទៅវិញនយោបាយដែលជននេះតែងអនុវត្តន៏យក
អំណាចរដ្ឋមកប្រើ គឺឃាតកម្មឥតខ្មោះទេសោះ។
ទោះយ៉ាងណាក៏ដោយ ស្តេចស៊ីហនុប្រហែលជាអាយ៉ងគេ ព្រោះគាត់តែងតែបានបំរើជា
និច្ច និងជាឧបករណ៏ ពួកចកុម្មុយនិស្ត(ចិនយួន)។ទង្វើនេះ ព្រោះគាត់សុខចិត្តដើរតួជាអា
យ៉ង ឆ្លើយដោះសាជួយពួកកុម្មុយនិស្តជានិច្ចគ្រប់សំនួររបស់អ្នកសារព័តិមានអន្តរជាតិចោទ
សួរគាត់។
មានមហាអំណាចខ្លះ មានជំនឿថា ស្តេចស៊ីហនុជា”អ្នកធ្វើឯកសមោធាន” អាចជួយមុខ
មាត់គេ ក្នុងការរកដំណោះស្រាយនូវវិបត្តិកម្ពុជាលើសេចក្តីវិនាសនៃប្រជាពលរដ្ឋខ្មែរ! ប៉ុន្តែបើ
និយាយអោយខ្លីទៅ ពួកមហាអំណាចទាំងនោះមានសិទ្ធិអ្វីនឹងបង្ខំអោយប្រជាពលរដ្ឋខ្មែរយក

បែបដោះស្រាយគេ ដែលមានភាពត្រឹមត្រូវតែក្នុងក្រដាស តែស្ថានភាពពិតវិញគឺ «តើមានឃាតកម្មច្រើនប៉ុណ្ណាទៀត ? »។

មានអ្នកដឹងនាំប្រទេសខ្លះទៀតធ្វើឧបទេសដោយអសម្បជញ្ញ គ្មានការទទួលខុសត្រូវ អោយព្រាជាពលរដ្ឋខ្មែរបំភ្លេច”ការសម្លាប់មហាជនខ្មែរ” និងអ្វីៗដែលស្តេចសុីហនុបានធ្វើនៅក្នុងអតីតកាល អោយគិតតែបច្ចុប្បន្នកាលក្នុងដំណោះស្រាយមួយដែលខ្មែរជាជនរកគ្រោះថិតនៅជាអ្នកទស្សនាក្រៅសៃវៀននយោបាយ។ជនដែលបាននិយាយបែបនេះជាមនុស្សរឡិករឡកខ្វះសិលធម៌ ជាឧបាយទុច្ចរិត ជាអំពើថោកទាប គួរយកជនទាំងនោះយកទៅកាត់ទោសនូវអំពើដែលពួកគេត្រៀនក្រើនបន្តនយោបាយបង្ហូរឈាមនៅកម្ពុជាតទៅទៀត។

ឯចំណែកអ្នកតាំងខ្លួនជាអ្នកជំនាញក្នុងបញ្ហាខ្មែរខ្លះ ដែលស្តេចសុីហនុតែងតែលើកមកសរសើរអំពីគុណសម្បត្តិនយោបាយនិងការទូតដ៏ឈ្លាតវៃរបស់ពួកទាំងនោះ តាមពិតអ្នកជំនាញទាំងនេះសុទ្ធជាជនគួរអោយអស់សំណើច រឡិករឡក គ្មានការអៀនខ្មាស សាហាវ មិនស្មោះត្រង់ ក្រអឺតក្រអោង ស្រីត ដូចគ្នានឹងស្តេចសុីហនុដែរ។ដូច្នេះឯកបានជាអ្នកជំនាញទាំងនេះតែងតែសរសេរសរសើរស្តេចសុីហនុ មិនចេះចប់ បំភ្លាត់សេចក្តីពិតអំពីគុណវិបត្តិរបស់សុីហនុ។

យើងដឹងថានៅក្នុងរបបរាជាធិបតេយ្យ ទំនៀមទំលាប់ ប្រពៃណី សាសនា អក្សរសាស្ត្រ ភាសានិយាយ គ្រប់ស្ថាប័នសង្គមឬនយោបាយសុទ្ធតែបង្កើតឡើងដើម្បីផ្សាំងរាស្ត្រខ្មែរអោយគោរពប្រត្តិបមហាក្សត្រទាំងរង្វង់ស្មារតី។